# រាជរដ្ឋាភិបាលកម្ពុជា
## ក្រសួងមុខងារសាធារណៈ

# ឯកសារណែនាំ
# ស្ដីពី
# វិធីសាស្ត្រនៃការវាយតម្លៃនិងការទទួលស្គាល់
# មណ្ឌលសុខភាពគំរូ

"មណ្ឌលសុខភាពផ្ដល់សេវាជូនប្រជាជនកាន់តែប្រសើរឡើង"

**ឆ្នាំ ២០២១**

## រាជរដ្ឋាភិបាលកម្ពុជា

## ក្រសួងមុខងារសាធារណៈ

# ឯកសារណែនាំ
# ស្តីពី
# វិធីសាស្ត្រនៃការវាយតម្លៃនិងការទទួលស្គាល់
# មណ្ឌលសុខភាពគំរូ

"មណ្ឌលសុខភាពផ្តល់សេវាជូនប្រជាជនកាន់តែប្រសើរឡើង"

**ឆ្នាំ ២០២១**

# បុព្វកថា

ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈនយោបាយ "**ឈ្នះ ឈ្នះ**" រាជរដ្ឋាភិបាលបានកសាងសន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍប្រកបដោយចីរភាព។

ក្រោមម្លប់សន្តិភាពដ៏ត្រជាក់នៅក្នុងនីតិកាលទី៦នៃរដ្ឋសភា រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីនយោបាយ ដោយបានកំណត់នូវគោលដៅជាយុទ្ធសាស្ត្រគោលនយោបាយធំៗជាអាទិភាព រួមទាំងគោល-នយោបាយអភិវឌ្ឍតាមវិស័យ និងវិធានការអនុវត្តជាក់ស្ដែងនានា និងជាត្រីវិស័យសម្រាប់តម្រង់ទិសសកម្មភាពរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងបម្រើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏បានដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ដែលជាឧបករណ៍ដ៏មានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា និងជាមូលដ្ឋានគ្រឹះដើម្បីឆ្ពោះទៅសម្រេចគោលដៅនៃចក្ខុវិស័យ កម្ពុជាជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដើម្បីរួមចំណែកសម្រេចគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ បានខិតខំប្រឹងប្រែងក្នុងការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួនក្នុងការចូលរួមជំរុញការអនុវត្តការងារកែទម្រង់គ្រប់ផ្នែក គ្រប់វិស័យឱ្យកាន់តែមានលក្ខណៈទូលំទូលាយ និងស៊ីជម្រៅ ក្នុងគោលដៅធ្វើឱ្យកម្ពុជាមានសុខដុមនីយកម្ម និងការអភិវឌ្ឍប្រកបដោយចីរភាព សំដៅឆ្លើយតបទៅនឹងតម្រូវការរបស់ប្រទេសជាតិនិងប្រជាជន ពិសេសគឺការពង្រឹងប្រសិទ្ធភាពនៃអភិបាលកិច្ចនៅតាមអង្គភាពរបស់ខ្លួន និងការយកចិត្តទុកដាក់ចំពោះការផ្ដល់សេវាសាធារណៈប្រកបដោយគុណភាព មានភាពសាមញ្ញ ភាពងាយស្រួល ភាពឆាប់រហ័ស ឆ្លើយតបទាន់ពេលវេលាទៅនឹងសេចក្ដីត្រូវការពីអ្នកប្រើប្រាស់សេវា និងអាចជឿទុកចិត្តបាន មានប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពសំដៅបម្រើប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង។

ដើម្បីបង្កើនគុណភាព និងស័ក្តិសិទ្ធិភាពនៃការផ្ដល់សេវាសាធារណៈបន្ថែមទៀតនៅក្នុងរដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលបានសម្រួចឆន្ទៈយ៉ាងមុតមាំក្នុងការគាំទ្រនិងលើកទឹកចិត្តដល់គ្រប់បណ្ដាអង្គភាពទាំងអស់ឱ្យមានការចូលរួមប្រកួតប្រជែងការផ្ដល់សេវាសាធារណៈគំរូ ដោយក្នុងក្របខណ្ឌនៃការអនុវត្ត ត្រូវចាប់ផ្ដើមពីវិស័យអាទិភាពខ្ពស់មុន ហើយវិស័យអាទិភាពផ្សេងទៀតនឹងត្រូវបន្តពង្រីកការអនុវត្តបន្ថែមនៅពេលបន្ទាប់។ ផ្អែកតាមសំណើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ ក្នុងក្របខណ្ឌនៃការកែទម្រង់រដ្ឋបាលសាធារណៈ នៅឆ្នាំ២០១៩ រាជរដ្ឋាភិបាលបានសម្រេចដាក់ឱ្យអនុវត្តមុនគេនូវការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល និងបានបង្កើតគណៈកម្មការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈថ្នាក់ជាតិ និងគណៈកម្មការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈនៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យ វាយតម្លៃ និងសម្រិតសម្រាំងជ្រើសបេក្ខភាពអង្គភាពផ្ដល់សេវាសាធារណៈគំរូ ប្រកបដោយតម្លាភាព សុចរិតភាព និងការទទួលខុសត្រូវខ្ពស់។ ការ-សម្រេចដាក់ឱ្យអនុវត្តនូវការប្រកួតប្រជែងការផ្ដល់សេវាសាធារណៈគំរូនេះ ពិតជាបានផ្ដល់នូវអត្ថប្រយោជន៍យ៉ាងសំខាន់ទៅលើរបៀបរបបថ្មីនៃការដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍអង្គភាពប្រកបដោយបរិយាប័ន្ន នវានុវត្តន៍និងបរិស្ថានល្អ ព្រមទាំងមានតម្លាភាព មានគណនេយ្យភាព និងមានការចូលរួមសហការទាំងផ្ទៃក្នុងអង្គភាពទាំងភាគីខាងក្រៅអង្គភាព។ ការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈគំរូ ត្រូវធ្វើឡើងដោយសម្រិតសម្រាំង

និងអនុលោមទៅតាមគោលការណ៍ នីតិវិធី និងសូចនាករច្បាស់លាស់។ សូចនាករដែលរៀបចំឡើងដោយគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ គឺជាមូលដ្ឋានគ្រឹះក្នុងការជំរុញឱ្យមានការផ្លាស់ប្តូរអង្គភាព ការផ្លាស់ប្តូរផ្នត់គំនិតអ្នកដឹកនាំ អ្នកគ្រប់គ្រងនិងមន្ត្រីទាំងអស់ក្នុងអង្គភាពឱ្យចូលរួមសហការគ្នា និងប្រើប្រាស់គំនិតច្នៃប្រឌិតរួមប្រកបដោយនវានុវត្តន៍ ដើម្បីអភិវឌ្ឍអង្គភាពរបស់ខ្លួនប្រកបដោយចីរភាព។

តាងនាមឱ្យ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា គោលការណ៍ នីតិវិធី និងសូចនាករដែលមានលក្ខណៈប្រាកដប្រជាប្រកបដោយឧត្តមានុវត្តន៍ ដែលរៀបចំដោយគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ ដែលមានក្រុមការងារបច្ចេកទេស និងលេខាធិការដ្ឋានជាជំនួយការ នឹងក្លាយជាមូលដ្ឋានគ្រឹះសម្រាប់ធ្វើការ-វាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូ ប្រកបដោយវិជ្ជាជីវៈ មានតម្លាភាព គណនេយ្យភាព និងអាចទទួលយកបានពីគ្រប់ភាគីពាក់ព័ន្ធ។

ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនៃក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល ដែលបានយកចិត្តទុកដាក់និងផ្តល់កិច្ចសហការយ៉ាងល្អជាមួយក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការគាំទ្រ និងជំរុញការរៀបចំនិងដាក់ឱ្យដំណើរការនៃការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូនៅតាមអង្គភាពជាវិទ្យាល័យ អនុវិទ្យាល័យ និងនៅតាមសាលាបឋមសិក្សាសម្រាប់វិស័យអប់រំ និងនៅតាមមន្ទីរពេទ្យបង្អែករាជធានី ខេត្ត មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ដែលផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ កម្រិត២ និងកម្រិត៣ និងនៅតាមមណ្ឌលសុខភាពសម្រាប់វិស័យសុខាភិបាល។

ជាចុងក្រោយ តាងនាមឱ្យ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណា-ចក្រកម្ពុជា ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះឯកឧត្តម រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធាន និងសមាជិកនៃគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈនៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ព្រមទាំងក្រុមការងារបច្ចេកទេស លេខាធិការដ្ឋាននៃគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ និងភាគីពាក់ព័ន្ធផ្សេងទៀត ដែលបានខិតខំប្រឹងប្រែងក្នុងការរៀបចំ និងជំរុញការអនុវត្តការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ឱ្យទទួលបានជោគជ័យ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់៕

ថ្ងៃ ពុធ ៩កើត ខែ ភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាតំណាង**
**ដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**
**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីប្រកាសទទួលស្គាល់ជ័យលាភីអង្គភាព**
**ផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

ផ្អែកតាមការសម្រេចរបស់រាជរដ្ឋាភិបាល តាមរយៈអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្ដីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល នៅឆ្នាំ២០១៩ គណៈកម្មការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈថ្នាក់ជាតិ ដែលមានសមាសភាពពីទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងសុខាភិបាល ក្រសួងបរិស្ថាន គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវខ្ពស់ តម្លាភាព សុចរិតភាព និងវិជ្ជាជីវៈ ក្នុងការវាយតម្លៃនិងទទួលស្គាល់វិទ្យាល័យគំរូសម្រាប់វិស័យអប់រំ និងមន្ទីរពេទ្យបង្អែករាជធានី ខេត្ត និងមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ គំរូ ដែលផ្ដល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ កម្រិត២ និងកម្រិត៣ សម្រាប់វិស័យសុខាភិបាល។

ដើម្បីពង្រីកការអនុវត្តការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្ដល់សេវាសាធារណៈគំរូ នៅតាមអង្គភាពផ្សេងទៀតនៃវិស័យអប់រំនិងវិស័យសុខាភិបាលស្របតាមស្មារតីនៃអនុក្រឹត្យខាងលើ គណៈកម្មការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈថ្នាក់ជាតិ សម្រេចបន្តអនុវត្តការប្រឡងប្រណាំងអង្គភាពផ្ដល់សេវាសាធារណៈគំរូនៅក្នុងចំណោមអនុវិទ្យាល័យនិងសាលាបឋមសិក្សាសម្រាប់វិស័យអប់រំ និងមណ្ឌលសុខភាពសម្រាប់វិស័យសុខាភិបាល។ ដើម្បីបន្តធានានូវសុចរិតភាព តម្លាភាព និងគុណភាពនៃការវាយតម្លៃ គណៈកម្មការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈថ្នាក់ជាតិ ចាំបាច់ត្រូវបន្តពង្រឹងនូវយន្តការ និងគោលការណ៍ នីតិវិធីដែលមានស្រាប់សម្រាប់អនុវត្តការវាយតម្លៃ និងត្រូវរៀបចំតារាងលក្ខណៈវិនិច្ឆ័យរងដោយឡែកសម្រាប់ជាមូលដ្ឋានក្នុងការវាយតម្លៃនិងទទួលស្គាល់អនុវិទ្យាល័យ សាលាបឋមសិក្សា និងមណ្ឌលសុខភាពគំរូ។

ខ្ញុំជឿជាក់ថា តាមរយៈការពង្រីកការអនុវត្តការប្រកួតប្រជែងការផ្ដល់សេវាសាធារណៈគំរូនៅតាមអង្គភាពផ្ដល់សេវាសាធារណៈក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល នឹងធ្វើឱ្យអ្នកគ្រប់គ្រងនិងមន្ត្រីរាជការតាមអង្គភាពផ្ដល់សេវាសាធារណៈនីមួយៗ យកចិត្តទុកដាក់និងចូលរួមយ៉ាងសកម្ម ដើម្បីប្រែក្លាយអង្គភាពរបស់ខ្លួនឱ្យទៅជាអង្គភាពឈានមុខនិងគំរូ លើផ្នែកស្តង់ដានិងនិយាមសេវាសាធារណៈ ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងអង្គភាព ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែលម្អបរិស្ថានអង្គភាព ការទាក់ទងនិងការដោះស្រាយបញ្ហាប្រឈមល្អជាមួយប្រជាពលរដ្ឋ សហគមន៍ ដៃគូអភិវឌ្ឍន៍ និងអ្នកប្រើប្រាស់សេវាសាធារណៈព្រមទាំងឈានមុខនិងគំរូ លើការរិះរកនិងអនុវត្តគំនិតបែបនវានុវត្តន៍។

ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះគណៈកម្មការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈថ្នាក់ជាតិ គណៈកម្មការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ ក្រុមការងារបច្ចេកទេសអន្តរក្រសួង ក្រុមលេខាធិការដ្ឋាននៃ គ.វ.ជ ទាំងអស់ ដែលបានគាំទ្រ និងចូលរួមយ៉ាងសកម្ម និងបានធ្វើឱ្យដំណើរការនៃការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យ

អប់រំ និងវិស័យសុខាភិបាល កន្លងមក ទទួលបានជោគជ័យ។ ឆ្លៀតឱកាសនេះ ខ្ញុំសូមអរគុណដល់ក្រុមការងារបច្ចេកទេសអន្តរក្រសួង និងក្រុមលេខាធិការដ្ឋាននៃ គ.វ.ជ ដែលបានខិតខំបំពេញការងារយ៉ាងសកម្មក្នុងការរៀបចំឯកសារណែនាំស្តីពីវិធីសាស្ត្រនៃការវាយតម្លៃនិងទទួលស្គាល់អនុវិទ្យាល័យនិងសាលាបឋមសិក្សាគំរូ និងឯកសារណែនាំស្តីពីវិធីសាស្ត្រនៃការវាយតម្លៃនិងទទួលស្គាល់មណ្ឌលសុខភាពគំរូនេះឡើង។ ឯកសារណែនាំទាំងពីរនេះ នឹងក្លាយជាត្រីវិស័យសម្រាប់តម្រង់ទិសការអនុវត្តការវាយតម្លៃនិងទទួលស្គាល់អនុវិទ្យាល័យ សាលាបឋមសិក្សា និងមណ្ឌលសុខាភាពរបស់គណៈកម្មការវាយតម្លៃថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌផង និងផ្តល់ជាផែនទីបង្ហាញផ្លូវសម្រាប់អនុវិទ្យាល័យ សាលាបឋមសិក្សា និងមណ្ឌលសុខាភាពនៅទូទាំងប្រទេសរៀបចំនិងកែលម្អការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់ខ្លួនឈានទៅក្លាយជាអង្គភាពគំរូផង។

ជាទីបញ្ចប់ ខ្ញុំសង្ឃឹមថា គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ គណៈកម្មការវាយតម្លៃថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈគ្រប់គ្រងនៃអនុវិទ្យាល័យ សាលាបឋមសិក្សា និងមណ្ឌលសុខភាពទូទាំងប្រទេស នឹងចូលរួមយ៉ាងសកម្មក្នុងចលនាប្រឡងប្រណាំងអង្គភាពផ្តល់សេវាសាធារណៈគំរូនេះ ដើម្បីធ្វើឱ្យការផ្តល់សេវាអប់រំនិងសុខភាពជូនពលរដ្ឋនៅមូលដ្ឋានកាន់តែប្រសើរឡើង។

ថ្ងៃ ចន្ទ ៧ រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធាន**

**គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ**

**កិត្តិបណ្ឌិត ពេជ្រ ប៊ុនធិន**

# អារម្ភកថា

រាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចដាក់ឱ្យអនុវត្តនូវការប្រកួតប្រជែងអង្គភាពផ្តល់សេវាសាធារណៈគំរូ តាមរយៈអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ដើម្បីលើកកម្ពស់អភិបាលកិច្ចក្នុងរដ្ឋបាលសាធារណៈ។

ក្រសួងមុខងារសាធារណៈដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការដឹកនាំការងារកែទម្រង់រដ្ឋបាលសាធារណៈ បានបំពេញតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួល គាំទ្រ និងរៀបចំឱ្យមាននូវយន្តការ គោលការណ៍ នីតិវិធី និងឯកសារលក្ខណៈវិនិច្ឆ័យ ដែលជាមូលដ្ឋានដ៏ចាំបាច់ក្នុងការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងក្របខណ្ឌវិទ្យាល័យ អនុវិទ្យាល័យ និងសាលាបឋមសិក្សាសម្រាប់វិស័យអប់រំ និងមន្ទីរពេទ្យបង្អែករាជធានី ខេត្ត មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ដែលផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ កម្រិត២ និងកម្រិត៣ និងមណ្ឌលសុខភាពសម្រាប់វិស័យសុខាភិបាល។

ក្នុងនាមថ្នាក់ដឹកនាំនៃក្រសួងមុខងារសាធារណៈ ខ្ញុំសូមកោតសរសើរចំពោះគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ និងគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលកន្លងមកបានបំពេញតួនាទីយ៉ាងសកម្មក្នុងការវាយតម្លៃ និងការទទួលស្គាល់វិទ្យាល័យជាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងមន្ទីរពេទ្យបង្អែករាជធានី ខេត្ត មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ដែលផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ កម្រិត២ និងកម្រិត៣ ជាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យសុខាភិបាល។ ខ្ញុំសង្ឃឹមនិងជឿជាក់ថា គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ និងគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នឹងសម្រេចបានជោគជ័យបន្ថែមទៀត ក្នុងកិច្ចការបន្តនៃការវាយតម្លៃនិងទទួលស្គាល់អនុវិទ្យាល័យ និងសាលាបឋមសិក្សា ជាអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ និងមណ្ឌលសុខភាពជាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យសុខាភិបាល។

ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ ខ្ញុំនឹងបន្តគាំទ្រ សម្របសម្រួល និងជំរុញដំណើរការអនុវត្តការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងក្របខណ្ឌអនុវិទ្យាល័យ និងសាលាបឋមសិក្សា សម្រាប់វិស័យអប់រំ និងមណ្ឌលសុខភាព សម្រាប់វិស័យសុខាភិបាល ឱ្យទទួលបានជោគជ័យ ដែលជាការរួមចំណែកក្នុងការសម្រេចសមិទ្ធផលថ្មីៗបន្ថែមទៀតរបស់រាជរដ្ឋាភិបាល។

ថ្ងៃ ច័ន្ទ ៧រោច ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ សីហា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ក្រសួងមុខងារសាធារណៈ**

**ព្រុំ សុខា**

# អារម្ភកថា

ប្រទេសកម្ពុជា ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ ឈ្លាសវៃ និងម៉ឺងម៉ាត់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចាត់ទុកសុខភាពរបស់ប្រជាជន គឺជាស្នូលនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ប្រទេស។ ការវិនិយោគធនធានរបស់រាជរដ្ឋាភិបាលនៅក្នុងបណ្តាឆ្នាំកន្លងមករហូតមកដល់បច្ចុប្បន្ននេះ លើការពង្រឹងប្រព័ន្ធសន្តិសុខសុខភាពជាតិ ជាពិសេសការពង្រឹងហេដ្ឋារចនាសម្ព័ន្ធមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ការរក្សាបាននូវនិរន្តភាពនៃការផ្តល់សេវាថែទាំសុខភាពសារវន្តជាប្រចាំជូនប្រជាពលរដ្ឋនៅក្នុងបរិបទនៃការរាតត្បាតដោយជំងឺឆ្លង បានធ្វើឱ្យប្រព័ន្ធសុខាភិបាលនៃប្រទេសកម្ពុជា កាន់តែមានសមត្ថភាពឆ្លើយតបទៅនឹងតម្រូវការផ្នែកសុខភាពរបស់ប្រជាជន ប្រកបដោយគុណភាព សុវត្ថិភាព និងសមធម៌។

តាមអនុក្រឹត្យលេខ ១១០ អនក្រ.បក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩ ស្តីពី «ការទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល» បានឆ្លុះបញ្ចាំងពីភាពរឹងមាំនិងជោគជ័យរបស់មន្ទីរពេទ្យបង្អែកក្នុងការផ្តល់សេវាថែទាំសុខភាពជូនប្រជាជនកម្ពុជា ប្រកបដោយគុណភាព។ ផ្អែកលើបទពិសោធន៍ដ៏ល្អនេះ គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ (គ.វ.ជ) និងក្រសួងសុខាភិបាលបានសម្រេចបន្តការប្រឡងប្រណាំងអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យសុខាភិបាលដល់មណ្ឌលសុខភាព។

គោលបំណងសំខាន់នៃ «ឯកសារណែនាំស្តីពីវិធីសាស្ត្រនៃការវាយតម្លៃ និងការទទួលស្គាល់មណ្ឌលសុខភាពគំរូ» គឺផ្តល់ជាមគ្គុទេសក៍ណែនាំច្បាស់លាស់ ដល់គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការបំពេញតួនាទីជាអ្នកវាយតម្លៃក្រោមដែនសមត្ថកិច្ចរបស់ខ្លួន និងផ្តល់ជាជំនួយបច្ចេកទេសដល់មណ្ឌលសុខភាពក្នុងការរៀបចំខ្លួនចូលរួមប្រឡងប្រណាំង។ បន្ថែមលើនេះ ឯកសារណែនាំក៏បានបង្ហាញពីទិសដៅនៃការអភិវឌ្ឍ ការកែលម្អការងារគ្រប់គ្រង និងដំណើរការផ្តល់សេវាប្រកបដោយគុណភាព សមធម៌ និងប្រសិទ្ធភាពខ្ពស់ ដើម្បីឱ្យក្លាយជាអង្គភាពផ្តល់សេវាសុខាភិបាលសាធារណៈគំរូ។ ម៉្យាងវិញទៀត ឯកសារណែនាំនេះក៏ផ្តល់សារៈប្រយោជន៍ផងដែរ ដល់ភាគីពាក់ព័ន្ធផ្សេងទៀត រួមទាំងអាជ្ញាធរដែនដី សហគមន៍មូលដ្ឋាន និងភ្នាក់ងារផ្តល់ជំនួយនានា ដើម្បីស្វែងយល់ចូលរួម និងគាំទ្រសកម្មភាពមណ្ឌលសុខភាពនៅទូទាំងប្រទេស សំដៅទាក់ទាញទំនុកចិត្តរបស់ប្រជាជន ក្នុងការប្រើប្រាស់សេវាថែទាំសុខភាពកាន់តែល្អប្រសើរជាងមុនថែមទៀត។

ក្នុងនាមក្រសួងសុខាភិបាល ខ្ញុំសូមកោតសរសើរដ៏ស្មោះដល់ក្រុមការងារបច្ចេកទេសអន្តរក្រសួង និងក្រុមលេខាធិការដ្ឋាននៃ គ.វ.ជ ដែលបានខិតខំរៀបចំចងក្រងឯកសារនេះឡើង សម្រាប់បម្រើការងារសុខាភិបាល

នៅថ្នាក់មណ្ឌលសុខភាព និងប្រើប្រាស់ជាឧបករណ៍ស្តង់ដាក្នុងការជ្រើសរើសអង្គភាពផ្តល់សេវាសុខាភិបាលសាធារណៈគំរូ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងសុក្រឹតភាព។

ទន្ទឹមនឹងនេះ ខ្ញុំសូមលើកទឹកចិត្តដល់មន្ត្រីបុគ្គលិកសុខាភិបាលទាំងអស់ ត្រូវបន្តរក្សាការផ្តល់សេវាថែទាំសុខភាពជូនប្រជាពលរដ្ឋ ឱ្យបានជាប់ជាប្រចាំតាមគន្លងបែបថ្មី ដើម្បីជានាការលើកកម្ពស់លទ្ធផលសុខភាព និងសុខមាលភាពរបស់ប្រជាជនកម្ពុជា។

ថ្ងៃ ច័ន្ទ ២រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០២១

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

# បញ្ជីរាយនាមសមាសភាពក្រុមការងារ

ក្រុមការងារដឹកនាំ តែងនិពន្ធ និងរៀបចំ **ឯកសារណែនាំស្តីពីវិធីសាស្រ្តនៃការវាយតម្លៃ និងការទទួលស្គាល់មណ្ឌលសុខភាពគំរូ** មានសមាសភាពដូចខាងក្រោម៖

## ក. ក្រុមការងារដឹកនាំនិងសម្របសម្រួល

១. ឯកឧត្តម **យក់ ប៊ុនណា** រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ និងជាអនុប្រធានប្រចាំការនៃ គ.វ.ជ.

២. ឯកឧត្តម **ឆាយ ឆត្រាវុធ** អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ

៣. ឯកឧត្តម **ឈុន សុជាតិ** អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈនៃក្រសួងមុខងារសាធារណៈ

៤. ឯកឧត្តម **ប្រាក់ ម៉ូវ** អគ្គនាយករងនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈនៃក្រសួងមុខងារសាធារណៈ

៥. លោក **សៀត វិចិត្រ** ប្រធាននាយកដ្ឋានសេវាសាធារណៈនៃក្រសួងមុខងារសាធារណៈ

## ខ. ក្រុមការងារនិពន្ធនិងរៀបចំអត្ថបទ

១. ឯកឧត្តមបណ្ឌិត **សយ រាសី** អគ្គនាយករងនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈនៃក្រសួងមុខងារសាធារណៈ

២. លោក **រាត់ សុិទ្ធ** អគ្គនាយករងនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាននៃក្រសួងបរិស្ថាន

៣. លោកស្រី **ឈាន អូនដាំ** អគ្គនាយករងនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈនៃក្រសួងមុខងារសាធារណៈ

៤. លោក **លន គីមហេង** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្សនិងស្ថាប័ននៃក្រសួងមុខងារសាធារណៈ

៥. លោក **ជា ផល្លី** ប្រធាននាយកដ្ឋានសុខាភិបាល សង្គមកិច្ច និងកិច្ចការនារីនៃទីស្តីការគណៈរដ្ឋមន្ត្រី

៦. លោកវេជ្ជបណ្ឌិត **លី វិជ្ជារ៉ាវុធ** ប្រធាននាយកដ្ឋានផែនការនិងព័ត៌មានសុខាភិបាលនៃក្រសួងសុខាភិបាល

៧. លោក **ឈឹន សាលីន** អនុប្រធាននាយកដ្ឋានសេវាសាធារណៈនៃក្រសួងមុខងារសាធារណៈ

៨. លោកស្រី **ហាវ ភីរម្យ** ប្រធានការិយាល័យថវិកាវិស័យសង្គមកិច្ចទី២នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៩. លោក **ប៊ុន ម៉ានិត** ប្រធានការិយាល័យមុខងារនិងធនធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយនៃលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប)

១០. លោកស្រី **ពៅ ធីតា** ប្រធានការិយាល័យនៃក្រសួងមុខងារសាធារណៈ

១១. លោកស្រីវេជ្ជបណ្ឌិត **លឹម ខាន់គ្រីកា** អនុប្រធានការិយាល័យធានាគុណភាពសុខាភិបាល នៃក្រសួងសុខាភិបាល

១២. លោក **ហេង សុជាតិ** អនុប្រធានការិយាល័យថវិកាវិស័យសង្គមកិច្ចទី២ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១៣. លោក **អ៊ូច សោភ័ណ** មន្ត្រីជំនាញជាន់ខ្ពស់ត្រួតពិនិត្យនិងវាយតម្លៃគម្រោងនៃ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

១៤. លោក **ហែម សាមឿន** មន្ត្រីការិយាល័យមុខងាររដ្ឋបាលថ្នាក់ក្រោមជាតិនៃ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប)

១៥. លោកស្រី **អ៊ុង វលក្ខទេវី** មន្ត្រីជំនួយការត្រួតពិនិត្យនិងវាយតម្លៃគម្រោងនៃ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

១៦. កញ្ញា **ឡេង ចាន់ភួង** មន្ត្រីជំនួយការត្រួតពិនិត្យនិងវាយតម្លៃគម្រោងនៃ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# មាតិកា

**បុព្វកថា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**.............................I
**អារម្ភកថា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធាន គ.វ.ជ**............III
**អារម្ភកថា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**......................................V
**អារម្ភកថា រដ្ឋមន្ត្រីក្រសួងសុខាភិបាល**......................................VI
**បញ្ជីរាយនាមសមាសភាពក្រុមការងារ**......................................VIII
**មាតិកា**......................................X
**សេចក្តីផ្តើម**......................................១
**ផ្នែកទី១៖ ស្តង់ដាសេវាសាធារណៈ**......................................៣
១.១ គុណភាពព័ត៌មាន......................................៤
១.២ ភាពងាយស្រួលក្នុងការទទួលយកសេវា......................................១០
១.៣ ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា......................................១៤
១.៤ ការផ្តល់សេវាតាមគោលការណ៍កំណត់ និងអភិបាលកិច្ចល្អ......................................១៧
**ផ្នែកទី២៖ ស្តង់ដាបទដ្ឋានិយាមនៃការផ្តល់សេវាសាធារណៈក្នុងវិស័យសុខាភិបាលសម្រាប់មណ្ឌលសុខភាព**......................................២១
២.១ ការដឹកនាំ និងការគ្រប់គ្រងមណ្ឌលសុខភាព......................................២២
២.២ ការបង្ការ ការត្រួតពិនិត្យការចម្លងរោគ និងអនាម័យ......................................២៨
២.៣ ការលើកកម្ពស់គុណភាពសេវាក្នុងមណ្ឌលសុខភាព......................................៣៦
២.៤ លទ្ធផលនៃការអនុវត្តការលើកកម្ពស់គុណភាពសេវាក្នុងមណ្ឌលសុខភាព......................................៤២
**ផ្នែកទី៣៖ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព**......................................៥៧
៣.១ ភាពជឿទុកចិត្តនៃថវិកា......................................៥៨
៣.២ ប្រព័ន្ធគ្រប់គ្រងគណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋ......................................៦១
៣.៣ ការតាមដាន និងការត្រួតពិនិត្យហិរញ្ញវត្ថុ......................................៦៣
**ផ្នែកទី៤៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព**......................................៦៥
៤.១ ការគ្រប់គ្រងធនធានមនុស្ស......................................៦៦
៤.២ ការអភិវឌ្ឍធនធានមនុស្ស......................................៧១
**ផ្នែកទី៥៖ ការរៀបចំ និងកែលម្អបរិស្ថានអង្គភាព**......................................៧៥
៥.១ ទស្សនវិស័យ និងសកម្មភាពមេត្រីភាពបរិស្ថាន(មានភាពស្អាត និងភាពបៃតងនៅក្នុងបរិវេណមណ្ឌលសុខភាព)......................................៧៦
៥.២ ការបញ្ជ្រាបការយល់ដឹង និងអនុវត្តអនាម័យបរិស្ថាន......................................៧៧

៥.៣ មេត្រីភាពបរិស្ថាននៅក្នុងបរិវេណមណ្ឌលសុខភាព ......... ៧៩
៥.៤ ការគ្រប់គ្រងសំណល់នៅមណ្ឌលសុខភាព ......... ៨៣
**ផ្នែកទី៦៖ ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ** ......... ៨៧
៦.១ ការពង្រឹងទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ ......... ៨៨
**ផ្នែកទី៧៖ ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ អាជ្ញាធរ និងសហគមន៍** .. ៩៣
៧.១ យន្តការព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា ......... ៩៤
៧.២ ការសហការជាមួយអាជ្ញាធរ សហគមន៍ និងមណ្ឌលសុខភាពដទៃ ដើម្បីដោះស្រាយបញ្ហារបស់អ្នកប្រើប្រាស់សេវា ......... ៩៦
**ផ្នែកទី៨៖ ការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍ ដើម្បីធ្វើឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរ** ......... ៩៧
៨.១ ការបញ្ជ្រាបការយល់ដឹងអំពីប្រធានបទនវានុវត្តន៍ និងការច្នៃប្រឌិត ដើម្បីជំរុញឱ្យអង្គភាពដំណើរការកាន់តែប្រសើរ ......... ៩៨
៨.២ ការដឹកនាំអនុវត្ត ការជំរុញ និងការគាំទ្រការអនុវត្តគំនិតច្នៃប្រឌិត និងនវានុវត្តន៍ក្នុងអង្គភាពផ្តល់សេវា ......... ៩៨
**សេចក្តីសន្និដ្ឋាន** ......... ១០១
**គន្ថនិទ្ទេស** ......... ១០២

# ឯកសារណែនាំស្តីពីវិធីសាស្ត្រនៃការវាយតម្លៃនិងការទទួលស្គាល់ មណ្ឌលសុខភាពគំរូ

## សេចក្តីផ្តើម

**អរគុណសន្តិភាព** សមិទ្ធផលគ្រប់វិស័យបានរីកដុះដាលនិងអភិវឌ្ឍឥតឈប់ឈរ។ កម្ពុជាបានឆ្លងកាត់ពីស្ថានភាពក្នុងឋានៈជាប្រទេសដែលមានចំណូលទាបមកជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបព្រមទាំងបាន និងកំពុងពង្រឹងសាមគ្គីភាពគ្រប់ផ្នែកនៃសង្គមជាតិឈានទៅកាន់ឋានៈជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០ ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកសុខភាពប្រជាពលរដ្ឋជាស្នូលនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមនៃព្រះរាជាណាចក្រកម្ពុជា។ វឌ្ឍនភាពនៃការពង្រីកហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលនិងការគ្របដណ្តប់នៃសេវាបានធ្វើឱ្យការប្រើប្រាស់សេវាសុខភាពកើនដល់កម្រិតមួយដែលពុំធ្លាប់មានពីមុនមកនៅក្នុងទសវត្សចុងក្រោយនេះ។ ភាពរឹងមាំនៃប្រព័ន្ធសុខាភិបាល រួមជាមួយវឌ្ឍនភាពនៃវិស័យផ្សេងទៀត ដូចជា ចីរភាពនៃកំណើនសេដ្ឋកិច្ច ល្បឿនលឿននៃការកាត់បន្ថយភាពក្រីក្រ បានធ្វើឱ្យសុខភាពនិងសុខុមាលភាពប្រជាពលរដ្ឋកម្ពុជាកាន់តែប្រសើរឡើង។ ប្រទេសកម្ពុជាបានសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាទាក់ទងនឹងសុខភាពមុនកាលកំណត់។ ទោះជាដូច្នេះក្តី ការបន្តលើកស្ទួយសុខភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជាស្ថិតនៅជាអាទិភាពខ្ពស់ក្នុងរបៀបវារៈនៃគោលនយោបាយសង្គមកិច្ចនិងសេដ្ឋកិច្ចនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

ប្រព័ន្ធនៃការផ្តល់សេវាសុខាភិបាលនៅកម្ពុជា រួមមាន៖ មន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែករាជធានី ខេត្ត មន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព។ មន្ទីរពេទ្យជាតិផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត៣ និងសេវាឯកទេសកម្រិតខ្ពស់ មន្ទីរពេទ្យបង្អែករាជធានី ខេត្តផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត២ឬកម្រិត៣ មន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ឬកម្រិត២ និងមណ្ឌលសុខភាព ផ្តល់សេវាសុខាភិបាលជាមូលដ្ឋាននិងចាំបាច់ជូនដល់ប្រជាជន ដូចមានចែងក្នុង "សំណុំសកម្មភាពអប្បបរមា"។

ក្នុងគោលដៅរួមចំណែកលើកកម្ពស់គុណភាពសេវាសុខាភិបាលឱ្យកាន់តែប្រសើរឡើងថែមទៀត គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ បានសម្រេចកំណត់យកមណ្ឌលសុខភាពជាគោលដៅនៃការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ បន្ទាប់ពីមន្ទីរពេទ្យបង្អែករាជធានី ខេត្ត និងមន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ ដែលត្រូវបានអនុវត្តនៅឆ្នាំ២០១៩។ ការចូលរួមក្នុងចលនាប្រឡងប្រណាំងនេះនឹងជំរុញឱ្យមណ្ឌលសុខភាពនៅទូទាំងប្រទេសអភិវឌ្ឍខ្លួនកាន់តែលឿននិងធ្វើឱ្យប្រជាពលរដ្ឋកាន់តែពេញចិត្តនិងមានទំនុកចិត្តលើសេវាសុខាភិបាលសាធារណៈបន្ថែមទៀត។

ឯកសារណែនាំស្ដីពីវិធីសាស្ត្រនៃការវាយតម្លៃនិងការទទួលស្គាល់មណ្ឌលសុខភាពគំរូ ត្រូវបានរៀបចំឡើង ដើម្បីជាជំនួយបច្ចេកទេសដល់គណៈកម្មការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការអនុវត្តតួនាទីវាយតម្លៃក្រោមដែនសមត្ថកិច្ចរបស់ខ្លួន និងផ្ដល់ជាមគ្គុទេសក៍ដល់អង្គភាពគោលដៅនៃការវាយតម្លៃក្នុងការរៀបចំខ្លួនចូលរួមប្រឡងប្រណាំង ព្រមទាំងបង្ហាញទិសដៅនៃការអភិវឌ្ឍមណ្ឌលសុខភាព ទៅជាអង្គភាពផ្ដល់សេវាសុខាភិបាលសាធារណៈគំរូផងដែរ។

ឯកសារណែនាំនេះ ត្រូវបានរៀបចំជាប្រាំបីផ្នែកស្របតាមលក្ខណៈវិនិច្ឆ័យគោលទាំងប្រាំបីនៃតារាងវាយតម្លៃនិងទទួលស្គាល់មណ្ឌលសុខភាពគំរូ ក្នុងនោះបានផ្ដល់នូវសេចក្ដីពន្យល់លម្អិតពីលក្ខណៈវិនិច្ឆ័យរងនីមួយៗ ពីមធ្យោបាយ និងវិធីសាស្ត្រឬការដាក់ពិន្ទុក្នុងការវាយតម្លៃ។

# ផ្នែកទី១៖ ស្តង់ដាសេវាសាធារណៈ

## ១. ស្តង់ដាសេវាសាធារណៈ (១៣០ពិន្ទុ)

ស្តង់ដាសេវាសាធារណៈ គឺជាម៉ែត្រវាស់កម្រិតគុណភាព និងចរិតលក្ខណៈនៅក្នុងការផ្តល់សេវាសាធារណៈដើម្បីទទួលបាននូវការពេញចិត្តពីសំណាក់អ្នកប្រើប្រាស់សេវាតាមលក្ខខណ្ឌកំណត់(ដូចជាការផ្តល់ព័ត៌មាន នីតិវិធី ឯកសារតម្រូវ ពេលវេលា តម្លៃ ទីកន្លែង និងឥរិយាបថរបស់អ្នកផ្តល់សេវា...) និងឆ្លើយទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់សេវា។

ការកំណត់ស្តង់ដាសេវាសាធារណៈជាលក្ខណៈវិនិច្ឆ័យគោលមួយនៃការវាយតម្លៃគឺដើម្បីជំរុញឱ្យមណ្ឌលសុខភាពបង្កើននូវគុណភាពនៃកាផ្តល់សេវារបស់ខ្លួនឱ្យកាន់តែប្រសើរឡើងថែមទៀត តាមរយៈការបង្កើននូវការផ្សព្វផ្សាយព័ត៌មាន ការបង្កនូវភាពងាយស្រួលក្នុងការទទួលបានសេវា និងភាពយកចិត្តទុកដាក់ចំពោះអ្នកប្រើប្រាស់សេវា ព្រមទាំងការផ្តល់សេវាដោយផ្អែកលើគោលការណ៍ដែលបានកំណត់។

នៅក្នុងផ្នែកស្តង់ដាសេវាសាធារណៈ មានពិន្ទុសរុបចំនួន១៣០ ដែលមានលក្ខណៈវិនិច្ឆ័យរងចំនួន៤ គឺ៖

**១. គុណភាពព័ត៌មាន** (៥០ពិន្ទុ)

**២. ភាពងាយស្រួលក្នុងការទទួលយកសេវា** (៣៥ពិន្ទុ)

**៣. ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា** (២០ពិន្ទុ)

**៤. ការផ្តល់សេវាតាមគោលការណ៍កំណត់ និងអភិបាលកិច្ចល្អ** (២៥ពិន្ទុ)

## ១.១ គុណភាពព័ត៌មាន (៥០ពិន្ទុ)

### ១.១.១ បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសេវា (១០ពិន្ទុ)

➢ ការរក្សាទុកបទដ្ឋានគតិយុត្តទាំងអស់ដែលពាក់ព័ន្ធនឹងសេវារបស់មណ្ឌលសុខភាពសម្រាប់អ្នកប្រើប្រាស់អាចពិនិត្យផ្ទៀងផ្ទាត់អំពីសេវាសាធារណៈ

- *សេចក្តីពន្យល់៖* សំដៅដល់បទដ្ឋានគតិយុត្តទាំងអស់ដែលពាក់ព័ន្ធនឹងដំណើរការនៃការផ្តល់សេវារបស់មណ្ឌលសុខភាពត្រូវបានរក្សាទុកយ៉ាងត្រឹមត្រូវនិងរក្សានៅកន្លែងដែលអ្នកប្រើប្រាស់អាចពិនិត្យផ្ទៀងផ្ទាត់បាន។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ១)ឯកសារបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការផ្តល់សេវារបស់អង្គភាព ២)ទីកន្លែងរក្សាទុកឯកសារ និង៣)សណ្តាប់ធ្នាប់ឯកសារ។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖*

| | |
|---|---|
| ពិន្ទុ ៥ | បទដ្ឋានគតិយុត្តទាំងអស់ដែលពាក់ព័ន្ធនឹងសេវារបស់មណ្ឌលសុខភាពមានរក្សាទុក មានសណ្តាប់ធ្នាប់ នៅផ្នែកជួរមុខ និងផ្នែករដ្ឋបាល |
| ពិន្ទុ ៤ | បទដ្ឋានគតិយុត្តទាំងអស់ដែលពាក់ព័ន្ធនឹងសេវារបស់មណ្ឌលសុខភាពមានរក្សាទុក នៅផ្នែកជួរមុខ និងផ្នែករដ្ឋបាល ប៉ុន្តែការរក្សាទុកមិនមានសណ្តាប់ធ្នាប់ |
| ពិន្ទុ ៣ | បទដ្ឋានគតិយុត្តទាំងអស់ដែលពាក់ព័ន្ធនឹងសេវារបស់មណ្ឌលសុខភាពមានរក្សាទុក នៅតែផ្នែកជួរមុខ |
| ពិន្ទុ ២ | បទដ្ឋានគតិយុត្តទាំងអស់ដែលពាក់ព័ន្ធនឹងសេវារបស់មណ្ឌលសុខភាពមានរក្សាទុក នៅតែផ្នែករដ្ឋបាល |
| ពិន្ទុ ១ | បទដ្ឋានគតិយុត្តមួយចំនួនដែលពាក់ព័ន្ធនឹងសេវារបស់មណ្ឌលសុខភាពមានរក្សាទុក នៅតែផ្នែករដ្ឋបាល ឬផ្នែកជួរមុខ និងគ្មានសណ្តាប់ធ្នាប់ |
| ពិន្ទុ ០ | បទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងសេវារបស់មណ្ឌលសុខភាពមិនមានរក្សាទុកនៅផ្នែករដ្ឋបាល ឬផ្នែកជួរមុខ |

- *ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖* បទដ្ឋានគតិយុត្តនៅក្នុងន័យនេះ មិនមែនជាឯកសារអ្នកជំងឺទេ។

➢ បទបញ្ជាផ្ទៃក្នុងសម្រាប់មណ្ឌលសុខភាព

- *សេចក្តីពន្យល់៖* សំដៅដល់បទបញ្ជាដែលរៀបចំឡើងដោយមណ្ឌលសុខភាពសម្រាប់ប្រើក្នុងមណ្ឌលសុខភាពដែលបានបិទផ្សាយជាសាធារណៈ។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ១)បទបញ្ជាផ្ទៃក្នុង និង២)ការបិទផ្សាយ។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖*

| | |
|---|---|
| ពិន្ទុ ៥ | មានបទបញ្ជាផ្ទៃក្នុងសម្រាប់មណ្ឌលសុខភាពជាទម្រង់A3 និងមានការបិទផ្សាយនៅផ្នែកជួរមុខនិងកន្លែងដទៃក្នុងបរិវេណមណ្ឌលសុខភាព |

| | |
|---|---|
| ពិន្ទុ ៤ | មានបទបញ្ជាផ្ទៃក្នុងសម្រាប់មណ្ឌលសុខភាពជាទម្រង់A3 និងមានការបិទផ្សាយនៅផ្នែកជួរមុខ |
| ពិន្ទុ ៣ | មានបទបញ្ជាផ្ទៃក្នុងសម្រាប់មណ្ឌលសុខភាពជាទម្រង់A3 និងមានការបិទផ្សាយនៅកន្លែងដទៃក្នុងបរិវេណមណ្ឌលសុខភាព |
| ពិន្ទុ ២ | មានបទបញ្ជាផ្ទៃក្នុងសម្រាប់មណ្ឌលសុខភាពជាទម្រង់A4 និងមានការបិទផ្សាយនៅផ្នែកជួរមុខ |
| ពិន្ទុ ១ | មានបទបញ្ជាផ្ទៃក្នុងសម្រាប់មណ្ឌលសុខភាពជាទម្រង់A3 ប៉ុន្តែមិនមានការបិទផ្សាយ |
| ពិន្ទុ ០ | មិនមានបទបញ្ជាផ្ទៃក្នុងសម្រាប់មណ្ឌលសុខភាព |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ក្នុងករណីដែលមានអង្គភាពមួយចំនួនយកបទដ្ឋានគតិយុត្ត(ប្រកាសរបស់ក្រសួងស្ថាប័ន ដីការបស់រាជធានីខេត្ត...) មកបិទប្រកាសហើយប្រាប់ថា ជាបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនគឺត្រូវផ្តល់ពិន្ទុ០។

### ១.១.២ ការផ្សព្វផ្សាយព័ត៌មាន (៣០ពិន្ទុ)

➢ <u>ការផ្សព្វផ្សាយប្រភេទនិងតម្លៃសេវា</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការផ្សព្វផ្សាយប្រភេទសេវានិងតម្លៃសេវារបស់មណ្ឌលសុខភាពដែលបានអនុម័តនិងដាក់ឱ្យដំណើរការនៅមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)តារាងប្រភេទសេវានិងតម្លៃសេវា ២)ទំហំតារាងប្រភេទសេវានិងតម្លៃសេវា និង៣)ការបិទផ្សាយ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានតារាងប្រភេទសេវានិងតម្លៃសេវាជាទម្រង់ផ្ទាំងធំ និងងាយស្រួលអាន មានការបិទផ្សាយនៅផ្នែកជួរមុខ និងមានជាទម្រង់ផ្សេងទៀតបិទផ្សាយនៅកន្លែងដទៃក្នុងបរិវេណមណ្ឌលសុខភាព |
| ពិន្ទុ ៤ | មានតារាងប្រភេទសេវានិងតម្លៃសេវាជាទម្រង់ផ្ទាំងធំ និងងាយស្រួលអាន មានការបិទផ្សាយនៅផ្នែកជួរមុខ |
| ពិន្ទុ ៣ | មានតារាងប្រភេទសេវានិងតម្លៃសេវាជាទម្រង់ផ្ទាំងធំ មានការបិទផ្សាយនៅផ្នែកជួរមុខ និងជាទម្រង់ផ្សេងទៀតបិទផ្សាយនៅកន្លែងដទៃក្នុងបរិវេណមណ្ឌលសុខភាព ប៉ុន្តែពិបាកអាន |
| ពិន្ទុ ២ | មានតារាងប្រភេទសេវានិងតម្លៃសេវាជាទម្រង់ផ្ទាំងធំ មានការបិទផ្សាយនៅផ្នែកជួរមុខ ប៉ុន្តែពិបាកអាន និងមិនមានបិទផ្សាយនៅកន្លែងដទៃក្នុងបរិវេណមណ្ឌលសុខភាព |
| ពិន្ទុ ១ | មានតារាងប្រភេទសេវានិងតម្លៃសេវាជាទម្រង់ផ្ទាំងតូច និងមានការបិទផ្សាយតែនៅផ្នែកជួរមុខ ប៉ុន្តែពិបាកអាន និងមិនមានបិទផ្សាយនៅកន្លែងដទៃក្នុងបរិវេណមណ្ឌលសុខភាព |
| ពិន្ទុ ០ | មិនមានតារាងប្រភេទនិងតម្លៃសេវា |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ក្នុងករណីដែលមណ្ឌលសុខភាពណាមួយមិនបានយកថ្លៃសេវាក៏ដោយ ក៏ត្រូវរៀបចំឱ្យមានតារាងប្រភេទសេវាដែរ ហើយត្រូវបិទផ្សាយជាសាធារណៈ។

➢ **ការផ្សព្វផ្សាយឯកសារតម្រូវ និងលក្ខខណ្ឌក្នុងការទទួលបានសេវាសាធារណៈ**

- ***សេចក្តីពន្យល់៖*** សំដៅដល់ការផ្សព្វផ្សាយជាសាធារណៈនូវឯកសារភ្ជាប់និងលក្ខខណ្ឌនានាដែលអ្នកប្រើប្រាស់សេវាត្រូវបំពេញដើម្បីទទួលបានសេវាពីមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផ្ទាំងឯកសារតម្រូវនិងលក្ខខណ្ឌក្នុងការទទួលបានសេវាសាធារណៈ ២)ទំហំផ្ទាំង និង៣)ការបិទផ្សាយ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានឯកសារតម្រូវ និងលក្ខខណ្ឌដើម្បីទទួលបានសេវាសាធារណៈជាទម្រង់ផ្ទាំងA3 ងាយស្រួលអាន និងមានការបិទផ្សាយនៅផ្នែកជួរមុខ និងនៅកន្លែងដទៃក្នុងបរិវេណមណ្ឌលសុខភាព |
| ពិន្ទុ ៤ | មានឯកសារតម្រូវ និងលក្ខខណ្ឌដើម្បីទទួលបានសេវាសាធារណៈជាទម្រង់ផ្ទាំងA3 និងមានការបិទផ្សាយនៅផ្នែកជួរមុខ |
| ពិន្ទុ ៣ | មានឯកសារតម្រូវ និងលក្ខខណ្ឌដើម្បីទទួលបានសេវាសាធារណៈជាទម្រង់ផ្ទាំងA4 និងមានការបិទផ្សាយនៅផ្នែកជួរមុខ និងនៅកន្លែងដទៃក្នុងបរិវេណមណ្ឌលសុខភាព |
| ពិន្ទុ ២ | មានឯកសារតម្រូវ និងលក្ខខណ្ឌដើម្បីទទួលបានសេវាសាធារណៈជាទម្រង់ផ្ទាំងA3 និងមានការបិទផ្សាយនៅកន្លែងដទៃក្នុងបរិវេណមណ្ឌលសុខភាព |
| ពិន្ទុ ១ | មានឯកសារតម្រូវ និងលក្ខខណ្ឌដើម្បីទទួលបានសេវាសាធារណៈជាទម្រង់ផ្ទាំងA4 និងមានការបិទផ្សាយនៅផ្នែកជួរមុខ |
| ពិន្ទុ ០ | មិនមានតារាងព័ត៌មានស្តីពីឯកសារតម្រូវ និងលក្ខខណ្ឌក្នុងការទទួលបានសេវាសាធារណៈ |

➢ **ការផ្សព្វផ្សាយម៉ោងពេលបំពេញការងារ និងមធ្យោបាយទំនាក់ទំនងអង្គភាពសេវា**

- ***សេចក្តីពន្យល់៖*** សំដៅដល់ការបិទផ្សាយនូវម៉ោងពេលបំពេញការងាររបស់អ្នកផ្តល់សេវា(គ្រូពេទ្យ...) នៅមណ្ឌលសុខភាព និងមធ្យោបាយនានាសម្រាប់ឱ្យអ្នកប្រើប្រាស់សេវា ឬប្រជាពលរដ្ឋ ឬភាគីពាក់ព័ន្ធអាចធ្វើទំនាក់ទំនងជាមួយមន្ត្រី ឬអ្នកផ្តល់សេវានៅមណ្ឌលសុខភាព មានដូចជា លេខទូរស័ព្ទ បណ្តាញទំនាក់ទំនងសង្គម...។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផ្ទាំងម៉ោងពេលបំពេញការងាររបស់គ្រូពេទ្យនិងមធ្យោបាយនានាសម្រាប់ទំនាក់ទំនង ២)ទំហំផ្ទាំង និង៣)ការបិទផ្សាយ។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានកាលវិភាគបំពេញការងារ និងមធ្យោបាយទំនាក់ទំនងអង្គភាពផ្តល់សេវាជាទម្រង់ផ្ទាំងA3 និងមានការបិទផ្សាយនៅផ្នែកជួរមុខ និងនៅកន្លែងដទៃក្នុងបរិវេណមណ្ឌលសុខភាព |
| ពិន្ទុ ៤ | មានកាលវិភាគបំពេញការងារ និងមធ្យោបាយទំនាក់ទំនងអង្គភាពផ្តល់សេវា ជាទម្រង់ផ្ទាំងA3 និងមានការបិទផ្សាយនៅផ្នែកជួរមុខ |
| ពិន្ទុ ៣ | មានកាលវិភាគបំពេញការងារ និងមធ្យោបាយទំនាក់ទំនងអង្គភាពផ្តល់សេវាជាទម្រង់ផ្ទាំងA4 និងមានការបិទផ្សាយនៅផ្នែកជួរមុខ និងនៅកន្លែងដទៃក្នុងបរិវេណមណ្ឌលសុខភាព |
| ពិន្ទុ ២ | មានកាលវិភាគបំពេញការងារ និងមធ្យោបាយទំនាក់ទំនងអង្គភាពផ្តល់សេវាជាទម្រង់ផ្ទាំងA3 និងមានការបិទផ្សាយនៅកន្លែងដទៃក្នុងបរិវេណមណ្ឌលសុខភាព |
| ពិន្ទុ ១ | មានកាលវិភាគបំពេញការងារ និងមធ្យោបាយទំនាក់ទំនងអង្គភាពផ្តល់សេវាជាទម្រង់ផ្ទាំងA4 និងមានការបិទផ្សាយនៅផ្នែកជួរមុខ |
| ពិន្ទុ ០ | មិនមានការបិទផ្សាយកាលវិភាគបំពេញការងារ និងមធ្យោបាយទំនាក់ទំនងអង្គភាពសេវា |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ចំពោះមណ្ឌលសុខភាពដែលមានផ្ទាំងកាលវិភាគបំពេញការងារដាច់ពីផ្ទាំងមធ្យោបាយទំនាក់ទំនងអង្គភាពផ្តល់សេវា គឺត្រូវបានវាយតម្លៃដូច មណ្ឌលសុខភាពដែលកាលវិភាគបំពេញការងារ និងមធ្យោបាយទំនាក់ទំនងអង្គភាពផ្តល់សេវាស្ថិតក្នុងផ្ទាំងតែមួយ។ ក្នុងករណីដែលមណ្ឌលសុខភាពណាមានតែកាលវិភាគបំពេញការងារ ឬមធ្យោបាយទំនាក់ទំនងអង្គភាពផ្តល់សេវាគឺត្រូវផ្តល់ពិន្ទុខ្ពស់បំផុតត្រឹមចំនួន២ ហើយអាចបានពិន្ទុទាបជាងនេះទៅតាមករណីជាក់ស្តែង។

## ➢ <u>ការផ្សព្វផ្សាយចរន្តនៃការផ្តល់សេវា</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការគូសបង្ហាញនិងការបិទផ្សាយនូវចរន្តឬរំហូរការងារឬបណ្តាកន្លែងដែលអ្នកជំងឺនឹងទទួលបានសេវានៅក្នុងដំណើរការនៃការទទួលសេវាពីមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផ្ទាំងចរន្តនៃការផ្តល់សេវា និង២)ការបិទផ្សាយ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានគំនូសបង្ហាញអំពីចរន្តឬរំហូរនៃការផ្តល់សេវាជាទម្រង់ផ្ទាំងធំ ងាយស្រួលអាន និងមានការបិទផ្សាយនៅផ្នែកជួរមុខនិងនៅកន្លែងដទៃក្នុងបរិវេណមណ្ឌលសុខភាព |
| ពិន្ទុ ៤ | មានគំនូសបង្ហាញអំពីចរន្តឬរំហូរនៃការផ្តល់សេវាជាទម្រង់ផ្ទាំងធំ និងមានការបិទផ្សាយនៅផ្នែកជួរមុខ |

| | |
|---|---|
| ពិន្ទុ ៣ | មានគំនូសបង្ហាញអំពីចរន្តឬរំហូរនៃការផ្តល់សេវាជាទម្រង់A3 និងមានការបិទផ្សាយនៅផ្នែកជួរមុខ និងនៅកន្លែងដទៃក្នុងបរិវេណមណ្ឌលសុខភាព |
| ពិន្ទុ ២ | មានគំនូសបង្ហាញអំពីចរន្តឬរំហូរនៃការផ្តល់សេវាជាទម្រង់A3 និងមានការបិទផ្សាយនៅផ្នែកជួរមុខ |
| ពិន្ទុ ១ | មានគំនូសបង្ហាញអំពីចរន្តឬរំហូរនៃការផ្តល់សេវាជាទម្រង់A4 និងមានការបិទផ្សាយនៅផ្នែកជួរមុខ |
| ពិន្ទុ ០ | មិនមានការបិទផ្សាយអំពីចរន្តឬរំហូរនៃការផ្តល់សេវា |

➢ <u>ការផ្សព្វផ្សាយរយៈពេលនៃការរង់ចាំចុះឈ្មោះអ្នកជំងឺ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការកំណត់និងការបិទផ្សាយនូវរយៈពេលនៃការរង់ចាំរបស់អ្នកជំងឺដើម្បីទទួលបានការចុះឈ្មោះពីគ្រូពេទ្យនៅផ្នែកជួរមុខ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផ្ទាំងកំណត់រយៈពេលនៃការរង់ចាំចុះឈ្មោះអ្នកជំងឺ និង២)ការបិទផ្សាយ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានការកំណត់រយៈពេលនៃការរង់ចាំចុះឈ្មោះអ្នកជំងឺ ដោយរៀបចំជាទម្រង់ផ្ទាំងA4 ងាយស្រួលអាន និងមានការបិទផ្សាយនៅផ្នែកជួរមុខនិងនៅកន្លែងដទៃក្នុងបរិវេណមណ្ឌលសុខភាព |
| ពិន្ទុ ៤ | មានការកំណត់រយៈពេលនៃការរង់ចាំចុះឈ្មោះអ្នកជំងឺ ដោយរៀបចំជាទម្រង់ផ្ទាំងA4 មិនងាយស្រួលក្នុងការអាន ប៉ុន្តែមានការបិទផ្សាយនៅផ្នែកជួរមុខនិងនៅកន្លែងដទៃក្នុងបរិវេណមណ្ឌលសុខភាព |
| ពិន្ទុ ៣ | មានការកំណត់រយៈពេលនៃការរង់ចាំចុះឈ្មោះអ្នកជំងឺ ដោយរៀបចំជាទម្រង់ផ្ទាំងA4 និងមានការបិទផ្សាយនៅផ្នែកជួរមុខ |
| ពិន្ទុ ២ | មានការកំណត់រយៈពេលនៃការរង់ចាំចុះឈ្មោះអ្នកជំងឺ ដោយរៀបចំជាទម្រង់ផ្ទាំងA4 និងមានការបិទផ្សាយនៅកន្លែងដទៃក្នុងបរិវេណមណ្ឌលសុខភាព |
| ពិន្ទុ ១ | មានការកំណត់រយៈពេលនៃការរង់ចាំចុះឈ្មោះអ្នកជំងឺជាទម្រង់ផ្ទាំងA4 ប៉ុន្តែមិនបានបិទផ្សាយ |
| ពិន្ទុ ០ | មិនមានការកំណត់និងបិទផ្សាយ |

➢ <u>ការផ្សព្វផ្សាយផែនការកែលម្អគុណភាពសេវា</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរៀបចំនិងការបិទផ្សាយនូវផែនការស្តីពីការកែលម្អគុណភាពសេវារបស់មណ្ឌលសុខភាព។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផ្ទាំងផែនការកែលម្អគុណភាពសេវា និង២)ការបិទផ្សាយ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានផែនការកែលម្អគុណភាពសេវាជាទម្រង់ផ្ទាំងA3 និងមានការបិទផ្សាយនៅផ្នែកជួរមុខនិងនៅកន្លែងផ្សេងទៀតក្នុងបរិវេណមណ្ឌលសុខភាព |
| ពិន្ទុ ៤ | មានផែនការកែលម្អគុណភាពសេវាជាទម្រង់ផ្ទាំងA3 និងមានការបិទផ្សាយនៅផ្នែកជួរមុខ |
| ពិន្ទុ ៣ | មានផែនការកែលម្អគុណភាពសេវាជាទម្រង់ផ្ទាំងA4 និងមានការបិទផ្សាយនៅផ្នែកជួរមុខនិងនៅកន្លែងផ្សេងទៀតក្នុងបរិវេណមណ្ឌលសុខភាព |
| ពិន្ទុ ២ | មានផែនការកែលម្អគុណភាពសេវាជាទម្រង់ផ្ទាំងA4 និងមានការបិទផ្សាយនៅផ្នែកជួរមុខ |
| ពិន្ទុ ១ | មានផែនការកែលម្អគុណភាពសេវា ប៉ុន្តែមិនបានបិទផ្សាយ |
| ពិន្ទុ ០ | មិនមានផែនការកែលម្អគុណភាពសេវា |

### ១.១.៣ មធ្យោបាយផ្សព្វផ្សាយ(១០ពិន្ទុ)

➢ <u>ការផ្សព្វផ្សាយតាមប្រព័ន្ធមិនមែនអេឡិចត្រូនិក</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការផ្សព្វផ្សាយព័ត៌មានានាដែលពាក់ព័ន្ធនឹងមណ្ឌលសុខភាពតាមរយៈឧគ្ឃោសនសព្ទ ប័ណ្ណប្រកាស ក្រុមទ្រទ្រង់សុខភាពភូមិ អាជ្ញាធរដែនដី សហគមន៍ និងការផ្សាយនៅនឹងកន្លែងជាដើម។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ មធ្យោបាយនៃការផ្សព្វផ្សាយរួមមានឧគ្ឃោសនសព្ទ ប័ណ្ណប្រកាស ក្រុមទ្រទ្រង់សុខភាពភូមិ អាជ្ញាធរដែនដី សហគមន៍ និងការផ្សាយនៅនឹងកន្លែង។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការផ្សព្វផ្សាយតាមឧគ្ឃោសនសព្ទ |
| ពិន្ទុ ១ | មានការផ្សព្វផ្សាយតាមក្រុមទ្រទ្រង់សុខភាពភូមិ |
| ពិន្ទុ ១ | មានការផ្សព្វផ្សាយតាមអាជ្ញាធរដែនដី សហគមន៍ |
| ពិន្ទុ ១ | មានការផ្សព្វផ្សាយតាមខិតប័ណ្ណ ឬប័ណ្ណប្រកាស |
| ពិន្ទុ ១ | មានការផ្សព្វផ្សាយនៅនឹងកន្លែង |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យនេះត្រូវបានបែងចែកជាលក្ខណៈវិនិច្ឆ័យលម្អិតចំនួន៥ ហើយលក្ខណៈវិនិច្ឆ័យលម្អិតនីមួយៗត្រូវបានផ្តល់ពិន្ទុ១។ ពិន្ទុសរុបនៅលក្ខណៈវិនិច្ឆ័យនេះមានចំនួន៥។

➢ ការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក

- ***សេចក្តីពន្យល់៖*** សំដៅដល់ការផ្សព្វផ្សាយព័ត៌មាននានាដែលពាក់ព័ន្ធនឹងមណ្ឌលសុខភាពតាមរយៈប្រព័ន្ធអេឡិចត្រូនិក( ទូរទស្សន៍ វិទ្យុ គេហទំព័រ បណ្តាញទំនាក់ទំនងសង្គម...) និងប្រកបដោយបច្ចុប្បន្នភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)មធ្យោបាយផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក និង២)ព័ត៌មានផ្សព្វផ្សាយប្រកបដោយបច្ចុប្បន្នភាព។ នៅក្នុងការពិនិត្យមើលព័ត៌មានផ្សព្វផ្សាយប្រកបដោយបច្ចុប្បន្នភាពគឺ គណៈកម្មការវាយតម្លៃត្រូវពិនិត្យមើលព័ត៌មានដែលបានផ្សព្វផ្សាយនៅតាមមធ្យោបាយទាំងនោះ ពិសេសបណ្តាញទំនាក់ទំនងសង្គម។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការផ្សព្វផ្សាយតាមវិទ្យុ ឬទូរទស្សន៍ |
| ពិន្ទុ ២ | មានការផ្សព្វផ្សាយតាមគេហទំព័រ និងមានការធ្វើបច្ចុប្បន្នកម្មជាប្រចាំ |
| ពិន្ទុ ២ | មានការផ្សព្វផ្សាយតាមបណ្តាញទំនាក់ទំនងសង្គម និងមានការធ្វើបច្ចុប្បន្នកម្មជាប្រចាំ |
| ពិន្ទុ ០ | មិនមានការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** បណ្តាញទំនាក់ទំនងសង្គមនៅចំណុចនេះផ្តោតសំខាន់ទៅលើFacebook។ លក្ខណៈវិនិច្ឆ័យនេះត្រូវបានបែងចែកជា៣លក្ខណៈវិនិច្ឆ័យលម្អិត ដែលលក្ខណៈវិនិច្ឆ័យលម្អិតទី១ត្រូវបានផ្តល់ពិន្ទុ១ លក្ខណៈវិនិច្ឆ័យលម្អិតទី២ត្រូវបានផ្តល់ពិន្ទុ២ និងលក្ខណៈវិនិច្ឆ័យលម្អិតទី៣ត្រូវបានផ្តល់ពិន្ទុ២។ ពិន្ទុសរុបនៅលក្ខណៈវិនិច្ឆ័យនេះមានចំនួន៥។

## ១.២ ភាពងាយស្រួលក្នុងការទទួលយកសេវា (៣៥ពិន្ទុ)

### ១.២.១ ទីតាំង និងហេដ្ឋារចនាសម្ព័ន្ធ (២០ពិន្ទុ)

➢ ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធនៅមណ្ឌលសុខភាព

- ***សេចក្តីពន្យល់៖*** សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធរបស់មណ្ឌលសុខភាព មានដូចជា អគារ ឬបន្ទប់ ខ្លោងទ្វារ របង និងផ្លូវចេញចូលមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)អគារ ឬបន្ទប់ ២)ខ្លោងទ្វារ ៣)របងព័ទ្ធជុំវិញ និង៤)ផ្លូវចេញចូលមណ្ឌលសុខភាព។

- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ១ | ផ្លូវចេញចូលមណ្ឌលសុខភាពមានលក្ខណៈងាយស្រួលក្នុងការធ្វើដំណើរ |
| ពិន្ទុ ២ | មានអគារ ឬបន្ទប់ស្របទៅតាមចំនួនសេវាដែលមណ្ឌលសុខភាពផ្តល់(យ៉ាងតិច៨បន្ទប់) |
| ពិន្ទុ ២ | មានខ្លោងទ្វារ និងរបងសមស្របព័ទ្ធជុំវិញបរិវេណមណ្ឌលសុខភាព |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យនេះត្រូវបានបែងចែកជា៣លក្ខណៈវិនិច្ឆ័យលម្អិត ដែលលក្ខណៈវិនិច្ឆ័យលម្អិតទី១ត្រូវបានផ្តល់ពិន្ទុ១ លក្ខណៈវិនិច្ឆ័យលម្អិតទី២ត្រូវបានផ្តល់ពិន្ទុ២ និងលក្ខណៈវិនិច្ឆ័យលម្អិតទី៣ត្រូវបានផ្តល់ពិន្ទុ២។ ពិន្ទុសរុបនៅលក្ខណៈវិនិច្ឆ័យនេះមានចំនួន៥។

➢ **ការបិទបង្ហាញប្លង់ និងស្លាកសញ្ញាប្រាប់ពីឈ្មោះផ្នែកផ្តល់សេវានីមួយៗច្បាស់លាស់**

- ***សេចក្តីពន្យល់៖*** សំដៅដល់ការបិទបង្ហាញនូវប្លង់អគារ ស្លាកសញ្ញាប្រាប់ពីឈ្មោះផ្នែកផ្តល់សេវានីមួយៗ និងសញ្ញាចង្អុលបង្ហាញទៅតាមផ្នែកឬកន្លែងនីមួយៗនៅមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ប្លង់អគារ ២)ស្លាកសញ្ញាប្រាប់ពីឈ្មោះផ្នែកផ្តល់សេវានីមួយៗ និង៣)សញ្ញាចង្អុលបង្ហាញទៅតាមផ្នែកឬកន្លែងនីមួយៗ។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ១ | មានប្លង់អគារជាទម្រង់ផ្ទាំងធំងាយស្រួលមើលនៅមុខមណ្ឌលសុខភាព |
| ពិន្ទុ ២ | មានសញ្ញាចង្អុលបង្ហាញទៅតាមផ្នែកឬកន្លែងនីមួយៗ |
| ពិន្ទុ ២ | មានស្លាកសញ្ញាប្រាប់ពីឈ្មោះផ្នែកផ្តល់សេវានីមួយៗ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យនេះត្រូវបានបែងចែកជា៣លក្ខណៈវិនិច្ឆ័យលម្អិត ដែលលក្ខណៈវិនិច្ឆ័យលម្អិតទី១ត្រូវបានផ្តល់ពិន្ទុ១ លក្ខណៈវិនិច្ឆ័យលម្អិតទី២ត្រូវបានផ្តល់ពិន្ទុ២ និងលក្ខណៈវិនិច្ឆ័យលម្អិតទី៣ត្រូវបានផ្តល់ពិន្ទុ២។ ពិន្ទុសរុបនៅលក្ខណៈវិនិច្ឆ័យនេះមានចំនួន៥។

➢ **ចំណតយានជំនិះ**

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរៀបចំឱ្យមានចំណតយានជំនិះ និងការចតមានរបៀបរៀបរយ នៅបរិវេណមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ចំណត ២)ប្រភេទចំណត ៣)គំនូសចំណត និង៤)របៀបរៀបរយ។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានទីកន្លែងសម្រាប់ចតប្រកបដោយផាសុកភាព |
| ពិន្ទុ ១ | មានការបែងចែកប្រភេទចំណត |
| ពិន្ទុ ១ | មានគំនូស និងស្លាកសម្គាល់ចំណត |
| ពិន្ទុ ១ | មានរបៀបរៀបរយ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យនេះត្រូវបានបែងចែកជា៤លក្ខណៈវិនិច្ឆ័យលម្អិត ដែលលក្ខណៈវិនិច្ឆ័យលម្អិតទី១ត្រូវបានផ្តល់ពិន្ទុ២ លក្ខណៈវិនិច្ឆ័យលម្អិតទី២ត្រូវបានផ្តល់ពិន្ទុ១ លក្ខណៈវិនិច្ឆ័យលម្អិតទី៣ត្រូវបានផ្តល់ពិន្ទុ១ និងលក្ខណៈវិនិច្ឆ័យលម្អិតទី៤ត្រូវបានផ្តល់ពិន្ទុ១។ ពិន្ទុសរុបនៅលក្ខណៈវិនិច្ឆ័យនេះមានចំនួន៥។

➢ **កន្លែងរង់ចាំ**

- ***សេចក្តីពន្យល់៖*** សំដៅដល់កន្លែងរង់ចាំរបស់អ្នកជំងឺទាំងនៅផ្នែកជួរមុខ និងកៅអីអង្គុយនៅបន្ទប់ពិគ្រោះជំងឺ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)កន្លែងអង្គុយរង់ចាំ និង២)បរិមាណនិងគុណភាពកៅអី។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានកន្លែងរង់ចាំនៅផ្នែកជួរមុខ |
| ពិន្ទុ ១ | មានកៅអីអង្គុយគ្រប់គ្រាន់នៅកន្លែងរង់ចាំនៅផ្នែកជួរមុខ |
| ពិន្ទុ ១ | កៅអីរង់ចាំនៅផ្នែកជួរមុខទាំងនោះអង្គុយបានដោយសុវត្ថិភាព |
| ពិន្ទុ ១ | មានកៅអីសម្រាប់អ្នកជំងឺអង្គុយប្រកបដោយសុវត្ថិភាពនៅបន្ទប់ពិគ្រោះជំងឺ |
| ពិន្ទុ ១ | មានគ្រែសម្រាប់ពិនិត្យអ្នកជំងឺនៅក្នុងបន្ទប់ពិគ្រោះជំងឺ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យនេះត្រូវបានបែងចែកជា៥លក្ខណៈវិនិច្ឆ័យលម្អិត ដែលលក្ខណៈវិនិច្ឆ័យលម្អិតទី១ត្រូវបានផ្តល់ពិន្ទុ១ លក្ខណៈវិនិច្ឆ័យលម្អិតទី២ត្រូវបានផ្តល់ពិន្ទុ១ លក្ខណៈវិនិច្ឆ័យលម្អិតទី៣ត្រូវបានផ្តល់ពិន្ទុ១ លក្ខណៈវិនិច្ឆ័យលម្អិតទី៤ត្រូវបានផ្តល់ពិន្ទុ១ និងលក្ខណៈវិនិច្ឆ័យលម្អិតទី៥ត្រូវបានផ្តល់ពិន្ទុ១។ ពិន្ទុសរុបនៅលក្ខណៈវិនិច្ឆ័យនេះមានចំនួន៥។

### ១.២.២ បែបបទ និងលក្ខខណ្ឌនៃការទទួលយកសេវា (១៥ពិន្ទុ)

➢ <u>លក្ខខណ្ឌនៃការទទួលសេវា និងទម្រង់បែបបទមានលក្ខណៈងាយស្រួល</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់នីតិវិធី ទម្រង់ពាក្យស្នើសុំ ឯកសារតម្រូវឬឯកសារភ្ជាប់ ដើម្បីទទួលបានសេវាមានលក្ខណៈមិនស្មុគស្មាញ ងាយបំពេញ និងមានចំនួនតិច។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)នីតិវិធី ២)សៀវភៅសុខភាពសម្រាប់អ្នកជំងឺ និង៣)ឯកសារតម្រូវឬឯកសារភ្ជាប់ដែលអ្នកប្រើប្រាស់សេវាត្រូវបំពេញដើម្បីទទួលបានសេវា។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | នីតិវិធីមិនស្មុគស្មាញ |
| ពិន្ទុ ១ | មានសៀវភៅសុខភាពសម្រាប់អ្នកជំងឺ |
| ពិន្ទុ ២ | ឯកសារតម្រូវ ឬឯកសារភ្ជាប់តិច |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យនេះត្រូវបានបែងចែកជា៣លក្ខណៈវិនិច្ឆ័យលម្អិត ដែលលក្ខណៈវិនិច្ឆ័យលម្អិតទី១ត្រូវបានផ្តល់ពិន្ទុ២ លក្ខណៈវិនិច្ឆ័យលម្អិតទី២ត្រូវបានផ្តល់ពិន្ទុ១ និងលក្ខណៈវិនិច្ឆ័យលម្អិតទី៣ត្រូវបានផ្តល់ពិន្ទុ២។ ពិន្ទុសរុបនៅលក្ខណៈវិនិច្ឆ័យនេះមានចំនួន៥។

➢ <u>អ្នកប្រើប្រាស់សេវាអាចចូលយកសេវាដោយគ្មានអន្តរការី</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ដំណើរការនៃការផ្តល់និងទទួលសេវានៅមណ្ឌលសុខភាពមិនមានអន្តរការី (មិនមានគ្រូពេទ្យប្រាប់អ្នកជំងឺឱ្យទៅគ្លីនិកឯកជន មិនមានអ្នកចាំជូនឬដឹកជញ្ជូនទៅគ្លីនិកឯកជន មិនមានអ្នករត់ការដើម្បីទទួលបានកម្រៃសេវាខុសច្បាប់ពីអ្នកប្រើប្រាស់សេវា...)។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផ្លាកព័ត៌មានជូនអ្នកប្រើប្រាស់សេវាមិនឱ្យប្រើប្រាស់អន្តរការី និង២)វត្តមានអន្តរការី។ ក្នុងការពិនិត្យមើលវត្តមានអន្តរការី គណៈកម្មការវាយតម្លៃអាចអង្កេតជាក់ស្តែងនៅមណ្ឌលសុខភាព ជាពិសេសនៅមុខច្រកចូល សួរអ្នកកំដរឬអ្នកជំងឺ និងពិនិត្យរបាយការណ៍របស់ភាគីពាក់ព័ន្ធផ្សេងៗ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មិនមានអន្តរការី និងមានស្លាកព័ត៌មានហាមមិនឱ្យមានអន្តរការី |
| ពិន្ទុ ៤ | មិនមានអន្តរការី ប៉ុន្តែគ្មានស្លាកព័ត៌មានហាមមិនឱ្យមានអន្តរការី |
| ពិន្ទុ ៣ | មានស្លាកព័ត៌មានហាមមិនឱ្យមានអន្តរការី ប៉ុន្តែមានអន្តរការីតិចតួច |
| ពិន្ទុ ២ | មិនមានស្លាកព័ត៌មានហាមមិនឱ្យមានអន្តរការី និងមានអន្តរការីតិចតួច |

| | |
|---|---|
| ពិន្ទុ ១ | មានស្លាកព័ត៌មានហាមមិនឱ្យមានអន្តរការី ប៉ុន្តែមានអន្តរការីច្រើន |
| ពិន្ទុ ០ | មិនមានស្លាកព័ត៌មានហាមមិនឱ្យមានអន្តរការី និងមានអន្តរការីច្រើន |

➢ <u>ការរង់ចាំចុះឈ្មោះរបស់អ្នកជំងឺមានរយៈពេលខ្លី</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់រយៈពេលរង់ចាំរបស់អ្នកជំងឺដើម្បីទទួលបានការចុះឈ្មោះនៅផ្នែកជួរមុខ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ រយៈពេលរង់ចាំចុះឈ្មោះរបស់អ្នកជំងឺ។ ក្នុងការពិនិត្យមើលសូចនាករនេះ គណៈកម្មការវាយតម្លៃត្រូវធ្វើការអង្កេតជាក់ស្តែងទៅលើអ្នកជំងឺដែលមកចុះឈ្មោះ និងអាចជួបសម្ភាសន៍ជាមួយអ្នកជំងឺឬអ្នកកំដរ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | ការរង់ចាំរបស់អ្នកជំងឺមានរយៈពេលយ៉ាងយូរ១០ នាទី |
| ពិន្ទុ ៤ | ការរង់ចាំរបស់អ្នកជំងឺមានរយៈពេល ពី ១១ នាទីទៅ ១៥ នាទី |
| ពិន្ទុ ៣ | ការរង់ចាំរបស់អ្នកជំងឺមានរយៈពេល ពី ១៦ នាទី ទៅ ២០ នាទី |
| ពិន្ទុ ២ | ការរង់ចាំរបស់អ្នកជំងឺមានរយៈពេល ពី ២១ នាទី ទៅ ២៥ នាទី |
| ពិន្ទុ ១ | ការរង់ចាំរបស់អ្នកជំងឺមានរយៈពេល ពី ២៦ នាទី ទៅ ៣០នាទី |
| ពិន្ទុ ០ | ការរង់ចាំរបស់អ្នកជំងឺមានរយៈពេល ពី ៣១ នាទី ឡើង |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** សូមកុំច្រឡំគ្នារវាងលក្ខណៈវិនិច្ឆ័យនេះជាមួយនឹងលក្ខណៈវិនិច្ឆ័យទី៥នៃចំណុច១.១.២ ដែលមានន័យសំដៅដល់ការផ្សព្វផ្សាយរយៈពេលនៃការរង់ចាំចុះឈ្មោះ។ ចំណែកឯលក្ខណៈវិនិច្ឆ័យនេះ សំដៅដល់រយៈពេលដែលអនុវត្តជាក់ស្តែងរបស់មណ្ឌលសុខភាព។ សូមកុំច្រឡំគ្នារវាងខ្លឹមសារនៃឃ្លា "រយៈពេលរង់ចាំចុះឈ្មោះ" និង ឃ្លា "រយៈពេលចុះឈ្មោះ"។

## ១.៣ ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា (២០ពិន្ទុ)

### ១.៣.១ ការទទួលអ្នកប្រើប្រាស់សេវា (១៥ពិន្ទុ)

➢ <u>មានកន្លែងសម្រាប់ផ្តល់ព័ត៌មានពាក់ព័ន្ធនឹងសេវាសាធារណៈរបស់មណ្ឌលសុខភាព និងវត្តមានអ្នកផ្តល់សេវានៅកន្លែងទទួលជំងឺដំបូងជាប្រចាំ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់មណ្ឌលសុខភាពមានកន្លែងឬមន្ត្រីសម្រាប់ផ្តល់ព័ត៌មានពាក់ព័ន្ធនឹងសេវាសាធារណៈរបស់មណ្ឌលសុខភាព និងមានអ្នកផ្តល់សេវានៅកន្លែងទទួលជំងឺដំបូងជាប្រចាំទៅតាមការកំណត់របស់ប្រធានមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)កន្លែង ឬមន្ត្រីសម្រាប់ផ្តល់ព័ត៌មាននិង

ផ្ដល់ការបំភ្លឺផ្សេងៗ និង២)វត្តមានអ្នកផ្ដល់សេវានៅកន្លែងទទួលជំងឺជំបូងៗ ដើម្បីពិនិត្យមើលវត្តមានអ្នកផ្ដល់សេវានៅកន្លែងទទួលជំងឺជំបូង គណៈកម្មការវាយតម្លៃអាចសួរអ្នកជំងឺ និងអង្កេតជាក់ស្ដែងនៅមណ្ឌលសុខភាពដោយធៀបជាមួយម៉ោងពេលដែលកំណត់ដោយមណ្ឌលសុខភាព។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានកន្លែងឬមន្ត្រីសម្រាប់ផ្ដល់ព័ត៌មាននិងផ្ដល់ការបំភ្លឺផ្សេងៗពាក់ព័ន្ធនឹងសេវាសាធារណៈរបស់អង្គភាព |
| ពិន្ទុ ៣ | អ្នកផ្ដល់សេវានៅកន្លែងទទួលជំងឺជំបូងមានវត្តមានជាប្រចាំ *(អ្នកផ្ដល់សេវានៅកន្លែងទទួលជំងឺជំបូងគោរពម៉ោងពេលបំពេញការងារបានល្អ បានពិន្ទុ៣, គោរពម៉ោងពេលបំពេញការងារបានល្អបង្គួរ បានពិន្ទុ២, គោរពម៉ោងពេលបំពេញការងារបានតិចតួចបានពិន្ទុ១)* |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យនេះត្រូវបានបែងចែកជា២លក្ខណៈវិនិច្ឆ័យលម្អិត ដែលលក្ខណៈវិនិច្ឆ័យលម្អិតទី១ត្រូវបានផ្ដល់ពិន្ទុ២ និងលក្ខណៈ វិនិច្ឆ័យលម្អិតទី២ត្រូវបានផ្ដល់ពិន្ទុ៣។ ពិន្ទុសរុបនៅលក្ខណៈវិនិច្ឆ័យនេះមានចំនួន៥។

➢ <u>ភាពរួសរាយរាក់ទាក់ មានសុជីវធម៌ទាំងអាកប្បកិរិយានិងពាក្យសំដីរបស់គ្រូពេទ្យនិងបុគ្គលិកអនាម័យ</u>

- ***សេចក្ដីពន្យល់៖*** សំដៅដល់ឥរិយាបថរួសរាយរាក់ទាក់ សំដីសមរម្យ សុជីវធម៌ល្អ របស់គ្រូពេទ្យនិងបុគ្គលិកអនាម័យនៅមណ្ឌលសុខភាពចំពោះអ្នកប្រើប្រាស់សេវា(អ្នកជំងឺ...)។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ឥរិយាបថរបស់គ្រូពេទ្យនិងបុគ្គលិកអនាម័យ។ ក្នុងការពិនិត្យមើលលក្ខណៈវិនិច្ឆ័យនេះ គណៈកម្មការវាយតម្លៃត្រូវសម្ភាសន៍ជាមួយអ្នកជំងឺ ឬអតីតអ្នកជំងឺ(ជួបផ្ទាល់ឬតាមទូរស័ព្ទ) យ៉ាងតិចឱ្យបាន៥នាក់ និងស្វែងរកព័ត៌មានក្នុងឯកសារ ឬរបាយការណ៍ដែលពាក់ព័ន្ធករណីនេះដើម្បីសិក្សាប្រៀបធៀប។ បន្ទាប់ពីទទួលបានព័ត៌មានគណៈកម្មការវាយតម្លៃត្រូវធ្វើមធ្យមភាគ និងផ្ដល់ពិន្ទុទៅតាមការកំណត់ដូចក្នុងតារាងខាងក្រោម។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | គ្រូពេទ្យនិងបុគ្គលិកអនាម័យមានភាពរួសរាយរាក់ទាក់ សុជីវធម៌ទាំងអាកប្បកិរិយានិងពាក្យសំដីល្អប្រសើរ(ពី៩១ភាគរយ ទៅ១០០ភាគរយ) |
| ពិន្ទុ ៤ | គ្រូពេទ្យនិងបុគ្គលិកអនាម័យមានភាពរួសរាយរាក់ទាក់ សុជីវធម៌ទាំងអាកប្បកិរិយានិងពាក្យសំដីល្អ(ពី៨១ភាគរយ ទៅ៩០ភាគរយ) |
| ពិន្ទុ ៣ | គ្រូពេទ្យនិងបុគ្គលិកអនាម័យមានភាពរួសរាយរាក់ទាក់ សុជីវធម៌ទាំងអាកប្បកិរិយានិងពាក្យសំដីល្អបង្គួរ(ពី៧១ភាគរយ ទៅ៨០ភាគរយ) |
| ពិន្ទុ ២ | គ្រូពេទ្យនិងបុគ្គលិកអនាម័យមានភាពរួសរាយរាក់ទាក់ សុជីវធម៌ទាំងអាកប្បកិរិយានិងពាក្យសំដីមធ្យម(ពី៦១ភាគរយ ទៅ៧០ភាគរយ) |

| | |
|---|---|
| ពិន្ទុ ១ | គ្រូពេទ្យនិងបុគ្គលិកអនាម័យមានភាពរួសរាយរាក់ទាក់ សុជីវធម៌ទាំងអាកប្បកិរិយានិងពាក្យសំដីមិនសូវសមរម្យ(ពី៥១ភាគរយ ទៅ៦០ភាគរយ) |
| ពិន្ទុ ០ | គ្រូពេទ្យនិងបុគ្គលិកអនាម័យមានភាពរួសរាយរាក់ទាក់ សុជីវធម៌ទាំងអាកប្បកិរិយានិងពាក្យសំដីមិនសមរម្យ(ក្រោម៥០ភាគរយ) |

➢ ឯកសណ្ឋាន និងការពាក់ស្លាកឈ្មោះសម្គាល់ខ្លួនជាប្រចាំរបស់មន្ត្រីក្នុងមុខតំណែងនីមួយៗ

- ***សេចក្តីពន្យល់៖*** សំដៅដល់គ្រូពេទ្យនិងបុគ្គលិកដែលបំពេញការងារនៅមណ្ឌលសុខភាពត្រូវពាក់ឯកសណ្ឋាននិងមានស្លាកឈ្មោះសម្គាល់ខ្លួនជាប្រចាំក្នុងពេលបំពេញការងារ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ឯកសណ្ឋាន និង២)ស្លាកឈ្មោះសម្គាល់ខ្លួន។ ក្នុងការពិនិត្យមើលលក្ខណៈវិនិច្ឆ័យនេះ គណៈកម្មការវាយតម្លៃត្រូវធ្វើការអង្កេតជាក់ស្តែងក្នុងទិដ្ឋភាពជារួម និងដោយឡែកនៅតាមតំណែងនីមួយៗ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | គ្រូពេទ្យនិងបុគ្គលិកពាក់ឯកសណ្ឋាន (គ្រូពេទ្យនិងបុគ្គលិកពាក់ឯកសណ្ឋានគ្រប់គ្នា បានពិន្ទុ២, គ្រូពេទ្យនិងបុគ្គលិកពាក់ឯកសណ្ឋានបានមួយចំនួនធំ បានពិន្ទុ១, គ្រូពេទ្យនិងបុគ្គលិកពាក់ឯកសណ្ឋានបានប្រហែល ៥០ភាគរយ បានពិន្ទុ០ |
| ពិន្ទុ ១ | ឯកសណ្ឋានមានអនាម័យ |
| ពិន្ទុ ២ | គ្រូពេទ្យនិងបុគ្គលិកមានស្លាកឈ្មោះសម្គាល់ (គ្រូពេទ្យនិងបុគ្គលិកមានស្លាកឈ្មោះសម្គាល់គ្រប់គ្នា បានពិន្ទុ២, គ្រូពេទ្យនិងបុគ្គលិកមានស្លាកឈ្មោះសម្គាល់បានមួយចំនួនធំ បានពិន្ទុ១, គ្រូពេទ្យនិងបុគ្គលិកមានស្លាកឈ្មោះសម្គាល់មានចំនួនប្រហែល ៥០ភាគរយ បានពិន្ទុ០) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** គ្រប់គ្រូពេទ្យនិងបុគ្គលិកដែលកំពុងបម្រើការនៅក្នុងអង្គភាពត្រូវមានស្លាកឈ្មោះគ្រប់គ្នា។ ស្លាកឈ្មោះអាចប៉ាក់នៅនឹងអាវ ឬអាចធ្វើជាប័ណ្ណពាក់។

### ១.៣.២ យន្តការសម្របសម្រួល (៥ពិន្ទុ)

➢ អ្នកផ្តល់សេវាមានការយកចិត្តទុកដាក់ចំពោះអ្នកប្រើប្រាស់សេវា

- ***សេចក្តីពន្យល់៖*** សំដៅដល់ការយកចិត្តទុកដាក់របស់អ្នកផ្តល់សេវា(គ្រូពេទ្យ...) ចំពោះអ្នកប្រើប្រាស់សេវា(អ្នកជំងឺ...) ជាពិសេសព្រះសង្ឃ ជនពិការ ជនចាស់ជរា អនក្ខរជន កុមារ ស្ត្រីមានកូនតូច ឬមានផ្ទៃពោះតាមរយៈការផ្តល់ព័ត៌មាននិងសម្រួលការលំបាករបស់អ្នកប្រើប្រាស់សេវាតាមទិដ្ឋភាពជាក់ស្តែង។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ជម្រាលជនពិការ ២)រទេះអ្នកជំងឺ ៣)មន្ត្រីសម្របសម្រួល និង៤)ការអនុវត្តនៃការយកចិត្តទុកដាក់។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានជម្រាលសម្រាប់ជនពិការ |
| ពិន្ទុ ១ | មានរទេះអ្នកជំងឺ |
| ពិន្ទុ ១ | មានមន្ត្រីសម្របសម្រួល |
| ពិន្ទុ ២ | ការយកចិត្តទុកដាក់របស់មន្ត្រីសម្របសម្រួលចំពោះអ្នកប្រើប្រាស់សេវា ពិសេស ព្រះសង្ឃ ជនពិការ ជនចាស់ជរា អនក្ខរជន កុមារ ស្ត្រីមានកូនតូច ឬមានផ្ទៃពោះ ក្នុងការបំពេញបែបបទ ការទទួលបានព័ត៌មាន និងក្នុងការងារផ្សេងៗទៀត។ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យនេះត្រូវបានបែងចែកជា៤លក្ខណៈវិនិច្ឆ័យលម្អិត ដែលលក្ខណៈវិនិច្ឆ័យលម្អិតទី១ត្រូវបានផ្តល់ពិន្ទុ១ លក្ខណៈវិនិច្ឆ័យលម្អិតទី២ត្រូវបានផ្តល់ពិន្ទុ១ លក្ខណៈវិនិច្ឆ័យលម្អិតទី៣ត្រូវបានផ្តល់ពិន្ទុ១ និងលក្ខណៈវិនិច្ឆ័យលម្អិតទី៤ត្រូវបានផ្តល់ពិន្ទុ២។ ពិន្ទុសរុបនៅលក្ខណៈវិនិច្ឆ័យនេះមានចំនួន៥។

## ១.៤ ការផ្តល់សេវាតាមគោលការណ៍កំណត់ និងអភិបាលកិច្ចល្អ (២៥ពិន្ទុ)

### ១.៤.១ ផ្តល់សេវាតាមគោលការណ៍កំណត់ (១០ពិន្ទុ)

➢ ការផ្តល់សេវាស្របតាមការកំណត់របស់បទដ្ឋានគតិយុត្តជាធរមាន

- ***សេចក្តីពន្យល់៖*** សំដៅដល់ការផ្តល់សេវារបស់មណ្ឌលសុខភាពអនុវត្តតាមបទដ្ឋានគតិយុត្ត ដូចជាតម្លៃសេវា ឯកសារតម្រូវ រំហូរឬចរន្តនៃការផ្តល់សេវា...។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការអនុវត្តតាមតារាងតម្លៃសេវា(មិនមានការទារយកថ្លៃសេវាបន្ថែមក្រៅផ្លូវការ) ២)ការអនុវត្តការងារទៅតាមបទបញ្ជាផ្ទៃក្នុង និង៣)ការអនុវត្តការផ្តល់សេវាទៅតាមរំហូរឬចរន្តនៃការផ្តល់សេវា។ ក្នុងការពិនិត្យទៅលើការអនុវត្តតាមតារាងតម្លៃសេវា គណៈកម្មការវាយតម្លៃត្រូវជួបសម្ភាសន៍ជាមួយអ្នកជំងឺ អតីតអ្នកជំងឺ អ្នកកំដរ(ជួបផ្ទាល់ តាមទូរស័ព្ទ) និងធ្វើការប្រៀបធៀបជាមួយរបាយការណ៍ស្តីពីបញ្ហានេះរបស់ភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ៣ | យកថ្លៃសេវាទៅតាមតារាងតម្លៃដែលបានកំណត់ *(យកថ្លៃសេវាទៅតាមតារាងតម្លៃដែលបានកំណត់ឬមិនមានការទារយកថ្លៃសេវាបន្ថែមក្រៅផ្លូវការ បានពិន្ទុ៣, មានការយកថ្លៃសេវាលើសពីតារាងតម្លៃដែលបានកំណត់ ឬមានការទារយកថ្លៃសេវាបន្ថែមក្រៅផ្លូវការទោះបីតិចតួចក្តីឬច្រើនក្តី បានពិន្ទុ០)* |

| | |
|---|---|
| ពិន្ទុ ១ | អនុវត្តការងារទៅតាមបទបញ្ជាផ្ទៃក្នុងអង្គភាព |
| ពិន្ទុ ១ | អនុវត្តការផ្តល់សេវាទៅតាមវេហូរប្រចរន្តនៃការផ្តល់សេវា |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** នៅលក្ខណៈវិនិច្ឆ័យនេះត្រូវបានបែងចែកជា៣លក្ខណៈវិនិច្ឆ័យលម្អិត ដែលលក្ខណៈវិនិច្ឆ័យលម្អិតទី១ត្រូវបានផ្តល់ពិន្ទុ៣ លក្ខណៈវិនិច្ឆ័យលម្អិតទី២ត្រូវបានផ្តល់ពិន្ទុ១ និងលក្ខណៈវិនិច្ឆ័យលម្អិតទី៣ត្រូវបានផ្តល់ពិន្ទុ១។ ពិន្ទុសរុបនៅលក្ខណៈវិនិច្ឆ័យនេះមានចំនួន៥។

➢ <u>អង្គភាពផ្តល់សេវាទទួលបានវិញ្ញាបនបត្រទទួលស្គាល់គុណភាពសេវាសាធារណៈ(ជាតិ ឬដៃគូអភិវឌ្ឍ)</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់វិញ្ញាបនបត្រទទួលស្គាល់គុណភាពសេវាសាធារណៈទាំងឡាយណាដែលមណ្ឌលសុខភាពធ្លាប់ទទួលបានទាំងក្នុងក្របខណ្ឌជាតិ ទាំងក្នុងក្របខណ្ឌដៃគូអភិវឌ្ឍ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ វិញ្ញាបនបត្រទទួលស្គាល់គុណភាពសេវាសាធារណៈ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | អង្គភាពផ្តល់សេវាទទួលបានវិញ្ញាបនបត្រទទួលស្គាល់គុណភាពសេវាសាធារណៈពីក្រសួងសុខាភិបាល |
| ពិន្ទុ ១ | អង្គភាពផ្តល់សេវាទទួលបានវិញ្ញាបនបត្រទទួលស្គាល់គុណភាពសេវាសាធារណៈពីរាជធានី ខេត្ត ឬមន្ទីរសុខាភិបាល |
| ពិន្ទុ ១ | អង្គភាពផ្តល់សេវាទទួលបានវិញ្ញាបនបត្រទទួលស្គាល់គុណភាពសេវាសាធារណៈពីការិយាល័យស្រុកប្រតិបត្តិ |
| ពិន្ទុ ១ | អង្គភាពផ្តល់សេវាទទួលបានវិញ្ញាបនបត្រទទួលស្គាល់គុណភាពសេវាសាធារណៈពីដៃគូអភិវឌ្ឍ/អង្គភាពឬស្ថាប័នផ្សេង |
| ពិន្ទុ ០ | អង្គភាពផ្តល់សេវាមិនទទួលបានវិញ្ញាបនបត្រទទួលស្គាល់គុណភាពសេវាសាធារណៈអ្វីទាំងអស់ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យនេះត្រូវបានបែងចែកជា៤លក្ខណៈវិនិច្ឆ័យលម្អិត ដែលលក្ខណៈវិនិច្ឆ័យលម្អិតទី១ត្រូវបានផ្តល់ពិន្ទុ២ លក្ខណៈវិនិច្ឆ័យលម្អិតទី២ត្រូវបានផ្តល់ពិន្ទុ១ លក្ខណៈវិនិច្ឆ័យលម្អិតទី៣ត្រូវបានផ្តល់ពិន្ទុ១ និងលក្ខណៈវិនិច្ឆ័យលម្អិតទី៤ត្រូវបានផ្តល់ពិន្ទុ១។ ពិន្ទុសរុបនៅលក្ខណៈវិនិច្ឆ័យនេះមានចំនួន៥។

### ១.៤.២ ការផ្តល់សេវាប្រកបដោយសមធម៌ និងការទទួលខុសត្រូវ (១៥ពិន្ទុ)

➢ ការត្រួតពិនិត្យ កែលម្អ និងធ្វើបច្ចុប្បន្នកម្ម លើដំណើរការ និងលក្ខខណ្ឌនៃការផ្តល់សេវារបស់មណ្ឌលសុខភាព

- ***សេចក្តីពន្យល់៖*** សំដៅដល់ដំណើរការនៃការត្រួតពិនិត្យនិងកែលម្អគុណភាពសេវា និងការធ្វើបច្ចុប្បន្នកម្មទៅលើចរន្តនៃការផ្តល់សេវា ឯកសារតម្រូវដើម្បីទទួលបានសេវា ប្រភេទសេវា និងតម្លៃសេវារបស់មណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ក្រុមការងារទទួលបន្ទុកត្រួតពិនិត្យ និងកែលម្អគុណភាពសេវា ២)របាយការណ៍លើដំណើរការកែលម្អការផ្តល់សេវា ៣)ប្រភេទសេវានិងតម្លៃសេវាដែលមានបច្ចុប្បន្នភាព និង៤)ចរន្តនៃការផ្តល់សេវានិងឯកសារភ្ជាប់ដែលមានបច្ចុប្បន្នភាព។ ក្នុងការពិនិត្យទៅលើបណ្តាចំណុចខាងលើ គណៈកម្មការវាយតម្លៃត្រូវស្វែងរកឯកសារ ឬបទដ្ឋានគតិយុត្តមកផ្ទៀងផ្ទាត់។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានក្រុមការងារទទួលបន្ទុកត្រួតពិនិត្យ និងកែលម្អគុណភាពសេវា |
| ពិន្ទុ ១ | មានរបាយការណ៍លើដំណើរការកែលម្អការផ្តល់សេវា |
| ពិន្ទុ ២ | ប្រភេទសេវានិងតម្លៃសេវាដែលកំពុងអនុវត្តត្រូវបានអនុម័តយ៉ាងយូរ៥ឆ្នាំមុន |
| ពិន្ទុ ១ | ចរន្តនៃការផ្តល់សេវានិងឯកសារភ្ជាប់ដើម្បីទទួលបានសេវាដែលកំពុងអនុវត្តត្រូវបានអនុម័តយ៉ាងយូរ៥ឆ្នាំមុន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យនេះត្រូវបានបែងចែកជា៤លក្ខណៈវិនិច្ឆ័យលម្អិត ដែលលក្ខណៈវិនិច្ឆ័យលម្អិតទី១ត្រូវបានផ្តល់ពិន្ទុ១ លក្ខណៈវិនិច្ឆ័យលម្អិតទី២ត្រូវបានផ្តល់ពិន្ទុ១ លក្ខណៈវិនិច្ឆ័យលម្អិតទី៣ត្រូវបានផ្តល់ពិន្ទុ២ និងលក្ខណៈវិនិច្ឆ័យលម្អិតទី៤ត្រូវបានផ្តល់ពិន្ទុ១។ ពិន្ទុសរុបនៅលក្ខណៈវិនិច្ឆ័យនេះមានចំនួន៥។

➢ ការផ្តល់សេវាប្រកបដោយសមធម៌

- ***សេចក្តីពន្យល់៖*** សំដៅដល់ការផ្តល់សេវាផ្អែកលើគោលការណ៍អ្នកមកមុនទទួលបានការផ្តល់សេវាមុន(លើកលែងចាស់ជរា ព្រះសង្ឃ ស្ត្រីមានផ្ទៃពោះ ជនពិការ) និងមិនមានការរើសអើង ឋានៈតួនាទី ភេទ សញ្ជាតិ ពូជសាសន៍ សាសនា ឬនិន្នាការនយោបាយឡើយ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការផ្តល់សេវាតាមលេខរៀង និង២)អ្នកជំងឺទទួលបានការព្យាបាលនិងថែទាំដូចគ្នាពីគ្រូពេទ្យ។

- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ២ | ការផ្តល់សេវាតាមលេខរៀង *(មានការចែកលេខ បានពិន្ទុ២, មានការផ្តល់តាមការហៅរបស់អ្នកផ្តល់សេវា បានពិន្ទុ១)* |
| ពិន្ទុ ២ | អ្នកជំងឺទទួលបានការព្យាបាលនិងថៃទាំដូចគ្នា(មិនរើសអើង)ពីគ្រូពេទ្យ |
| ពិន្ទុ ១ | អនុវត្តការផ្តល់សិទ្ធិអាទិភាពចំពោះចាស់ជរា ព្រះសង្ឃ ស្ត្រីមានផ្ទៃពោះ ជនពិការ ស្ត្រីមានកូនតូច |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- *ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖* លក្ខណៈវិនិច្ឆ័យនេះត្រូវបានបែងចែកជា៣លក្ខណៈវិនិច្ឆ័យលម្អិត ដែលលក្ខណៈវិនិច្ឆ័យលម្អិតទី១ត្រូវបានផ្តល់ពិន្ទុ២ លក្ខណៈវិនិច្ឆ័យលម្អិតទី២ត្រូវបានផ្តល់ពិន្ទុ២ និងលក្ខណៈវិនិច្ឆ័យលម្អិតទី៣ត្រូវបានផ្តល់ពិន្ទុ១។ ពិន្ទុសរុបនៅលក្ខណៈវិនិច្ឆ័យនេះមានចំនួន៥។

➢ ការលើកលែងបង់ថ្លៃសេវាដល់ជនងាយរងគ្រោះ

- *សេចក្តីពន្យល់៖* សំដៅដល់ការលើកលែងបង់ថ្លៃសេវាដល់ជនទាំងឡាយណាដែលមិនមានលទ្ធភាពបង់ថ្លៃសេវាដែលផ្តល់ដោយមណ្ឌលសុខភាព។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ១)ក្រុមការងារទទួលបន្ទុក ២)គោលការណ៍ណែនាំអនុវត្តន៍ និង៣)ការអនុវត្តតាមគោលការណ៍ណែនាំ។ ដើម្បីពិនិត្យមើលចំណុចក្រុមការងារទទួលបន្ទុក និងគោលការណ៍ណែនាំអនុវត្តន៍ គណៈកម្មការវាយតម្លៃត្រូវពិនិត្យបទដ្ឋានគតិយុត្តពាក់ព័ន្ធលើការលើកលែងបង់ថ្លៃសេវាដល់ជនងាយរងគ្រោះ។ ចំណែកឯការអនុវត្តតាមគោលការណ៍ណែនាំគឺត្រូវធ្វើការអង្កេត ជួបសម្ភាសន៍ និងស្វែងរកព័ត៌មានតាមរយៈរបាយការណ៍។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ១ | មានក្រុមការងារ ឬមន្ត្រីទទួលបន្ទុក |
| ពិន្ទុ ២ | ក្រុមការងារ ឬមន្ត្រីទទួលបន្ទុកមានវត្តមានជាប្រចាំ |
| ពិន្ទុ ១ | មានគោលការណ៍ណែនាំអនុវត្តន៍ |
| ពិន្ទុ ១ | ការអនុវត្តទៅតាមគោលការណ៍ណែនាំ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- *ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖* លក្ខណៈវិនិច្ឆ័យនេះត្រូវបានបែងចែកជា៤លក្ខណៈវិនិច្ឆ័យលម្អិត ដែលលក្ខណៈវិនិច្ឆ័យលម្អិតទី១ត្រូវបានផ្តល់ពិន្ទុ១ លក្ខណៈវិនិច្ឆ័យលម្អិតទី២ត្រូវបានផ្តល់ពិន្ទុ២ លក្ខណៈវិនិច្ឆ័យលម្អិតទី៣ត្រូវបានផ្តល់ពិន្ទុ១ និងលក្ខណៈវិនិច្ឆ័យលម្អិតទី៤ត្រូវបានផ្តល់ពិន្ទុ១។ ពិន្ទុសរុបនៅលក្ខណៈវិនិច្ឆ័យនេះមានចំនួន៥។

# ផ្នែកទី២៖ ស្តង់ដាឬនិយាមនៃការផ្តល់សេវាសាធារណៈ ក្នុងវិស័យសុខាភិបាលសម្រាប់មណ្ឌលសុខភាព

## ២. ស្តង់ដាឬនិយាមនៃការផ្តល់សេវាសាធារណៈក្នុងវិស័យសុខាភិបាលសម្រាប់មណ្ឌលសុខភាព (២៤០ពិន្ទុ)

មណ្ឌលសុខភាពមានតួនាទី ផ្តល់សេវាសុខភាពជាមូលដ្ឋានដល់ប្រជាជន ដូចដែលបានចែងនៅក្នុង «សំណុំសកម្មភាពអប្បបរមា»។ មណ្ឌលសុខភាពត្រូវមានលក្ខណៈសម្បត្តិដូចតទៅ (១)ដំណើរការមុខងារ (ផ្តល់សេវាសុខភាព និងគ្រប់គ្រង) មានប្រសិទ្ធភាព និងនិរន្តភាព (២)ផ្តល់សេវាលើកកម្ពស់និងអប់រំសុខភាព បង្ការជំងឺនិងព្យាបាលជាមូលដ្ឋានដែលមានគុណភាពខ្ពស់ តាមបែបសមាហរណកម្ម (៣)ធានាថាប្រជាជនទទួលបានសេវាសុខភាព សមស្របតាមលក្ខខ័ណ្ឌហិរញ្ញវត្ថុ ភូមិសាស្ត្រ វប្បធម៌ និងទំនៀមទំលាប់ប្រពៃណី (៤)រក្សាទំនាក់ទំនងជិតស្និទ្ធជាមួយប្រជាជនក្នុងតំបន់ទទួលខុសត្រូវរបស់មណ្ឌលសុខភាព និង(៥)លើកទឹកចិត្តប្រជាជននិងសហគមន៍ឲ្យចូលរួមក្នុងសកម្មភាពសុខភាព។ ការពង្រឹងការផ្តល់សេវាសុខាភិបាល ត្រូវផ្តោតទៅលើតម្រូវការរបស់ប្រជាជន និងស្របទៅតាមស្តង់ដានៃគុណភាព។

គុណភាពសេវាសុខាភិបាលគឺជាកត្តាកំណត់លទ្ធផលសុខភាពដ៏សំខាន់។ ដូច្នេះការវិនិយោគលើការកែលម្អគុណភាពសេវាគឺជាអាទិភាពសំខាន់សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងសុខាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ និងវិស័យឯកជន។ ស្តង់ដាឬនិយាមនៃការផ្តល់សេវាសាធារណៈក្នុងវិស័យសុខាភិបាលសម្រាប់មណ្ឌលសុខភាព មានសារៈប្រយោជន៍សំខាន់ ក្នុងការរួមចំណែកកែលម្អគុណភាពសេវាសុខាភិបាលនៅថ្នាក់មណ្ឌលសុខភាព។ លក្ខណៈវិនិច្ឆ័យគោលនេះ មានពិន្ទុសរុបចំនួន២៤០ ដែលមានលក្ខណៈវិនិច្ឆ័យរងចំនួន៤ គឺ៖

**១. ការដឹកនាំ និងការគ្រប់គ្រងមណ្ឌលសុខភាព** (៥៥ពិន្ទុ)

**២. ការបង្ការ ការត្រួតពិនិត្យការចម្លងរោគ និងអនាម័យ** (៦០ពិន្ទុ)

**៣. ការលើកកម្ពស់គុណភាពសេវាក្នុងមណ្ឌលសុខភាព** (៥០ពិន្ទុ)

**៤. លទ្ធផលនៃការអនុវត្តការលើកកម្ពស់គុណភាពសេវាក្នុងមណ្ឌលសុខភាព** (៧៥ពិន្ទុ)

## ២.១ ការដឹកនាំ និងការគ្រប់គ្រងមណ្ឌលសុខភាព (៥៥ពិន្ទុ)

### ២.១.១ ការលើកកម្ពស់គុណភាពសេវារបស់មណ្ឌលសុខភាព (១០ពិន្ទុ)

➢ ផែនការលើកកម្ពស់គុណភាពសេវាប្រចាំត្រីមាស

- ***សេចក្តីពន្យល់៖*** សំដៅដល់ផែនការលើកកម្ពស់គុណភាពប្រចាំត្រីមាសរបស់មណ្ឌលសុខភាពដែលបានធ្វើបច្ចុប្បន្នកម្មអនុសាសន៍ ឬការវាយតម្លៃប្រចាំត្រីមាស។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការលើកកម្ពស់គុណភាពប្រចាំត្រីមាស(៤ត្រីមាស) និង២)ផែនការត្រូវធ្វើបច្ចុប្បន្នកម្មផ្អែកតាមលទ្ធផលនៃការវាយតម្លៃប្រចាំត្រីមាស។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានផែនការលើកកម្ពស់គុណភាពសេវាប្រចាំត្រីមាស (៤ត្រីមាស) |
| ពិន្ទុ ៣ | ខ្លឹមសារផែនការលើកកម្ពស់គុណភាព(ទម្រង់ បច្ចុប្បន្នភាព និងហត្ថលេខាប្រធានមណ្ឌលសុខភាព) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ត្រូវពិនិត្យផ្ទៀងផ្ទាត់សកម្មភាពក្នុងផែនការលើកកម្ពស់គុណភាពសេវា ជាមួយរបាយការណ៍លទ្ធផលវាយតម្លៃក្នុងត្រីមាសមុន។

➢ ការអនុវត្តវិធានការកែលម្អការផ្តល់សេវាទៅតាមផែនការលើកកម្ពស់គុណភាពសេវា

- ***សេចក្តីពន្យល់៖*** សំដៅដល់ការអនុវត្តផែនការលើកកម្ពស់គុណភាពសេវារបស់មណ្ឌលសុខភាពប្រចាំត្រីមាស។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តផែនការលើកកម្ពស់គុណភាពសេវា និង២)លទ្ធផលនៃការអនុវត្តសកម្មភាព(សកម្មភាពដែលបានអនុវត្តធៀបជាមួយចំនួនសកម្មភាពសរុបនៅក្នុងផែនការប្រចាំត្រីមាស)។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | របាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តផែនការលើកកម្ពស់គុណភាពសេវា(៤ត្រីមាស) |
| ពិន្ទុ ៣ | លទ្ធផលនៃការអនុវត្តសកម្មភាព៖ ករណីអនុវត្តសកម្មភាពបានចាប់ពី៨០ភាគរយឡើងត្រូវផ្តល់ពិន្ទុ៣, ករណីអនុវត្តសកម្មភាពបានចាប់ពី៦៥ភាគរយ ដល់៧៩ភាគរយត្រូវផ្តល់ពិន្ទុ២, ករណីអនុវត្តសកម្មភាពបានចាប់ពី៥០ភាគរយ ដល់៦៤ភាគរយត្រូវផ្តល់ពិន្ទុ១, ករណីអនុវត្តសកម្មភាពបានក្រោម៥០ភាគរយ ត្រូវផ្តល់ពិន្ទុ០ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យលម្អិតនេះមានសង្គតិភាពជាមួយនឹងលក្ខណៈវិនិច្ឆ័យលម្អិតខាងលើ ស្តីពី "**មានផែនការលើកកម្ពស់គុណ**

**ភាពប្រចាំត្រីមាស"** នៅក្នុងចំណុច២.១.១។ ករណីមណ្ឌលសុខភាពមានផែនការលើកកម្ពស់គុណភាពប្រចាំត្រីមាសចំនួន៣ ដូចនេះរបាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តផែនការលើកកម្ពស់គុណភាពសេវាត្រូវមានចំនួន៣ដូចគ្នា។ ក្នុងនោះ ការគណនាពិន្ទុលទ្ធផលនៃការអនុវត្តសកម្មភាព ត្រូវធ្វើមធ្យមភាគ៤ត្រីមាសតាមរូបមន្តៈ យកភាគរយនៃត្រីមាសទី១ បូកភាគរយនៃត្រីមាសទី២ បូកភាគរយនៃត្រីមាសទី៣ រួចចែកនឹង៤។

### ២.១.២ ការគ្រប់គ្រងប្រព័ន្ធព័ត៌មានសុខាភិបាល (២៥ពិន្ទុ)

➢ ការបញ្ចូលទិន្នន័យពេញលេញ និងទាន់ពេលទៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាលដោយមណ្ឌលសុខភាព

- ***សេចក្តីពន្យល់៖*** សំដៅដល់ការបញ្ចូលទិន្នន័យស្តីពីការគ្របដណ្តប់នៃសេវាសុខាភិបាលទៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាសុខាភិបាល(HMIS) ប្រកបដោយភាពពេញលេញ និងទាន់ពេលដោយមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ចំនួនខែនៃការបញ្ចូលទិន្នន័យក្នុង១ឆ្នាំ ២)ភាពទាន់ពេលនៃការបញ្ចូលទិន្នន័យ និង៣)ភាពត្រឹមត្រូវនៃការបញ្ចូលទិន្នន័យ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | ចំនួនខែនៃការបញ្ចូលទិន្នន័យក្នុង១ឆ្នាំ៖ ករណីបញ្ចូលទិន្នន័យបាន១២ខែក្នុង១ឆ្នាំ ត្រូវផ្តល់ពិន្ទុ២, ករណីបញ្ចូលទិន្នន័យចាប់ពី ១១ខែចុះ ក្នុង១ឆ្នាំ ត្រូវផ្តល់ពិន្ទុ០ |
| ពិន្ទុ ២ | ភាពទាន់ពេលនៃការបញ្ចូលទិន្នន័យ (បញ្ចូលទាន់ពេលចាប់ពីថ្ងៃទី១ដល់១៥នៃខែបន្ទាប់)៖ ករណីបញ្ចូលទិន្នន័យបានទាន់ពេលបាន១២ខែក្នុង១ឆ្នាំ ត្រូវផ្តល់ពិន្ទុ២, ករណីបញ្ចូលទិន្នន័យមិនបានទាន់ពេល១ខែ ត្រូវដកកន្លះពិន្ទុ |
| ពិន្ទុ ១ | ភាពត្រឹមត្រូវនៃការបញ្ចូលទិន្នន័យ (ផ្ទៀងផ្ទាត់ទិន្នន័យរវាងបញ្ជីកត់ត្រាជាមួយទិន្នន័យក្នុងប្រព័ន្ធ) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ការធ្វើបច្ចុប្បន្នកម្មទៀងទាត់នៃតារាងតាមដានសុខាភិបាល (Tableau de board)

- ***សេចក្តីពន្យល់៖*** សំដៅដល់ការបំពេញទិន្នន័យនៅក្នុងតារាងតាមដានសុខាភិបាលលើសូចនាករស្នូល (Tableau de board)របស់មណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ចំនួនខែនៃការបំពេញទិន្នន័យ ២)ការបញ្ចូលទិន្នន័យគ្រប់សូចនាករ(ទិន្នន័យដែលមានប្រចាំខែ) និង៣)ភាពត្រឹមត្រូវនៃទិន្នន័យគ្រប់សូចនាករធៀបទៅនឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាសុខាភិបាល ឬតាមរបាយការណ៍ HC1។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | ចំនួនខែនៃការបំពេញទិន្នន័យគ្រប់ខែដល់ខែចុងក្រោយ |

| | |
|---|---|
| ពិន្ទុ ២ | ការបញ្ចូលទិន្នន័យគ្រប់សូចនាករ( ទិន្នន័យដែលមានប្រចាំខែ ) |
| ពិន្ទុ ១ | ភាពត្រឹមត្រូវនៃទិន្នន័យគ្រប់សូចនាករធៀបទៅនឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាសុខាភិបាល ឬតាមរបាយការណ៍ HC1 |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ទិន្នន័យដែលកត់ត្រាលើតារាងតាមដានសុខាភិបាល ជាទិន្នន័យនៃខែក្នុងឆ្នាំ កំពុងពិនិត្យវាយតម្លៃ។ ការវាយតម្លៃក្នុងលក្ខណៈវិនិច្ឆ័យលម្អិតនេះគឺមិនពិនិត្យទៅលើផ្នែកហិរញ្ញវត្ថុទេ។

➢ <u>ការពិនិត្យលទ្ធផលប្រចាំត្រីមាសរបស់មណ្ឌលសុខភាព</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការត្រួតពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តផែនការប្រចាំត្រីមាសរបស់មណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍សមិទ្ធផលប្រចាំត្រីមាសទាំង៤ ដែលមានចុះហត្ថលេខាដោយប្រធាន ២)បញ្ជីឈ្មោះអ្នកចូលរួមនៃកិច្ចប្រជុំពិនិត្យលទ្ធផលប្រចាំត្រីមាស និង៣)របៀបវារៈនៃកិច្ចប្រជុំ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ៣ | របាយការណ៍សមិទ្ធផលប្រចាំត្រីមាសទាំង៤ ដែលមានចុះហត្ថលេខាដោយប្រធាន |
| ពិន្ទុ ១ | បញ្ជីឈ្មោះអ្នកចូលរួមនៃកិច្ចប្រជុំពិនិត្យលទ្ធផលប្រចាំត្រីមាស |
| ពិន្ទុ ១ | របៀបវារៈនៃកិច្ចប្រជុំ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** អាចចាត់ទុកថាបានពិនិត្យលទ្ធផលប្រចាំត្រីមាស លុះត្រាតែបានរៀបចំកិច្ចប្រជុំ ដោយមាន (១)ថ្ងៃខែឆ្នាំប្រជុំ (២)របៀបវារៈនៃកិច្ចប្រជុំ (៣)បញ្ជីឈ្មោះអ្នកចូលរួមមានចុះហត្ថលេខា និង(៤)របាយការណ៍វឌ្ឍនភាព។

➢ <u>ការវិភាគលទ្ធផលប្រចាំត្រីមាសពីចំណុចខ្លាំង និងខ្សោយ (SWOT ឬវិធីសាស្ត្រផ្សេងទៀត)</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការវិភាគលើសូចនាករសំខាន់ៗ ដើម្បីកំណត់ឱ្យបាននូវចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តន៍ភាព និងភាពគំរាមកំហែង ដោយប្រើប្រាស់តាមវិធីសាស្ត្រវិភាគ SWOT។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តន៍ភាព និងភាពគំរាមកំហែង(វិភាគ SWOT)។ ដើម្បីពិនិត្យមើលការវិភាគនេះ គណៈកម្មការវាយតម្លៃត្រូវស្វែងរកក្នុងរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទាំង៤ត្រីមាស ដែលមានចុះហត្ថលេខាដោយប្រធានអង្គភាព។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការវិភាគចំណុចខ្លាំង |
| ពិន្ទុ ២ | មានការវិភាគចំណុចខ្សោយ |
| ពិន្ទុ ១ | មានការវិភាគកាលានុវត្តន៍ភាព( ឱកាស ) |
| ពិន្ទុ ១ | មានការវិភាគភាពគំរាមកំហែង |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** របាយការណ៍ពិនិត្យលទ្ធផលប្រចាំត្រីមាស ជារបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការប្រចាំត្រីមាសរបស់មណ្ឌលសុខភាព (មានបញ្ចូលវឌ្ឍនភាពនៃការអនុវត្តផែនការលើកកម្ពស់គុណភាពសេវា)។

➢ <u>ការរកដំណោះស្រាយសម្រាប់អនុវត្តនៅត្រីមាសបន្ត</u>

- ***សេចក្ដីពន្យល់៖*** សំដៅដល់ការកំណត់នូវដំណោះស្រាយ ដើម្បីឆ្លើយតបទៅនឹងចំណុចខ្សោយ និងភាពគំរាមកំហែងសម្រាប់រៀបចំផែនការសកម្មភាពត្រីមាសបន្ទាប់។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ដំណោះស្រាយដែលមាននៅក្នុងរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទាំង៤ត្រីមាស។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានការកំណត់នូវដំណោះស្រាយ ឆ្លើយតបទៅនឹងចំណុចខ្សោយ និងភាពគំរាមកំហែងក្នុងរបាយការណ៍វឌ្ឍនភាព៤ត្រីមាស |
| ពិន្ទុ ៤ | មានការកំណត់នូវដំណោះស្រាយ ឆ្លើយតបទៅនឹងចំណុចខ្សោយ និងភាពគំរាមកំហែងក្នុងរបាយការណ៍វឌ្ឍនភាព៣ត្រីមាស |
| ពិន្ទុ ៣ | មានការកំណត់នូវដំណោះស្រាយ ឆ្លើយតបទៅនឹងចំណុចខ្សោយ និងភាពគំរាមកំហែងក្នុងរបាយការណ៍វឌ្ឍនភាព២ត្រីមាស |
| ពិន្ទុ ២ | មានការកំណត់នូវដំណោះស្រាយ ឆ្លើយតបទៅនឹងចំណុចខ្សោយ និងភាពគំរាមកំហែងក្នុងរបាយការណ៍វឌ្ឍនភាព១ត្រីមាស |
| ពិន្ទុ ០ | គ្មានការកំណត់នូវដំណោះស្រាយ ឆ្លើយតបទៅនឹងចំណុចខ្សោយ និងភាពគំរាមកំហែងក្នុងរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** មានផែនការសកម្មភាពសម្រាប់អនុវត្តត្រីមាសបន្ទាប់ ក៏ដូចជាបានកំណត់នូវដំណោះស្រាយដែរ។

### ២.១.៣ ការគ្រប់គ្រងមណ្ឌលសុខភាព (២០ពិន្ទុ)

➢ **ការធានាការផ្តល់សេវា២៤ម៉ោង**

- ***សេចក្តីពន្យល់៖*** សំដៅដល់មណ្ឌលសុខភាពមានវត្តមានបុគ្គលិកប្រចាំការ ២៤ម៉ោង ក្នុង១ថ្ងៃ និង ៧ថ្ងៃ ក្នុង១សប្តាហ៍។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)តារាងបែងចែកវេនយាម ២)តារាងកម្មវិធីការងារប្រចាំសប្តាហ៍និងប្រចាំខែ និង៣)វត្តមានរបស់បុគ្គលិក។ ការពិនិត្យមើលវត្តមានរបស់បុគ្គលិកគឺ ត្រូវធ្វើឡើងតាមការជួបសម្ភាសន៍តាមរយៈទូរស័ព្ទជាមួយអ្នកប្រើប្រាស់សេវា ឬប្រជាពលរដ្ឋដែលបានប្រើប្រាស់សេវាមណ្ឌលសុខភាព យ៉ាងតិច៥នាក់។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | តារាងបែងចែកវេនយាម |
| ពិន្ទុ ១ | តារាងកម្មវិធីការងារប្រចាំសប្តាហ៍និងប្រចាំខែ |
| ពិន្ទុ ៣ | វត្តមានរបស់បុគ្គលិក៖ ករណីអ្នកប្រើប្រាស់សេវាផ្តល់ចម្លើយវិជ្ជមានទាំង៥នាក់ ត្រូវផ្តល់ពិន្ទុ៣, ករណីអ្នកប្រើប្រាស់សេវា១នាក់ផ្តល់ចម្លើយអវិជ្ជមាន ត្រូវដក១ពិន្ទុ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** កម្មវិធីការងារប្រចាំសប្តាហ៍ ឬប្រចាំខែ សំដៅលើមណ្ឌលសុខភាពត្រូវរៀបចំតារាងសម្រាប់បំពេញការងារ១សប្តាហ៍ ឬ ១ខែម្តង ដោយមានដាក់ឈ្មោះបុគ្គលិក ថ្ងៃខែធ្វើការ ពេលយាម ការចុះផ្តល់សេវាមូលដ្ឋាន និងការបំពេញភារកិច្ចផ្សេងៗទៀត។ លើសពីនេះ មណ្ឌលសុខភាពត្រូវមានផែនការជំនួសបុគ្គលិកពេលអវត្តមាន ដើម្បីជៀសវាងដំណើរការរអាក់រអួលនៅមណ្ឌលសុខភាព។ ក្នុងករណីមណ្ឌលសុខភាពបានរៀបចំតែកម្មវិធីប្រចាំសប្តាហ៍ អាចបូកជាប្រចាំខែ។

➢ **កិច្ចប្រជុំបុគ្គលិកប្រចាំខែ**

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរៀបចំកិច្ចប្រជុំប្រចាំខែរបស់បុគ្គលិកមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)កំណត់ហេតុនៃកិច្ចប្រជុំ ២)បញ្ជីឈ្មោះអ្នកចូលរួមមានចុះហត្ថលេខា និង៣)របៀបវារៈនៃកិច្ចប្រជុំ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ៣ | មានកំណត់ហេតុនៃកិច្ចប្រជុំ១២ខែក្នុង១ឆ្នាំ៖ ក្នុងករណីមិនមានកំណត់ហេតុនៃកិច្ចប្រជុំ១ខែ ត្រូវដក១ពិន្ទុ |
| ពិន្ទុ ១ | មានបញ្ជីឈ្មោះអ្នកចូលរួមដោយមានចុះហត្ថលេខានៃកិច្ចប្រជុំ១២ខែក្នុង១ឆ្នាំ |
| ពិន្ទុ ១ | មានរបៀបវារៈនៃកិច្ចប្រជុំ១២ខែក្នុង១ឆ្នាំ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** របៀបវារៈនៃកិច្ចប្រជុំបុគ្គលិក ផ្តោតលើ (១)ផ្តល់នូវព័ត៌មានផ្សេងៗជុំវិញការអនុវត្តការងាររបស់បុគ្គលិក ឬព័ត៌មានដែលទទួលបានពីកន្លែងផ្សេងទៀត (២)បង្ហាញពីលទ្ធផលនៃការអនុវត្តការងារដោយប្រៀបធៀបនឹងផែនការជូនបុគ្គលិកពិនិត្យរួមគ្នា (៣)ផ្តល់ឱកាសដល់បុគ្គលិកបញ្ចេញយោបល់ពីបញ្ហាដែលពួកគេជួបប្រទះ និងរកដំណោះស្រាយរួមគ្នា។

## ➢ ភាពស្អាតនៃឱសថស្ថានមណ្ឌលសុខភាព និងការរៀបចំឱសថតាមគោលការណ៍ណែនាំ

- ***សេចក្តីពន្យល់៖*** សំដៅដល់ភាពស្អាត អនាម័យ សណ្តាប់ធ្នាប់តាមគោលការណ៍ណែនាំនៅក្នុងឱសថស្ថានមណ្ឌលសុខភាពដើម្បីធានាគុណភាព និងងាយស្រួលតាមដានស្តុកឱសថ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផ្ទៃកម្រាល ពិដាន ជញ្ជាំង បង្អួច ទ្វារ ធ្នើដាក់ឱសថ ប្រអប់ឱសថ និងបរិក្ខារមានភាពស្អាត ២)ការរៀបចំទុកដាក់ឱសថតាមលំដាប់អក្សរ(សម្រាប់ឱសថសារវន្ត) ៣)ការអនុវត្តតាមគោលការណ៍ FEFO និងFIFO ៤)មានទែម៉ូម៉ែត្រនៅក្នុងឱសថស្ថាន(សីតុណ្ហភាពត្រូវមានកម្រិតប្រែប្រួលទៅតាមនាយកដ្ឋានឱសថ...) និង៥)ឯកសារគ្រប់គ្រងឱសថ បញ្ជីឱសថដែលមានបច្ចុប្បន្នភាព និងលិខិតស្នើសុំឱសថប្រចាំខែ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | ផ្ទៃកម្រាល ពិដាន ជញ្ជាំង បង្អួច ទ្វារ ធ្នើដាក់ឱសថ ប្រអប់ឱសថ និងបរិក្ខារមានភាពស្អាត |
| ពិន្ទុ ១ | ការរៀបចំទុកដាក់ឱសថតាមលំដាប់អក្សរ(សម្រាប់ឱសថសារវន្ត) |
| ពិន្ទុ ១ | ការអនុវត្តតាមគោលការណ៍ FEFO និងFIFO |
| ពិន្ទុ ១ | មានទែម៉ូម៉ែត្រនៅក្នុងឱសថស្ថាន(សីតុណ្ហភាពត្រូវមានកម្រិតប្រែប្រួលទៅតាមនាយកដ្ឋាន ឱសថ...) |
| ពិន្ទុ ១ | មានឯកសារគ្រប់គ្រងឱសថ បញ្ជីឱសថដែលមានបច្ចុប្បន្នភាព និងលិខិតស្នើសុំឱសថប្រចាំខែ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ➢ ការគ្រប់គ្រងប្រព័ន្ធត្រជាក់

- ***សេចក្តីពន្យល់៖*** សំដៅដល់ការគ្រប់គ្រងប្រព័ន្ធត្រជាក់(សម្ភារៈដែលបានផ្តល់ដោយកម្មវិធីជាតិផ្តល់ថ្នាំបង្ការ) នៅក្នុងមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ទូទឹកកកថែរក្សាវ៉ាក់សាំង ២)ធុងក្លាស្សេ(ខ្នាត២៥ និង១៤លីត្រ)សម្រាប់ដឹកជញ្ជូនវ៉ាក់សាំង ៣)ធុងវ៉ាក់សាំងសម្រាប់ផ្តល់ថ្នាំបង្ការនៅមណ្ឌលសុខភាព និងតាមភូមិ ៤)កំណត់ត្រាសីតុណ្ហភាពនៅនឹងកន្លែង(សីតុណ្ហភាពបានវាស់វែងតាមពិធីសារជាតិ ដែលជានិច្ចកាលស្ថិតចន្លោះពី ២ទៅ៨អង្សាសេ) និង៥)របាយការណ៍ស្ថានភាពវ៉ាក់សាំងនិងសម្ភារៈប្រចាំខែ។

- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ១ | ទូទឹកកកថែរក្សាវ៉ាក់សាំងដំណើរការល្អ |
| ពិន្ទុ ១ | ធុងក្លាសេ្ស(ខ្នាត២៥ និង១៤លីត្រ)សម្រាប់ដឹកជញ្ជូនវ៉ាក់សាំង |
| ពិន្ទុ ១ | ធុងវ៉ាក់សាំងសម្រាប់ផ្តល់ថ្នាំបង្ការនៅមណ្ឌលសុខភាព និងតាមភូមិ |
| ពិន្ទុ ១ | កំណត់ត្រាសីតុណ្ហភាពនៅនឹងកន្លែង(សីតុណ្ហភាពបានវាស់វែងតាមពិធីសារជាតិ ដែលជានិច្ចកាលស្ថិតចន្លោះពី ២ទៅ៨អង្សាសេ) |
| ពិន្ទុ ១ | របាយការណ៍ស្ថានភាពវ៉ាក់សាំងនិងសម្ភារៈប្រចាំខែ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ២.២ ការបង្ការ ការត្រួតពិនិត្យការចម្លងរោគ និងអនាម័យ (៦០ពិន្ទុ)

### ២.២.១ ការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ (១៥ពិន្ទុ)

➢ <u>ក្រុមការងារត្រួតពិនិត្យការចម្លងរោគតាមស្តង់ដា</u>

- *សេចក្តីពន្យល់៖* សំដៅដល់ក្រុមការងារត្រួតពិនិត្យការចម្លងរោគ ដែលបានបង្កើតឡើងដើម្បីត្រួតពិនិត្យ តាមដានការបង្ការការចម្លងរោគក្នុងមណ្ឌលសុខភាព។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ១)លិខិតបង្គាប់ការបង្កើតក្រុមការងារត្រួតពិនិត្យការចម្លងរោគ ២)មានតួនាទីភារកិច្ច ឬមានអ្នកទទួលខុសត្រូវការងារត្រួតពិនិត្យការចម្លងរោគ និង៣)មណ្ឌលសុខភាពស្អាត។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់ ៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ២ | មានលិខិតបង្គាប់ការបង្កើតក្រុមការងារត្រួតពិនិត្យការចម្លងរោគ |
| ពិន្ទុ ២ | មណ្ឌលសុខភាពស្អាត |
| ពិន្ទុ ១ | មានតួនាទីភារកិច្ច ឬមានអ្នកទទួលខុសត្រូវការងារត្រួតពិនិត្យការចម្លងរោគ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>ការអនុវត្តបានត្រឹមត្រូវនូវការចាក់ថ្នាំដែលមានសុវត្ថិភាព</u>

- *សេចក្តីពន្យល់៖* សំដៅដល់ការប្រតិបត្តិទាំងឡាយដែលធ្វើឡើងនៅពេលចាក់ថ្នាំដើម្បីកុំឱ្យគ្រោះថ្នាក់ដល់អ្នកជំងឺ អ្នកផ្តល់សេវាប៉ះពាល់ទៅនឹងហានិភ័យណាមួយ និងការចាក់ថ្នាំបង្កជាសំណល់ដែលអាចគ្រោះថ្នាក់ដល់បុគ្គលិកដទៃទៀត ឬសហគមន៍។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ១)សៀវភៅមគ្គុទេសក៍ស្តីពីសុវត្ថិភាពនៃការចាក់ថ្នាំ(ឆ្នាំ២០១៤) និង២)ការប្រតិបត្តិត្រឹមត្រូវទាំង១០ចំណុច(១.អ្នកជំងឺត្រឹមត្រូវ ២.ឱសថ

ត្រឹមត្រូវ ៣.រូបមន្តត្រឹមត្រូវ ៤.ឧបករណ៍ចាក់ថ្នាំត្រឹមត្រូវ ៥.ដូសត្រឹមត្រូវ ៦.ពេលវេលាត្រឹមត្រូវ ៧.ផ្លូវបញ្ចូលឱសថត្រឹមត្រូវ ៨.ការរក្សាឯកសារត្រឹមត្រូវ ៩.ការទុកដាក់ត្រឹមត្រូវ ១០.ការបោះចោលត្រឹមត្រូវ)។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់ ៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានសៀវភៅមគ្គុទេសក៍ ស្តីពីសុវត្ថិភាពនៃការចាក់ថ្នាំនិងបុគ្គលិកមណ្ឌលសុខភាពឆ្លើយត្រូវទាំង១០ចំណុច |
| ពិន្ទុ ៤ | មានសៀវភៅមគ្គុទេសក៍ ស្តីពីសុវត្ថិភាពនៃការចាក់ថ្នាំនិងបុគ្គលិកមណ្ឌលសុខភាពឆ្លើយត្រូវបាន៨-៩ចំណុច |
| ពិន្ទុ ៣ | មានសៀវភៅមគ្គុទេសក៍ ស្តីពីសុវត្ថិភាពនៃការចាក់ថ្នាំនិងបុគ្គលិកមណ្ឌលសុខភាពឆ្លើយត្រូវបាន៦-៧ចំណុច |
| ពិន្ទុ ២ | មានសៀវភៅមគ្គុទេសក៍ ស្តីពីសុវត្ថិភាពនៃការចាក់ថ្នាំនិងបុគ្គលិកមណ្ឌលសុខភាពឆ្លើយត្រូវបាន៤-៥ចំណុច |
| ពិន្ទុ ១ | មានសៀវភៅមគ្គុទេសក៍ ស្តីពីសុវត្ថិភាពនៃការចាក់ថ្នាំនិងបុគ្គលិកមណ្ឌលសុខភាពឆ្លើយត្រូវបានតែ៣ចំណុច |
| ពិន្ទុ ០ | គ្មានសៀវភៅមគ្គុទេសក៍ ស្តីពីសុវត្ថិភាពនៃការចាក់ថ្នាំ ឬមានសៀវភៅប៉ុន្តែបុគ្គលិកមណ្ឌលសុខភាពឆ្លើយត្រូវបានតែ ១-២ចំណុច |

➢ ផែនការគ្រប់គ្រងសំណល់វេជ្ជសាស្ត្ររបស់មណ្ឌលសុខភាព

- ***សេចក្តីពន្យល់៖*** សំដៅដល់ផែនការសម្រាប់គ្រប់គ្រងសំណល់វេជ្ជសាស្ត្ររបស់មណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ផែនការគ្រប់គ្រងសំណល់របស់មណ្ឌលសុខភាព។ នៅក្នុងផែនការមាន៥ចំណុចរួមមាន៖ ១)ការចាត់ចែងសំណល់ក្នុងមណ្ឌលសុខភាព(ការញែកសំណល់ ការប្រមូលសំណល់ចេញពីសាលឬបន្ទប់ ការរក្សាទុកសំណល់បណ្តោះអាសន្ន ការបោះចោលសំណល់ចុងក្រោយ) ២)តាមដានត្រួតពិនិត្យការចាត់ចែងសំណល់ ៣)ប្រជុំផ្សព្វផ្សាយពីការចាត់ចែងសំណល់ជាមួយបុគ្គលិក ៤)ប្រជុំផ្សព្វផ្សាយពីការចាត់ចែងសំណល់ជាមួយអ្នកកំដរនិងអ្នកជំងឺ និង៥)វគ្គបណ្តុះបណ្តាល ឬរំលឹកស្តីពីការបង្ការនិងត្រួតពិនិត្យការចម្លងរោគ(មានគំរូផែនការគ្រប់គ្រងសំណល់)។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការចាត់ចែងសំណល់ក្នុងមណ្ឌលសុខភាព( ការញែកសំណល់ ការប្រមូលសំណល់ចេញពីសាលឬបន្ទប់ ការរក្សាទុកសំណល់បណ្តោះអាសន្ន ការបោះចោលសំណល់ចុងក្រោយ) |

| | |
|---|---|
| ពិន្ទុ ១ | មានការតាមដានត្រួតពិនិត្យការចាត់ចែងសំណល់ដោយប្រើបញ្ជីផ្ទៀងផ្ទាត់២ដងក្នុង១សប្ដាហ៍ |
| ពិន្ទុ ១ | មានប្រជុំផ្សព្វផ្សាយពីការចាត់ចែងសំណល់ជាមួយបុគ្គលិករាល់ពេលព្រឹករៀងរាល់ថ្ងៃ |
| ពិន្ទុ ១ | មានប្រជុំផ្សព្វផ្សាយពីការចាត់ចែងសំណល់ជាមួយអ្នកកំដរ និងអ្នកជំងឺរាល់ពេលព្រឹករៀងរាល់ថ្ងៃ |
| ពិន្ទុ ១ | មានវគ្គបណ្ដុះបណ្ដាលឬរំលឹកស្ដីពីការបង្ការនិងត្រួតពិនិត្យការចម្លងរោគដល់បុគ្គលិកទាំងអស់រួមទាំងអ្នកសម្អាតឬអ្នកបើកបរ |
| ពិន្ទុ ០ | គ្មានផែនការគ្រប់គ្រងសំណល់ |

### ២.២.២ អនាម័យ (២៥ពិន្ទុ)

➢ <u>មានកន្លែងលាងដៃនៅផ្នែកពិគ្រោះជំងឺក្រៅ បន្ទប់ពិនិត្យផ្ទៃពោះ បន្ទប់សម្រាល បន្ទប់ក្រោយសម្រាល បន្ទប់ចាក់ថ្នាំបង្ការ បង្គន់ ដែលមានទឹករ៉ូប៊ីណេ មានក្រដាសជូតដៃ ឬកន្សែងស្អាតសម្រាប់ជូតដៃ (ប្រើតែម្ដង) មានសាប៊ូទឹក</u>

- ***សេចក្ដីពន្យល់៖*** សំដៅដល់កន្លែងលាងដៃ(ឡាវ៉ាបូ)នៅមណ្ឌលសុខភាពដែលមានទឹករ៉ូប៊ីណេ មានសាប៊ូទឹក មានក្រដាសជូតដៃឬកន្សែងស្អាតសម្រាប់ជូតដៃ(ប្រើតែម្ដង)។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)កន្លែងលាងដៃ(ឡាវ៉ាបូ) នៅតាមបន្ទប់ពិគ្រោះជំងឺក្រៅ បន្ទប់ពិនិត្យផ្ទៃពោះ បន្ទប់សម្រាល បន្ទប់ក្រោយសម្រាល បន្ទប់ចាក់ថ្នាំបង្ការ បង្គន់ និង២)មានសម្ភារៈគ្រប់ចំនួន។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់ ៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានកន្លែងលាងដៃនៅគ្រប់កន្លែងទាំង៦ដំណើរការ និងមានសម្ភារៈគ្រប់គ្រាន់ |
| ពិន្ទុ ៤ | មានកន្លែងលាងដៃ៥កន្លែងដំណើរការ និងមានសម្ភារៈគ្រប់គ្រាន់ |
| ពិន្ទុ ៣ | មានកន្លែងលាងដៃ៤កន្លែងដំណើរការ និងមានសម្ភារៈគ្រប់គ្រាន់ |
| ពិន្ទុ ២ | មានកន្លែងលាងដៃ៣កន្លែងដំណើរការ និងមានសម្ភារៈគ្រប់គ្រាន់ |
| ពិន្ទុ ១ | មានកន្លែងលាងដៃតែ២កន្លែងដំណើរការ និងមានសម្ភារៈគ្រប់គ្រាន់ |
| ពិន្ទុ ០ | មានកន្លែងលាងដៃនៅគ្រប់កន្លែងទាំង៦ តែគ្មានសម្ភារៈគ្រប់គ្រាន់ ឬមានកន្លែងលាងដៃតែមួយកន្លែង |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** បើមានតែកន្លែងលាងដៃតែខ្វះសម្ភារៈសូមផ្ដល់ពិន្ទុ០។

➢ <u>បុគ្គលិកមណ្ឌលសុខភាពបានអនុវត្តអនាម័យដៃ (HH Compliance)</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការអនុវត្តអនាម័យដៃរបស់បុគ្គលិកមណ្ឌលសុខភាពក្នុងពេលផ្តល់សេវា ត្រូវអនុវត្តតាមជំហានទាំង៦ និងវេលាទាំង៥ តាមស្តង់ដា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** គណៈកម្មការវាយតម្លៃត្រូវធ្វើការសង្កេតមើលការអនុវត្តអនាម័យដៃរបស់បុគ្គលិកមណ្ឌលសុខភាពនៅពេលផ្តល់សេវា តាមវេលាទាំង៥ និងជំហានទាំង៦(សង្កេតមើលបុគ្គលិកផ្នែកពិគ្រោះជំងឺក្រៅ ផ្នែកពិនិត្យផ្ទៃពោះ ផ្នែកសម្រាលកូន ផ្នែកផ្តល់ថ្នាំបង្ការ)។ល។ ត្រូវកត់ត្រាទុកក្នុងតារាងសង្កេតដើម្បីចែករកមធ្យមភាគ (តារាងនេះមានក្នុងឧបករណ៍តាមដាននិងវាយតម្លៃសម្រាប់ការបង្ការនិងការត្រួតពិនិត្យការចម្លងរោគ ទំព័រ១៣)។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់ ៥៖***

| | |
|---|---|
| ពិន្ទុ ៥ | អនុវត្តន៍អនាម័យដៃរបស់បុគ្គលិកមណ្ឌលសុខភាពបាន ៩០-១០០ភាគរយ |
| ពិន្ទុ ៤ | អនុវត្តន៍អនាម័យដៃរបស់បុគ្គលិកមណ្ឌលសុខភាពបាន ៨០-៨៩ភាគរយ |
| ពិន្ទុ ៣ | អនុវត្តន៍អនាម័យដៃរបស់បុគ្គលិកមណ្ឌលសុខភាពបាន ៦០-៧៩ភាគរយ |
| ពិន្ទុ ២ | អនុវត្តន៍អនាម័យដៃរបស់បុគ្គលិកមណ្ឌលសុខភាពបាន ៤០-៥៩ភាគរយ |
| ពិន្ទុ ១ | អនុវត្តន៍អនាម័យដៃរបស់បុគ្គលិកមណ្ឌលសុខភាពបាន ២០-៣៩ភាគរយ |
| ពិន្ទុ ០ | អនុវត្តន៍អនាម័យដៃរបស់បុគ្គលិកមណ្ឌលសុខភាពបាន ០-១៩ភាគរយ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** បើសិនបុគ្គលិកបានអនុវត្តអនាម័យដៃបានត្រឹមត្រូវតាមពេលវេលាសូមធ្វើការរាប់ឱកាស និងការអនុវត្តជាក់ស្តែង រួចសូមផ្តល់ពិន្ទុតាមភាគរយដែលពួកគាត់ទទួលបាន។ ឧទាហរណ៍៖ ដើម្បីរកភាគរយនៃការធ្វើអនាម័យដៃដែលពួកគាត់ទទួលបាន ត្រូវយកចំនួនសកម្មភាពអនាម័យដៃដែលបានធ្វើគុណនិង១០០ រួចចែកនិងសកម្មភាពអនាម័យដៃដែលចាំបាច់ត្រូវធ្វើ(ឱកាស)

$$\text{ភាគរយនៃការលាងដៃដែលពួកគាត់ទទួលបាន} = \frac{\text{សកម្មភាពអនាម័យដៃដែលបានធ្វើ} \times ១០០}{\text{សកម្មភាពអនាម័យដៃដែលចាំបាច់ត្រូវធ្វើ(ឱកាស)}}$$

➢ ស្ត្រីសម្រាលកូន និងអ្នកកំដរមានចំណេះដឹងអំពីអនាម័យដៃ

- *សេចក្តីពន្យល់៖* សំដៅដល់ស្ត្រីសម្រាលកូននិងអ្នកកំដរត្រូវមានចំណេះដឹងអំពីអនាម័យដៃ ដើម្បីបង្ការការចម្លងរោគពីម្តាយទៅកូន ឬពីអ្នកកំដរទៅទារក។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ចំណេះដឹងពាក់ព័ន្ធនឹងការធ្វើអនាម័យដៃរបស់ស្ត្រីសម្រាលកូន និងអ្នកកំដរ តាមពេលវេលាដូចខាងក្រោម៖ ១)ពេលមុនប៉ះពាល់ទារក ២)មុននិងក្រោយបរិភោគអាហារ ៣)ក្រោយផ្លាស់កន្ទបកូន ៤)ក្រោយចេញពីបន្ទប់ទឹក ៥)នៅពេលដៃប្រលាក់ ៦)បន្ទាប់ពីក្អក កណ្តាស់ ឬជូតសំបោរ ៧)បន្ទាប់ពីប៉ះពាល់វត្ថុរាវចេញពីរាងកាយ ៨)បន្ទាប់ពីជូតសម្អាតបន្ទប់ទឹក ៩)បន្ទាប់ពីប៉ះពាល់លាមកសត្វ ១០)បន្ទាប់ពីប៉ះសំរាម ឬរបស់របរដែលអាចចម្លងរោគ ១១)បន្ទាប់ពីប៉ះសាច់ឆៅ ១២)មុន និងក្រោយពេលប៉ះពាល់របួស ដំបៅ និង១៣)បន្ទាប់ពីដៃមើលឃើញកខ្វក់។ ដើម្បីពិនិត្យមើលចំណុចខាងលើ គណៈកម្មការវាយតម្លៃត្រូវជួបសម្ភាសន៍ជាមួយស្ត្រីសម្រាលកូន និងអ្នកកំដរ។ ក្នុងករណីមិនជួបស្ត្រីសម្រាលកូនទេ សូមសម្ភាសន៍ជាមួយអតិថិជនដែលចូលមកប្រើប្រាស់សេវានៅមណ្ឌលសុខភាព(ឧ.ស្ត្រីយកកូនមកចាក់វ៉ាក់សាំង ឬមកពិនិត្យផ្ទៃពោះ ឬក៏ស្ត្រីដែលយកកូនមកពិនិត្យពិគ្រោះជំងឺក្រៅ។ល។ ឬសម្ភាសន៍តាមទូរស័ព្ទជាមួយអតិថិជនដែលធ្លាប់មកប្រើប្រាស់សេវា។ សម្ភាសន៍ជាមួយស្ត្រីសម្រាល និងអ្នកកំដរ ឬអតិថិជនដែលចូលមកប្រើប្រាស់សេវានៅមណ្ឌលសុខភាព ចំនួន៥នាក់។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់ ៥៖*

| | |
|---|---|
| ពិន្ទុ ៥ | ស្ត្រីសម្រាលឆ្លើយបានត្រឹមត្រូវ ១០ ចំណុច |
| ពិន្ទុ ៤ | ស្ត្រីសម្រាលឆ្លើយបានត្រឹមត្រូវ ៨-៩ ចំណុច |
| ពិន្ទុ ៣ | ស្ត្រីសម្រាលឆ្លើយបានត្រឹមត្រូវ ៦-៧ ចំណុច |
| ពិន្ទុ ២ | ស្ត្រីសម្រាលឆ្លើយបានត្រឹមត្រូវ ៤-៥ ចំណុច |
| ពិន្ទុ ១ | ស្ត្រីសម្រាលឆ្លើយបានត្រឹមត្រូវ ២-៣ ចំណុច |
| ពិន្ទុ ០ | ស្ត្រីសម្រាលឆ្លើយត្រូវ ០-១ ចំណុច |

➢ អនាម័យនៅតាមបន្ទប់ផ្តល់សេវាទាំងអស់ ផ្នែកពិគ្រោះជំងឺក្រៅ បន្ទប់ពិនិត្យផ្ទៃពោះ បន្ទប់សម្រាល បន្ទប់ក្រោយសម្រាល បន្ទប់ចាក់ថ្នាំបង្ការ និងកន្លែងចុះឈ្មោះដំបូង (របៀបសម្អាត និងការប្រើប្រាស់សូលុយស្យុង)

- *សេចក្តីពន្យល់៖* សំដៅដល់ការធ្វើអនាម័យនៅតាមបន្ទប់ផ្តល់សេវាទាំងអស់ក្នុងមណ្ឌលសុខភាពដោយប្រើប្រាស់សូលុយស្យុងសម្លាប់មេរោគ និងរបៀបសម្អាតតាមបន្ទប់នីមួយៗ។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ១)របៀបសម្អាត និង២)ការប្រើប្រាស់

សូលុយស្យុងឱ្យបានត្រឹមត្រូវតាមបន្ទប់នីមួយៗ។ ដើម្បីមើលរបៀបសម្អាត គណៈកម្មការវាយតម្លៃត្រូវសួរសំណួរចំនួន៤ ដូចជាៈ ១.របៀបសម្អាតវត្ថុរាវចេញពីរាងកាយអ្នកជំងឺយ៉ាងដូចម្តេច? ២.តើការសម្អាតពីតំបន់ប្រឈមទាប ទៅតំបន់ប្រឈមខ្ពស់ឬយ៉ាងណា? ៣.តើការប្រើប្រាស់សម្ភារៈសម្អាតយ៉ាងដូចម្តេច? និង៤.តើការសម្អាតសម្ភារៈនិងទុកដាក់បន្ទាប់ពីធ្វើការសម្អាតរួចយ៉ាងដូចម្តេច?។ ដើម្បីមើលការប្រើប្រាស់សូលុយស្យុងឱ្យបានត្រឹមត្រូវតាមបន្ទប់នីមួយៗ គណៈកម្មការវាយតម្លៃត្រូវសួរសំណួរចំនួន៣ ដូចជាៈ ១.ការប្រើប្រាស់សូលុយស្យុងសម្អាតតាមបន្ទប់នីមួយៗ តើបន្ទប់ណាត្រូវប្រើសុលុយស្យុងអ្វី? ២.តើដឹងពីរបៀបលាយសុលុយស្យុង ក្លរីន ០.០៥ភាគរយ ឬទេ ហើយប្រើពេលណា? និង៣.តើក្លរីន ០.៥ភាគរយ ប្រើពេលណា?។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់ ៥ៈ***

| | |
|---|---|
| ពិន្ទុ ៥ | ឆ្លើយត្រូវទាំង៧សំណួរ |
| ពិន្ទុ ៤ | ឆ្លើយខុស១សំណួរ |
| ពិន្ទុ ៣ | ឆ្លើយខុស២សំណួរ |
| ពិន្ទុ ២ | ឆ្លើយខុស៣សំណួរ |
| ពិន្ទុ ១ | ឆ្លើយខុស៤សំណួរ |
| ពិន្ទុ ០ | ឆ្លើយខុស៥សំណួរ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យៈ*** ដើម្បីយល់កាន់តែច្បាស់ពីចម្លើយរបស់សំណួរខាងលើសូមអានគោលការណ៍ណែនាំស្តីពីការបង្ការ និងត្រួតពិនិត្យការចម្លងរោគ ឆ្នាំ២០១៧ (ទំព័រ ៥៣, ៥៤, ៥៥, ១៧៣, ១១១)។ ប្រសិនបើមណ្ឌលសុខភាពគ្មានអ្នកអនាម័យទេ សូមសម្ភាសន៍ជាមួយបុគ្គលិកមណ្ឌលសុខភាព។

➤ <u>នៅតាមបន្ទប់នីមួយៗ ផ្ទៃកម្រាល ពិដាន ជញ្ជាំង បង្អួច ទ្វារ និងកង្ហារ មានភាពស្អាត</u>

- ***សេចក្តីពន្យល់ៈ*** សំដៅដល់ការធ្វើអនាម័យនៅតាមបន្ទប់ផ្តល់សេវាទាំងអស់ក្នុងមណ្ឌលសុខភាព ដោយពិនិត្យមើលផ្ទៃកម្រាល ពិដាន ជញ្ជាំង បង្អួច ទ្វារ និងកង្ហារ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)ៈ*** ចំណុចត្រូវពិនិត្យគឺ ភាពស្អាតនៅផ្ទៃកម្រាល ពិដាន ជញ្ជាំង បង្អួច ទ្វារ និងកង្ហារ តាមបន្ទប់ផ្តល់សេវាទាំងអស់។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)ៈ***

| | |
|---|---|
| ពិន្ទុ ១ | បន្ទប់ពិគ្រោះជំងឺក្រៅនិងកន្លែងចុះឈ្មោះដំបូងស្អាត គ្រប់កន្លែងទាំងអស់ |
| ពិន្ទុ ១ | បន្ទប់សម្រាលស្អាត គ្រប់កន្លែងទាំងអស់ |
| ពិន្ទុ ១ | បន្ទប់ពិនិត្យផ្ទៃពោះស្អាត គ្រប់កន្លែងទាំងអស់ |

| | |
|---|---|
| ពិន្ទុ ១ | បន្ទប់ក្រោយសម្រាលស្អាត គ្រប់កន្លែងទាំងអស់ |
| ពិន្ទុ ១ | បន្ទប់ផ្តល់ថ្នាំបង្ការស្អាត គ្រប់កន្លែងទាំងអស់ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** បើបន្ទប់ណាមួយ មានធូលី ឬពីងពាង ឬសំរាមលើផ្ទៃកម្រាល ឬពិដាន ឬជញ្ជាំង ឬបង្អួច ឬទ្វារ ឬកង្ហារ គឺបានពិន្ទុ០ក្នុងបន្ទប់នោះ។

### ២.២.៣ សុវត្ថិភាពទឹក (២០ពិន្ទុ)

➢ <u>មានប្រភពទឹកស្អាតនៅក្នុងបរិវេណសម្រាប់ផ្គត់ផ្គង់ទឹកគ្រប់ពេល(គោលការណ៍ណែនាំស្តីពីទឹកស្អាត និងអនាម័យនៅមូលដ្ឋានព្យាបាល និងថែទាំសុខភាព ឆ្នាំ២០១៨)</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ប្រភពទឹកស្អាតសម្រាប់ផ្គត់ផ្គង់ការប្រើប្រាស់នៅក្នុងមណ្ឌលសុខភាព (ឧ.ទឹកត្រូវមានពេញមួយឆ្នាំ និងមិនត្រូវបានកាត់ផ្តាច់ដោយរដូវកាល ឬការដាច់ចរន្តអគ្គិសនីឡើយ ប្រភពទឹកស្អាតរួមមាន៖ ទឹកពីប្រព័ន្ធទុយោដែលចែកចាយ ឬផ្គត់ផ្គង់ដោយអង្គភាពដែលមានអាជ្ញាប័ណ្ណ ទឹកពីអណ្តូងដែលមានការការពារ ទឹកផុសធម្មជាតិដែលមានការការពារ និងទឹកភ្លៀង ដូចមានចែងក្នុងឧបសម្ព័ន្ធទី២ នៃគោលការណ៍ណែនាំស្តីពី ទឹកស្អាត និងអនាម័យនៅមូលដ្ឋានព្យាបាល និងថែទាំសុខភាព ឆ្នាំ២០១៨)។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ប្រភពទឹកស្អាត ២)ការការពារត្រឹមត្រូវ និង៣)ផ្គត់ផ្គង់បានគ្រប់ពេល។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានប្រភពទឹកស្អាតត្រឹមត្រូវសមស្របតាមគោលការណ៍ណែនាំស្តីពីទឹកស្អាតនិងអនាម័យ |
| ពិន្ទុ ២ | ការផ្គត់ផ្គង់បានគ្រប់ពេល |
| ពិន្ទុ ១ | ការការពារត្រឹមត្រូវ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>ទឹកមានគ្រប់ពេល ប្រព័ន្ធទុយោទឹកត្រូវតែដំណើរការ(គ្មានការលេចធ្លាយ រាល់ចំណុចប្រើទាំងអស់ត្រូវតែតភ្ជាប់ទៅនឹងប្រព័ន្ធផ្គត់ផ្គង់ទឹកដែលដំណើរការ)</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់វត្តមានទឹកត្រូវតែមានគ្រប់ពេល២៤ម៉ោង/២៤ម៉ោង ហើយអាចយកមកប្រើប្រាស់បានតាមរយៈរ៉ូប៊ីណេដែលដំណើរការនៅគ្រប់កន្លែងផ្តល់សេវាថែទាំសុខភាពទាំងអស់។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ក្បាលរ៉ូប៊ីណេទាំងអស់ក្នុងមណ្ឌលសុខភាព និង២)មានទឹកហូរចេញពីក្បាលរ៉ូប៊ីណេគ្រប់ពេល។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | គ្រប់ក្បាលរ៉ូប៊ីណេទាំងអស់ដំណើរការ និងមានទឹកហូរ |
| ពិន្ទុ ៤ | បើខូចរ៉ូប៊ីណេ១ |
| ពិន្ទុ ៣ | បើខូចរ៉ូប៊ីណេ២ |
| ពិន្ទុ ២ | បើខូចរ៉ូប៊ីណេ៣ |
| ពិន្ទុ ១ | បើខូចរ៉ូប៊ីណេ៤ |
| ពិន្ទុ ០ | បើខូចរ៉ូប៊ីណេ៥ ឬគ្មានទឹក/ដាច់ទឹក |

➢ <u>បរិមាណទឹកគ្រប់គ្រាន់ ដើម្បីបំពេញតាមតម្រូវការអប្បរមាប្រចាំថ្ងៃរបស់មណ្ឌលសុខភាព(គោលការណ៍ណែនាំស្តីពីទឹកស្អាត និងអនាម័យនៅមូលដ្ឋានព្យាបាល និងថែទាំសុខភាព ឆ្នាំ២០១៨)</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ទឹកស្អាតត្រូវតែមានបរិមាណគ្រប់គ្រាន់ដើម្បីបំពេញតាមតម្រូវការអប្បបរមាប្រចាំថ្ងៃរបស់មណ្ឌលសុខភាពសម្រាប់អ្នកជំងឺ ភ្ញៀវ និងបុគ្គលិក។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖***ចំណុចត្រូវពិនិត្យគឺ ១)មានធុងស្តុកទឹកដែលមានសមត្ថភាពផ្គត់ផ្គង់ទឹកបានរយៈពេល២ថ្ងៃ ដើម្បីប្រើជាទឹកបម្រុងក្នុងករណីប្រភពទឹកមានបញ្ហាមិនអាចប្រើប្រាស់បាន ២)ធុងស្តុកទឹកមានភាពស្អាត គម្របបិទជិត និងថែទាំបានល្អ ដើម្បីបង្ការភាពកខ្វក់(គ្មានស្មៅ ម្រេះ លេច) និង៣)ធុងស្តុកទឹក មានតភ្ជាប់ជាមួយប្រព័ន្ធបង្ហូរ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានធុងស្តុកទឹកដែលមានសមត្ថភាពផ្គត់ផ្គង់ទឹកបានរយៈពេល២ថ្ងៃ និងមានទឹក |
| ពិន្ទុ ២ | ធុងស្តុកទឹកស្អាត មានគម្របបិទជិតនិងថែទាំបានល្អ ដើម្បីបង្ការភាពកខ្វក់(គ្មានស្មៅ ម្រេះ លេច) |
| ពិន្ទុ ១ | ធុងស្តុកទឹកដែលមានតភ្ជាប់ជាមួយប្រព័ន្ធបង្ហូរ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ដើម្បីគណនាតម្រូវការទឹកអប្បបរមាដែលត្រូវការសម្រាប់មណ្ឌលសុខភាពបរិមាណស្តង់ដាត្រូវបានណែនាំសម្រាប់គណនាមាននៅក្នុងតារាងទី៣ក្នុងគោលការណ៍ណែនាំស្តីពីទឹកស្អាត និងអនាម័យនៅមូលដ្ឋានព្យាបាល និងថែទាំសុខភាព ឆ្នាំ២០១៨)។

➢ មានទឹកស្អាតសម្រាប់អ្នកប្រើប្រាស់សេវាទទួលទាន

- ***សេចក្តីពន្យល់៖*** សំដៅដល់ទឹកសម្រាប់ទទួលទាន ដែលមានគុណភាពត្រឹមត្រូវស្របតាមស្តង់ដាគុណភាពទឹកផឹកជាតិ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ១)ទឹកស្អាតសម្រាប់បុគ្គលិក អ្នកជំងឺ និងភ្ញៀវទទួលទាននៅកន្លែងចុះឈ្មោះដំបូង ២)កន្លែងដាក់ធុងទឹក ឬបំពង់ចម្រោះត្រូវមានភាពស្អាត និងអនាម័យ និង៣)មានកែវប្រើប្រាស់គ្រប់គ្រាន់។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានទឹកស្អាតសម្រាប់បុគ្គលិក អ្នកជំងឺ និងភ្ញៀវទទួលទាននៅកន្លែងចុះឈ្មោះដំបូង |
| ពិន្ទុ ២ | កន្លែងដាក់ធុងទឹក ឬបំពង់ចម្រោះត្រូវមានភាពស្អាត និងអនាម័យ |
| ពិន្ទុ ១ | មានកែវប្រើប្រាស់គ្រប់គ្រាន់ និងមានអនាម័យ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ២.៣ ការលើកកម្ពស់គុណភាពសេវាក្នុងមណ្ឌលសុខភាព (៥០ពិន្ទុ)

### ២.៣.១ ការរក្សាទុកនូវគោលការណ៍ណែនាំ/សេចក្តីណែនាំ (១០ពិន្ទុ)

➢ មានសេចក្តីណែនាំគ្លីនិក និងសេចក្តីណែនាំប្រតិបត្តិស្តីពីសំណុំសកម្មភាពអប្បបរមា

- ***សេចក្តីពន្យល់៖*** សំដៅដល់ "សេចក្តីណែនាំគ្លីនិក និងសេចក្តីណែនាំប្រតិបត្តិស្តីពីសំណុំសកម្មភាពអប្បបរមា" មាននៅមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)សេចក្តីណែនាំគ្លីនិកស្តីពីសំណុំសកម្មភាពអប្បបរមា ឆ្នាំ២០១៨ និងសេចក្តីណែនាំប្រតិបត្តិស្តីពីសំណុំសកម្មភាពអប្បបរមា ឆ្នាំ២០១៨ ២)ការទុកដាក់ត្រឹមត្រូវ និង៣)ភាពងាយស្រួលយកមកប្រើប្រាស់។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មណ្ឌលសុខភាពមានរក្សាទុកសៀវភៅសេចក្តីណែនាំគ្លីនិក ស្តីពីសំណុំសកម្មភាពអប្បបរមា |
| ពិន្ទុ ១ | មណ្ឌលសុខភាពមានរក្សាទុកសៀវភៅសេចក្តីណែនាំប្រតិបត្តិស្តីពីសំណុំសកម្មភាពអប្បបរមា |
| ពិន្ទុ ១ | មានការទុកដាក់បានត្រឹមត្រូវ និងមានសណ្តាប់ធ្នាប់(នៅកន្លែងពិគ្រោះជំងឺក្រៅ) |
| ពិន្ទុ ២ | មានភាពងាយស្រួលយកមកប្រើប្រាស់ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ មានគោលការណ៍ណែនាំស្តីពីទឹកស្អាត និងអនាម័យនៅមូលដ្ឋានព្យាបាល និងថែទាំសុខភាព និង គោលការណ៍ណែនាំស្តីពីការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ

- ***សេចក្តីពន្យល់៖*** សំដៅដល់"គោលការណ៍ណែនាំស្តីពីទឹកស្អាត និងអនាម័យនៅមូលដ្ឋានព្យាបាល និងថែទាំសុខភាព" និង "គោលការណ៍ណែនាំស្តីពីការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ" មាននៅមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)សៀវភៅគោលការណ៍ណែនាំស្តីពីទឹកស្អាតនិងអនាម័យ នៅមូលដ្ឋានព្យាបាល និងថែទាំសុខភាព ឆ្នាំ២០១៨ និងគោលការណ៍ណែនាំស្តីពីការបង្ការនិងការត្រួតពិនិត្យការចម្លងរោគ ឆ្នាំ២០១៧ ២)ការទុកដាក់ត្រឹមត្រូវ និង៣)ភាពងាយស្រួលយកមកប្រើប្រាស់។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មណ្ឌលសុខភាពមានរក្សាទុកសៀវភៅគោលការណ៍ណែនាំស្តីពី ទឹកស្អាតនិងអនាម័យនៅមូលដ្ឋានព្យាបាល និងថែទាំសុខភាព ឆ្នាំ២០១៨ |
| ពិន្ទុ ១ | មណ្ឌលសុខភាពមានរក្សាទុកសៀវភៅគោលការណ៍ណែនាំស្តីពីការបង្ការនិងការត្រួតពិនិត្យការចម្លងរោគ ឆ្នាំ២០១៧ |
| ពិន្ទុ ១ | មានការទុកដាក់បានត្រឹមត្រូវ និងមានសណ្តាប់ធ្នាប់ |
| ពិន្ទុ ២ | មានភាពងាយស្រួលយកមកប្រើប្រាស់ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ២.៣.២ ការលើកកម្ពស់គុណភាពផ្នែកសុខភាពមាតា និងទារក (២៥ពិន្ទុ)

➢ ការពិនិត្យមើលលទ្ធផលនៃការធ្វើតេស្តចំណេះដឹងលើករណីសិក្សាគ្លីនិក(រយៈពេល៣ត្រីមាស)

- ***សេចក្តីពន្យល់៖*** សំដៅដល់ការពិនិត្យមើលចំណេះដឹងរបស់បុគ្គលិកឆ្មបផ្នែកសុខភាពមាតានិងទារកលើករណីសិក្សា គ្លីនិក។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ចំណេះដឹងរបស់បុគ្គលិកឆ្មបផ្នែកសុខភាពមាតានិងទារកលើករណីសិក្សាគ្លីនិក។ ដើម្បីពិនិត្យមើលចំណេះដឹងនេះ គណៈកម្មការវាយតម្លៃត្រូវ ១)មើលតារាងពិន្ទុវាយតម្លៃគុណភាពសេវាសម្រាប់មណ្ឌលសុខភាពនៅត្រង់ផ្នែកទីII ២)បូកពិន្ទុករណីសិក្សាគ្លីនិករបស់បុគ្គលិកឆ្មប២នាក់ ក្នុងរយៈពេល៣ត្រីមាសចុងក្រោយនៃការវាយតម្លៃគុណភាពសេវាសម្រាប់មណ្ឌលសុខភាព។ ពិន្ទុសរុបទាំង៣ត្រីមាសច្រើនបំផុតស្មើ ៦០ពិន្ទុ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | ពិន្ទុទទួលបានចាប់ពី ៥៦ ដល់ ៦០ |
| ពិន្ទុ ៤ | ពិន្ទុទទួលបានចាប់ពី ៥១ ដល់ ៥៥ |

| | |
|---|---|
| ពិន្ទុ ៣ | ពិន្ទុទទួលបានចាប់ពី ៤៦ ដល់ ៥០ |
| ពិន្ទុ ២ | ពិន្ទុទទួលបានចាប់ពី ៤១ ដល់ ៤៥ |
| ពិន្ទុ ១ | ពិន្ទុទទួលបានចាប់ពី ៣៦ ដល់ ៤០ |
| ពិន្ទុ ០ | ពិន្ទុទទួលបានទាបជាង ៣៦ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ប្រសិនបើមណ្ឌលសុខភាពណាទទួលបានពិន្ទុ៥ គណៈកម្មការវាយតម្លៃមានសិទ្ធិក្នុងការពិនិត្យផ្ទៀងផ្ទាត់ដោយជ្រើសរើសបុគ្គលិកម្នាក់ដោយចៃដន្យ ដើម្បីធ្វើករណីសិក្សានេះឡើងវិញ។

➢ <u>ការពិនិត្យមើលលទ្ធផលនៃការធ្វើតេស្តចំណេះដឹងលើការសង្គ្រោះទារក(រយៈពេល៣ត្រីមាស)</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការពិនិត្យមើលចំណេះដឹងរបស់បុគ្គលិកផ្នែកសុខភាពមាតានិងទារកលើការសង្គ្រោះទារក(ណេអូណាតាលី)។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ចំណេះដឹងរបស់បុគ្គលិកផ្នែកសុខភាពមាតានិងទារក លើការសង្គ្រោះទារក(ណេអូណាតាលី)។ ដើម្បីពិនិត្យចំណេះដឹងនេះ គណៈកម្មការវាយតម្លៃត្រូវ ១)មើលតារាងពិន្ទុវាយតម្លៃគុណភាពសេវាសម្រាប់មណ្ឌលសុខភាពនៅត្រង់ផ្នែកទីII ២)បូកពិន្ទុបុគ្គលិកធ្វើតេស្តចំណេះដឹងលើការសង្គ្រោះទារក(ណេអូណាតាលី) ក្នុងរយៈពេល៣ត្រីមាសចុងក្រោយនៃការវាយតម្លៃគុណភាពសេវាសម្រាប់មណ្ឌលសុខភាព។ ពិន្ទុសរុបទាំង៣ត្រីមាសច្រើនបំផុតស្មើ ៦០ពិន្ទុ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | ពិន្ទុទទួលបានចាប់ពី ៥៦ ដល់ ៦០ |
| ពិន្ទុ ៤ | ពិន្ទុទទួលបានចាប់ពី ៥១ ដល់ ៥៥ |
| ពិន្ទុ ៣ | ពិន្ទុទទួលបានចាប់ពី ៤៦ ដល់ ៥០ |
| ពិន្ទុ ២ | ពិន្ទុទទួលបានចាប់ពី ៤១ ដល់ ៤៥ |
| ពិន្ទុ ១ | ពិន្ទុទទួលបានចាប់ពី ៣៦ ដល់ ៤០ |
| ពិន្ទុ ០ | ពិន្ទុទទួលបានទាបជាង ៣៦ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ប្រសិនបើមណ្ឌលសុខភាពណាទទួលបានពិន្ទុ៥ គណៈកម្មការវាយតម្លៃមានសិទ្ធិក្នុងការពិនិត្យផ្ទៀងផ្ទាត់ដោយជ្រើសរើសបុគ្គលិកម្នាក់ដោយចៃដន្យ ដើម្បីធ្វើតេស្តចំណេះដឹងនេះឡើងវិញ។

## ➢ ការពិនិត្យការបំពេញប៉ាតូក្រាហ្វបានត្រឹមត្រូវគ្រប់ចំនួនសម្រាលក្នុងរយៈពេល១ខែនៃត្រីមាសកន្លងមក

- ***សេចក្តីពន្យល់៖*** សំដៅដល់ការពិនិត្យការបំពេញប៉ាតូក្រាហ្វ(Patograph) របស់បុគ្គលិកឆ្មប ដោយបំពេញត្រឹមត្រូវទាំងសងខាង(បំពេញឱ្យបានគ្រប់ចំនុចទាំងអស់ ក្នុងដំណាក់កាលទី១ ដំណាក់កាលទី២ ដំណាក់កាលទី៣ និងដំណាក់កាលទី៤)។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ចំនួនប៉ាតូក្រាហ្វ ២)ទិន្នន័យលើក្តារព័ត៌មាន(ឧ.បើមានករណីសម្រាល១០ត្រូវមានប៉ាតូក្រាហ្វចំនួន១០ដែរ) ៣)ការបំពេញប៉ាតូក្រាហ្វ។ ក្នុងការពិនិត្យមើលប៉ាតូក្រាហ្វនេះ គណៈកម្មការវាយតម្លៃត្រូវជ្រើសរើសឯកសារស្ត្រីសម្រាលក្នុងរយៈពេល១ខែនៃត្រីមាសកន្លងមក។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | ចំនួនប៉ាតូក្រាហ្វដូចគ្នានឹងទិន្នន័យដែលបានកត់ត្រាលើក្តារព័ត៌មាន |
| ពិន្ទុ ៣ | ការបំពេញប៉ាតូក្រាហ្វទាំងអស់ត្រឹមត្រូវគ្រប់ចំណុច |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** បើប៉ាតូក្រាហ្វណាមួយបំពេញមិនគ្រប់ខ្វះចំណុចណាមួយក្នុងដំណាក់កាលណាមួយក៏ដោយ គឺផ្តល់ពិន្ទុ០ នៅត្រង់សូចនាករ "ការបំពេញប៉ាតូក្រាហ្វទាំងអស់ត្រឹមត្រូវគ្រប់ចំណុច"។

## ➢ ការពិនិត្យប័ណ្ណពន្យារកំណើតតាមមធ្យោបាយនីមួយៗ

- ***សេចក្តីពន្យល់៖*** សំដៅដល់ការពិនិត្យប័ណ្ណពន្យារកំណើតតាមមធ្យោបាយនីមួយៗ (ថ្នាំគ្រាប់ពន្យារកំណើត ថ្នាំចាក់ពន្យារកំណើត កងដាក់ក្នុងស្បូន កងដាក់ក្រោមស្បែក ស្រោមអនាម័យ)។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការបំពេញប័ណ្ណពន្យារកំណើតទាំង៥ (ប័ណ្ណថ្នាំគ្រាប់ពន្យារកំណើត ប័ណ្ណថ្នាំចាក់ពន្យារកំណើត ប័ណ្ណកងដាក់ក្នុងស្បូន ប័ណ្ណកងដាក់ក្រោមស្បែក ប័ណ្ណស្រោមអនាម័យ) និង២)ការរក្សាទុកប័ណ្ណពន្យារកំណើតទាំង៥។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ៣ | ការបំពេញប័ណ្ណពន្យារកំណើតទាំង៥ បានត្រឹមត្រូវ |
| ពិន្ទុ ២ | ការរក្សាទុកប័ណ្ណពន្យារកំណើត ក្នុងទូ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ➢ ការអនុវត្តការថែទាំសារវន្តទារកទើបកើត

- ***សេចក្តីពន្យល់៖*** សំដៅដល់ចំណេះដឹងរបស់ឆ្មបទៅលើការថែទាំទារកដែលទើបតែកើតភ្លាមៗ ដោយធ្វើការវាយតម្លៃការយំ/ការដកដង្ហើម និងសកម្មភាពរបស់ទារក។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ចំណេះដឹងក្នុងការអនុវត្តការថែទាំទារកទើបកើត។ ដើម្បីពិនិត្យចំណេះដឹង គណៈកម្មការវាយតម្លៃត្រូវសួរ ឬសម្ភាសន៍ផ្ទាល់ជាមួយឆ្មប។
- ***របៀបនៃការដាក់ពិន្ទុពី០ ឬ៥៖***

| | |
|---|---|
| ពិន្ទុ ៥ | បុគ្គលិកឆ្មបម្នាក់ឆ្លើយត្រឹមត្រូវទាំង១០ចំណុច |
| ពិន្ទុ ០ | បុគ្គលិកឆ្មបរៀបរាប់មិនគ្រប់១០ចំណុច |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ជ្រើសរើសឆ្មបម្នាក់ដើម្បីសាកសួរ។ នៅក្នុងក្បួនខ្នាតនេះ បើខ្វះមួយជំហាន/ចំណុច គឺសូន្យ បើឆ្លើយត្រូវទាំងអស់បាន៥ពិន្ទុ។ បើមណ្ឌលសុខភាពគ្មានឆ្មបផ្តល់ពិន្ទុ០។ ឆ្មបត្រូវរៀបរាប់ចំណុចទាំង១០ ដោយមិនបាច់មើលលើឯកសារណែនាំ។

### ២.៣.៣ ការថែទាំកុមារក្រោម៥ឆ្នាំ(ពិនិត្យប័ណ្ណ ស ព ជ ក) (១០ពិន្ទុ)

➢ <u>ភាគរយកុមារអាយុក្រោម៥ឆ្នាំបានទទួលការពិនិត្យព្យាបាលតាម ស ព ជ ក</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការគិតជាភាគរយកុមារអាយុក្រោម៥ឆ្នាំដែលបានពិនិត្យព្យាបាលតាមសមាហរណកម្មព្យាបាលជំងឺកុមារ(ប័ណ្ណ ស ព ជ ក)។ ប័ណ្ណ ស ព ជ ក គឺជាប័ណ្ណកត់ត្រាការទទួលបន្ទុកពិនិត្យព្យាបាលកុមារឈឺអាយុពី ២ខែ ដល់ក្រោម ៥ឆ្នាំ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ចំនួនប័ណ្ណកត់ត្រាអ្នកជំងឺ ស ព ជ ក ដែលបានបំពេញរួចក្នុងខែកន្លងទៅ និង២)ចំនួនកុមារក្រោម៥ឆ្នាំដែលមកពិគ្រោះជំងឺដែលបានកត់ត្រាក្នុងសៀវភៅបញ្ជីកត់ត្រាក្នុងខែកន្លងទៅ។ ដើម្បីគណនា គណៈកម្មការវាយតម្លៃត្រូវអនុវត្តនៅរូបមន្តដូចខាងក្រោម៖
    a. រាប់ចំនួនប័ណ្ណកត់ត្រាអ្នកជំងឺ ស ព ជ ក ដែលបានបំពេញរួចក្នុងខែកន្លងទៅ
    b. រាប់ចំនួនកុមារក្រោម៥ឆ្នាំដែលមកពិគ្រោះជំងឺដែលបានកត់ត្រាក្នុងសៀវភៅបញ្ជីកត់ត្រាក្នុងខែកន្លងទៅ
    c. បន្ទាប់មកគណនាសមាមាត្រកុមារឈឺ(កុមារក្រោម៥ឆ្នាំ)ដែលបានពិនិត្យព្យាបាលតាម ស ព ជ ក= (a ចែក b)x 100។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | សមាមាត្រកុមារឈឺ(កុមារក្រោម៥ឆ្នាំ)ដែលបានពិនិត្យព្យាបាលតាម ស ព ជ ក = ១០០ភាគរយ |
| ពិន្ទុ ៤ | សមាមាត្រកុមារឈឺកុមារក្រោម៥ឆ្នាំដែលបានពិនិត្យព្យាបាលតាម ស ព ជ ក = ៨០ភាគរយ-៩៩ភាគរយ |
| ពិន្ទុ ៣ | សមាមាត្រកុមារឈឺកុមារក្រោម៥ឆ្នាំដែលបានពិនិត្យព្យាបាលតាម ស ព ជ ក = ៦០ភាគរយ-៧៩ភាគរយ |

| | |
|---|---|
| ពិន្ទុ ២ | សមាមាត្រកុមារឈឺកុមារក្រោម៥ឆ្នាំដែលបានពិនិត្យព្យាបាលតាម ស ព ជ ក = ៤០ភាគរយ-៥៩ភាគរយ |
| ពិន្ទុ ១ | សមាមាត្រកុមារឈឺកុមារក្រោម៥ឆ្នាំដែលបានពិនិត្យព្យាបាលតាម ស ព ជ ក = ១០ភាគរយ-៣៩ភាគរយ |
| ពិន្ទុ ០ | សមាមាត្រកុមារឈឺកុមារក្រោម៥ឆ្នាំដែលបានពិនិត្យព្យាបាលតាម ស ព ជ ក ត្រឹមត្រូវតិចជាង ១០ភាគរយ |

➢ ការបំពេញប័ណ្ណ ស ព ជ ក ត្រឹមត្រូវនៅពេលពិនិត្យជំងឺកុមារ

- ***សេចក្តីពន្យល់៖*** សំដៅដល់ការបំពេញប័ណ្ណ ស. ព. ជ. ក( សមាហរណកម្មព្យាបាលជំងឺកុមារ ) នៅពេលកុមារមកពិនិត្យព្យាបាលនៅមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ការបំពេញប័ណ្ណស.ព.ជ.ក។ គណៈកម្មការវាយតម្លៃត្រូវពិនិត្យមើលប័ណ្ណស.ព.ជ.ក ទាំងអស់ ថាតើការបំពេញប័ណ្ណបានត្រឹមត្រូវ ឬទេ ក្នុងរយៈពេល១ខែកន្លងទៅ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | ការបំពេញប័ណ្ណបានត្រឹមត្រូវទាំងអស់១០០ភាគរយ |
| ពិន្ទុ ៤ | ការបំពេញប័ណ្ណបានត្រឹមត្រូវ ៨០ភាគរយ-៩៩ភាគរយ |
| ពិន្ទុ ៣ | ការបំពេញប័ណ្ណបានត្រឹមត្រូវ ៦០ភាគរយ-៧៩ភាគរយ |
| ពិន្ទុ ២ | ការបំពេញប័ណ្ណបានត្រឹមត្រូវ ៤០ភាគរយ-៥៩ភាគរយ |
| ពិន្ទុ ១ | ការបំពេញប័ណ្ណបានត្រឹមត្រូវ ១០ភាគរយ-៣៩ភាគរយ |
| ពិន្ទុ ០ | ការបំពេញប័ណ្ណបានត្រឹមត្រូវតិចជាង ១០ភាគរយ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** សូមផ្ទៀងផ្ទាត់ជាមួយ **លក្ខណៈវិនិច្ឆ័យលម្អិតខាងលើ** "ភាគរយកុមារអាយុក្រោម៥ឆ្នាំបានទទួលការពិនិត្យព្យាបាលតាម ស ព ជ ក"។ បើសិនជាការគណនាសមាមាត្រកុមារឈឺ( កុមារក្រោម៥ឆ្នាំ ) ដែលបានពិនិត្យព្យាបាលតាម ស ព ជ ក បានតិចជាង ឬស្មើ ៥០ភាគរយ ដូច្នេះសូមផ្តល់ពិន្ទុសូន្យចំពោះលក្ខណៈវិនិច្ឆ័យលម្អិតនេះ។

### ២.៣.៤ គុណភាពផ្នែកពិនិត្យជំងឺក្រៅ ( ៥ពិន្ទុ )

➢ ការពិនិត្យមើលលទ្ធផលនៃការធ្វើតេស្តចំណេះដឹងលើករណីសិក្សាគ្លីនិក(រយៈពេល៣ត្រីមាស )

- ***សេចក្តីពន្យល់៖*** សំដៅដល់ការពិនិត្យមើលចំណេះដឹងរបស់បុគ្គលិកផ្នែកពិនិត្យជំងឺក្រៅ លើករណីសិក្សាគ្លីនិក។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ចំណេះដឹងរបស់បុគ្គលិកផ្នែកពិនិត្យជំងឺក្រៅ លើករណីសិក្សាគ្លីនិក។ ដើម្បីពិនិត្យមើលចំណេះដឹងនេះ គណៈកម្មការវាយតម្លៃត្រូវ ១)មើលតារាងពិន្ទុវាយតម្លៃគុណភាពសេវាសម្រាប់មណ្ឌលសុខភាពនៅត្រង់ផ្នែកទីII ២)បូកពិន្ទុករណីសិក្សាគ្លីនិក របស់បុគ្គលិកពិនិត្យជំងឺក្រៅ ២នាក់ ក្នុងរយៈពេល៣ត្រីមាសចុងក្រោយនៃការវាយតម្លៃគុណភាពសេវាសម្រាប់មណ្ឌលសុខភាព។ ពិន្ទុសរុបទាំង៣ត្រីមាសច្រើនបំផុតស្មើ ៦០ពិន្ទុ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | ពិន្ទុទទួលបានចាប់ពី ៥៦ ដល់ ៦០ |
| ពិន្ទុ ៤ | ពិន្ទុទទួលបានចាប់ពី ៥១ ដល់ ៥៥ |
| ពិន្ទុ ៣ | ពិន្ទុទទួលបានចាប់ពី ៤៦ ដល់ ៥០ |
| ពិន្ទុ ២ | ពិន្ទុទទួលបានចាប់ពី ៤១ ដល់ ៤៥ |
| ពិន្ទុ ១ | ពិន្ទុទទួលបានចាប់ពី ៣៦ ដល់ ៤០ |
| ពិន្ទុ ០ | ពិន្ទុទទួលបានទាបជាង ៣៦ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ប្រសិនបើមណ្ឌលសុខភាពណាទទួលបានពិន្ទុ៥ គណៈកម្មការវាយតម្លៃមានសិទ្ធិក្នុងការពិនិត្យផ្ទៀងផ្ទាត់ដោយជ្រើសរើសបុគ្គលិកផ្នែកពិនិត្យជំងឺក្រៅ ១នាក់ដោយចៃដន្យ ដើម្បីធ្វើករណីសិក្សានេះឡើងវិញ។

## ២.៤ លទ្ធផលនៃការអនុវត្តការលើកកម្ពស់គុណភាពសេវាក្នុងមណ្ឌលសុខភាព (៧៥ពិន្ទុ)

### ២.៤.១ សមិទ្ធផលនៃការផ្តល់សេវាទូទៅ (១៥ពិន្ទុ)

➢ <u>ចំនួនករណីពិគ្រោះជំងឺថ្មីសម្រាប់ប្រជាជនម្នាក់ក្នុងមួយឆ្នាំ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ចំនួនករណីថ្មី ដែលមកពិគ្រោះជំងឺជាមធ្យមនៃប្រជាជនម្នាក់ក្នុង១ឆ្នាំ នៅមណ្ឌលសុខភាព ក្នុងចំណោមប្រជាជនដែលគ្របដណ្តប់ដោយមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ របាយការណ៍ពិនិត្យលទ្ធផលប្រចាំឆ្នាំរបស់មណ្ឌលសុខភាព។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | លទ្ធផលនៃសូចនាករសម្រេចបាន ១០០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៤ | លទ្ធផលនៃសូចនាករសម្រេចបានត្រឹម ៩៥ភាគរយឡើងទៅ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |

| | |
|---|---|
| ពិន្ទុ ៣ | លទ្ធផលនៃសូចនាករសម្រេចបានត្រឹម ៩០ភាគរយឡើងទៅ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ២ | លទ្ធផលនៃសូចនាករសម្រេចបានត្រឹម ៨៥ភាគរយឡើងទៅ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ១ | លទ្ធផលនៃសូចនាករសម្រេចបានត្រឹម ៨០ភាគរយឡើងទៅ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ០ | លទ្ធផលនៃសូចនាករសម្រេចបានតិចជាង ៨០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ទិន្នន័យយកមកផ្ទៀងផ្ទាត់ ជាទិន្នន័យមានសង្គតិភាពរវាងទិន្នន័យផ្តល់ដោយមណ្ឌលសុខភាព និងទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាសុខាភិបាលតាមគេហទំព័រ។ ក្នុងករណីមិនត្រូវគ្នាត្រូវដក២ពិន្ទុពីលើចំណុចខាងលើ និងយកទិន្នន័យដែលទាបមកគណនា។

## ➢ ចំនួនករណីពិនិត្យពិគ្រោះជំងឺសរុប

- ***សេចក្តីពន្យល់៖*** សំដៅដល់ចំនួនសរុបនៃចំនួនករណីពិគ្រោះជំងឺថ្មី និងចំនួនករណីពិគ្រោះជំងឺចាស់នៅក្នុងមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ របាយការណ៍ពិនិត្យលទ្ធផលប្រចាំឆ្នាំ ឬទិន្នន័យក្នុងរបាយការណ៍ HC1 ប្រចាំឆ្នាំរបស់មណ្ឌលសុខភាព។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | ចំនួនករណីពិគ្រោះជំងឺក្រៅសរុប ត្រូវមានតួលេខតែមួយជាមួយទិន្នន័យបានមកពីការបូកសរុបប្រចាំខែទាំង១២ខែក្នុងឆ្នាំ នៃបញ្ជីកត់ត្រាអ្នកជំងឺក្រៅ និងដូចគ្នាជាមួយទិន្នន័យទាញចេញពីប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល |
| ពិន្ទុ ៤ | ចំនួនករណីពិគ្រោះជំងឺក្រៅសរុប មានតួលេខខុសគ្នាជាមួយទិន្នន័យបានមកពីការបូកសរុបប្រចាំខែទាំង១២ខែក្នុងឆ្នាំ នៃបញ្ជីកត់ត្រាអ្នកជំងឺក្រៅ១ភាគរយ និងដូចគ្នាជាមួយទិន្នន័យទាញចេញពីប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល |
| ពិន្ទុ ៣ | ចំនួនករណីពិគ្រោះជំងឺក្រៅសរុប មានតួលេខខុសគ្នាជាមួយទិន្នន័យបានមកពីការបូកសរុបប្រចាំខែទាំង១២ខែក្នុងឆ្នាំ នៃបញ្ជីកត់ត្រាអ្នកជំងឺក្រៅ១ភាគរយ និងខុសគ្នាជាមួយទិន្នន័យទាញចេញពីប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល១ភាគរយ |

| | |
|---|---|
| ពិន្ទុ ២ | ចំនួនករណីពិគ្រោះជំងឺក្រៅសរុប មានតួលេខខុសគ្នាជាមួយទិន្នន័យបានមកពីការបូកសរុបប្រចាំខែទាំង១២ខែក្នុងឆ្នាំ នៃបញ្ជីកត់ត្រាអ្នកជំងឺក្រៅ២ភាគរយ និងខុសគ្នាជាមួយទិន្នន័យទាញចេញពីប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល១ភាគរយ |
| ពិន្ទុ ១ | ចំនួនករណីពិគ្រោះជំងឺក្រៅសរុប មានតួលេខខុសគ្នាជាមួយទិន្នន័យបានមកពីការបូកសរុបប្រចាំខែទាំង១២ខែក្នុងឆ្នាំ នៃបញ្ជីកត់ត្រាអ្នកជំងឺក្រៅ២ភាគរយ និងខុសគ្នាជាមួយទិន្នន័យទាញចេញពីប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល២ភាគរយ |
| ពិន្ទុ ០ | ចំនួនករណីពិគ្រោះជំងឺក្រៅសរុប មានតួលេខខុសគ្នាជាមួយទិន្នន័យបានមកពីការបូកសរុបប្រចាំខែទាំង១២ខែក្នុងឆ្នាំ នៃបញ្ជីកត់ត្រាអ្នកជំងឺក្រៅលើសពី២ភាគរយទៅ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** បូកសរុបទិន្នន័យក្នុងបញ្ជីកត់ត្រាអ្នកជំងឺក្រៅ រយៈពេល១ឆ្នាំ ផ្ទៀងផ្ទាត់ជាមួយរបាយការណ៍សមិទ្ធផលមណ្ឌលសុខភាពប្រចាំឆ្នាំ និងទិន្នន័យទាញចេញពីប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល។ ទិន្នន័យទាំងបីនេះ ត្រូវតែដូចគ្នា។

## ➢ ការពង្រឹងការបញ្ជូនជំងឺទៅមន្ទីរពេទ្យបង្អែក

- ***សេចក្តីពន្យល់៖*** សំដៅដល់ដំណើរការបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យបង្អែក ដើម្បីពិនិត្យព្យាបាលបន្តឱ្យមានប្រសិទ្ធភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍ពិនិត្យលទ្ធផលប្រចាំឆ្នាំរបស់មណ្ឌលសុខភាព ២)លិខិតបញ្ជូនជំងឺទៅមន្ទីរពេទ្យបង្អែក និង៣)របាយការណ៍បញ្ជូនជំងឺ (គំរូលិខិតនៅជំពូកឧបសម្ព័ន្ធក្នុងសេចក្តីណែនាំប្រតិបត្តិស្តីពីសំណុំសកម្មភាពអប្បបរមា)។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | ចំនួនករណីបញ្ជូនក្នុងរបាយការណ៍សមិទ្ធផលប្រចាំឆ្នាំ ស្មើនឹងចំនួនលិខិតបញ្ជូន និងស្មើនឹងចំនួនរបាយការណ៍បញ្ជូន ក្នុងរយៈពេលដូចគ្នា |
| ពិន្ទុ ៤ | ចំនួនករណីបញ្ជូនក្នុងរបាយការណ៍សមិទ្ធផលប្រចាំឆ្នាំ ខុសគ្នានឹងចំនួនលិខិតបញ្ជូន ឬចំនួនរបាយការណ៍បញ្ជូន(ក្នុងរង្វង់៥ភាគរយចុះ) ក្នុងរយៈពេលដូចគ្នា |
| ពិន្ទុ ៣ | ចំនួនករណីបញ្ជូនក្នុងរបាយការណ៍សមិទ្ធផលប្រចាំឆ្នាំ ខុសគ្នានឹងចំនួនលិខិតបញ្ជូន ឬចំនួនរបាយការណ៍បញ្ជូន(ក្នុងរង្វង់ពី៦ ទៅ១០ភាគរយ) ក្នុងរយៈពេលដូចគ្នា |
| ពិន្ទុ ២ | ចំនួនករណីបញ្ជូនក្នុងរបាយការណ៍សមិទ្ធផលប្រចាំឆ្នាំ ខុសគ្នានឹងចំនួនលិខិតបញ្ជូន ឬចំនួនរបាយការណ៍បញ្ជូន(ក្នុងរង្វង់ពី១១ ទៅ១៥ភាគរយ) ក្នុងរយៈពេលដូចគ្នា |
| ពិន្ទុ ១ | ចំនួនករណីបញ្ជូនក្នុងរបាយការណ៍សមិទ្ធផលប្រចាំឆ្នាំ ខុសគ្នានឹងចំនួនលិខិតបញ្ជូន ឬចំនួនរបាយការណ៍បញ្ជូន(ក្នុងរង្វង់ពី១៦ ទៅ២០ភាគរយ) ក្នុងរយៈពេលដូចគ្នា |
| ពិន្ទុ ០ | ចំនួនករណីបញ្ជូនក្នុងរបាយការណ៍សមិទ្ធផលប្រចាំឆ្នាំ ខុសគ្នានឹងចំនួនលិខិតបញ្ជូន ឬចំនួនរបាយការណ៍បញ្ជូន(ចាប់ពី២០ភាគរយឡើងទៅ) ក្នុងរយៈពេលដូចគ្នា |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** បុគ្គលិកមណ្ឌលសុខភាពត្រូវបំពេញលិខិតបញ្ជូនជំងឺ ឬរបាយការណ៍បញ្ជូនជំងឺចំពោះគ្រប់ករណីបញ្ជូន ដោយបញ្ជាក់នូវព័ត៌មានច្បាស់លាស់ក្នុងនោះមានការសន្និដ្ឋានរោគឬសង្ស័យ និងឱសថដែលបានផ្តល់។ ដូចនេះលិខិតបញ្ជូនជំងឺ ឬរបាយការណ៍បញ្ជូនជំងឺ ដែលត្រូវយកមកផ្ទៀងផ្ទាត់ត្រូវតែបានបំពេញពេញលេញ និងត្រឹមត្រូវ។ ក្នុងករណីចំនួនលិខិតបញ្ជូនជំងឺ និងរបាយការណ៍បញ្ជូនជំងឺមិនស្មើគ្នា ត្រូវដក២ពិន្ទុបន្ថែមលើល័ក្ខខ័ណ្ឌខាងលើ។

### ២.៤.២ សមិទ្ធផលនៃការផ្តល់សេវាផ្នែកកុមារ (៣០ពិន្ទុ)

➢ <u>ចំនួនលើក/ដងនៃការពិគ្រោះជំងឺក្រៅករណីថ្មីលើកុមារអាយុក្រោម៥ឆ្នាំ ម្នាក់ក្នុងមួយឆ្នាំ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការពិគ្រោះជំងឺក្រៅករណីថ្មីលើកុមារអាយុក្រោម៥ឆ្នាំ ជាមធ្យមម្នាក់ក្នុងមួយឆ្នាំ នៅមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ របាយការណ៍ពិនិត្យលទ្ធផលប្រចាំឆ្នាំរបស់មណ្ឌលសុខភាពធៀបជាមួយគោលដៅចំណុចថ្នាក់ជាតិ។ ទិន្នន័យយកមកពិនិត្យត្រូវគិត រយៈពេល ១ឆ្នាំពេញ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | លទ្ធផលនៃសូចនាករសម្រេចបាន ១០០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៤ | លទ្ធផលនៃសូចនាករសម្រេចបានត្រឹម៩៥ ដល់៩៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៣ | លទ្ធផលនៃសូចនាករសម្រេចបានត្រឹម៩០ ដល់៩៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ២ | លទ្ធផលនៃសូចនាករសម្រេចបានត្រឹម៨៥ ដល់៨៩ភាគរយនៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ១ | លទ្ធផលនៃសូចនាករសម្រេចបានត្រឹម៨០ ដល់៨៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ០ | លទ្ធផលនៃសូចនាករសម្រេចបានតិចជាង ៨០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ទិន្នន័យយកមកផ្ទៀងផ្ទាត់ ជាទិន្នន័យមានសង្គតិភាពរវាងទិន្នន័យផ្តល់ដោយមណ្ឌលសុខភាព និងទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល។ ក្នុងករណីមិនត្រូវគ្នា ត្រូវដក២ពិន្ទុពីលើចំណុចខាងលើ និងយកទិន្នន័យដែលទាបមកគណនា។

➢ <u>អត្រាគ្របដណ្តប់នៃវ៉ាក់សាំងបង្ការជំងឺខាន់ស្លាក់-ក្អកមាន់-តេតាណូស-រលាកថ្លើមប្រភេទបេ-រលាកសួត-រលាកស្រោមខួរ ៣ដូស</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់អត្រាកុមារក្រោម១ឆ្នាំដែលបានទទួលវ៉ាក់សាំង៣ដូស បង្ការជំងឺខាន់ស្លាក់-ក្អកមាន់-តេតាណូស-រលាកថ្លើមប្រភេទបេ-រលាកសួត-រលាកស្រោមខួរ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ របាយការណ៍លទ្ធផលប្រចាំឆ្នាំរបស់មណ្ឌលសុខភាពធៀបជាមួយគោលដៅចំណុចថ្នាក់ជាតិ។ ទិន្នន័យយកមកពិនិត្យត្រូវគិតរយៈពេល១ឆ្នាំពេញ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | លទ្ធផលនៃសូចនាករសម្រេចបាន ១០០ភាគរយនៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៤ | លទ្ធផលនៃសូចនាករសម្រេចបានពី៩៥ ដល់៩៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៣ | លទ្ធផលនៃសូចនាករសម្រេចបានពី៩០ ដល់៩៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ២ | លទ្ធផលនៃសូចនាករសម្រេចបានពី៨៥ ដល់៨៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ១ | លទ្ធផលនៃសូចនាករសម្រេចបានពី៨០ ដល់៨៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ០ | លទ្ធផលនៃសូចនាករសម្រេចបានតិចជាង ៨០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ទិន្នន័យយកមកផ្ទៀងផ្ទាត់ ជាទិន្នន័យមានសង្គតិភាពរវាងទិន្នន័យដែលផ្ដល់ដោយមណ្ឌលសុខភាព និងទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល។ ក្នុងករណីដែលទិន្នន័យមិនត្រូវគ្នា ត្រូវយកទិន្នន័យដែលទាបបំផុតមកគណនា រួចត្រូវដក២ពិន្ទុ។

➢ អត្រាគ្របដណ្ដប់នៃវ៉ាក់សាំងបង្ការកញ្ជ្រឹល-ស្អូច នៅខែទី៩

- ***សេចក្ដីពន្យល់៖*** សំដៅដល់អត្រាកុមារក្រោម១ឆ្នាំដែលបានទទួលវ៉ាក់សាំងបង្ការជំងឺកញ្ជ្រឹល-ស្អូច នៅខែទី៩។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ របាយការណ៍លទ្ធផលប្រចាំឆ្នាំរបស់មណ្ឌលសុខភាពធៀបជាមួយគោលដៅចំណុចថ្នាក់ជាតិ។ ទិន្នន័យយកមកពិនិត្យត្រូវគិតរយៈពេល ១ឆ្នាំពេញ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | លទ្ធផលនៃសូចនាករសម្រេចបាន ១០០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៤ | លទ្ធផលនៃសូចនាករសម្រេចបានពី៩៥ ដល់៩៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៣ | លទ្ធផលនៃសូចនាករសម្រេចបានពី៩០ ដល់៩៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ២ | លទ្ធផលនៃសូចនាករសម្រេចបានពី៨៥ ដល់៨៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ១ | លទ្ធផលនៃសូចនាករសម្រេចបានពី៨០ ដល់៨៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ០ | លទ្ធផលនៃសូចនាករសម្រេចបានតិចជាង ៨០ភាគរយនៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ទិន្នន័យយកមកផ្ទៀងផ្ទាត់ ជាទិន្នន័យមានសង្គតិភាពរវាងទិន្នន័យដែលផ្ដល់ដោយមណ្ឌលសុខភាព និងទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល។ ក្នុងករណីដែលទិន្នន័យមិនត្រូវគ្នា ត្រូវយកទិន្នន័យដែលទាបបំផុតមកគណនា រួចត្រូវដក២ពិន្ទុ។

- ភាគរយនៃទារកបានទទួលការបំបៅដោយទឹកដោះម្តាយក្នុងអំឡុងមួយម៉ោងដំបូងនៃកំណើត

- ***សេចក្តីពន្យល់៖*** សំដៅដល់អត្រាកុមារអាយុក្រោម២៤ខែ ដែលបានទទួលការការបំបៅដោយទឹកដោះម្តាយ ក្នុងអំឡុងម៉ោងទីមួយនៃកំណើត។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ របាយការណ៍លទ្ធផលប្រចាំឆ្នាំរបស់មណ្ឌលសុខភាពធៀបជាមួយគោលដៅចំណុចថ្នាក់ជាតិ។ ទិន្នន័យយកមកពិនិត្យត្រូវគិតរយៈពេល ១ឆ្នាំពេញ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | លទ្ធផលនៃសូចនាករសម្រេចបាន ១០០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៤ | លទ្ធផលនៃសូចនាករសម្រេចបានពី៩៥ ដល់៩៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៣ | លទ្ធផលនៃសូចនាករសម្រេចបានពី៩០ ដល់៩៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ២ | លទ្ធផលនៃសូចនាករសម្រេចបានពី៨៥ ដល់៨៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ១ | លទ្ធផលនៃសូចនាករសម្រេចបានពី៨០ ដល់៨៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ០ | លទ្ធផលនៃសូចនាករសម្រេចបានតិចជាង ៨០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ទិន្នន័យយកមកផ្ទៀងផ្ទាត់ ជាទិន្នន័យមានសង្គតិភាពរវាងទិន្នន័យដែលផ្តល់ដោយមណ្ឌលសុខភាព និងទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល។ ក្នុងករណីដែលទិន្នន័យមិនត្រូវគ្នា ត្រូវយកទិន្នន័យដែលទាបបំផុតមកគណនា រួចត្រូវដក២ពិន្ទុ។

- **ភាគរយនៃកុមារអាយុពី៦ខែទៅ៥៩ខែ បានទទួលគ្រាប់ថ្នាំជីវជាតិអាក្នុងអំឡុងពេល៦ខែចុងក្រោយនៃឆ្នាំ**
  - ***សេចក្តីពន្យល់៖*** សំដៅដល់អត្រាកុមារអាយុ ៦-៥៩ ខែ បានទទួលគ្រាប់ថ្នាំជីវជាតិអា ក្នុងរយៈពេល ៦ខែចុងក្រោយ។
  - ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ របាយការណ៍លទ្ធផលប្រចាំឆ្នាំរបស់មណ្ឌលសុខភាពធៀបជាមួយគោលដៅចំណុចថ្នាក់ជាតិ។ ទិន្នន័យយកមកពិនិត្យត្រូវគិតរយៈពេល ៦ខែចុងក្រោយនៃឆ្នាំ។
  - ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | លទ្ធផលនៃសូចនាករសម្រេចបាន ១០០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៤ | លទ្ធផលនៃសូចនាករសម្រេចបានពី៩៥ ដល់៩៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៣ | លទ្ធផលនៃសូចនាករសម្រេចបានពី៩០ ដល់៩៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ២ | លទ្ធផលនៃសូចនាករសម្រេចបានពី៨៥ ដល់៨៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ១ | លទ្ធផលនៃសូចនាករសម្រេចបានពី៨០ ដល់៨៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ០ | លទ្ធផលនៃសូចនាករសម្រេចបានតិចជាង ៨០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |

  - ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ទិន្នន័យយកមកផ្ទៀងផ្ទាត់ ជាទិន្នន័យមានសង្គតិភាពរវាងទិន្នន័យដែលផ្តល់ដោយមណ្ឌលសុខភាព និងទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល។ ក្នុងករណីដែលទិន្នន័យមិនត្រូវគ្នា ត្រូវយកទិន្នន័យដែលទាបបំផុតមកគណនា រួចត្រូវដក២ពិន្ទុ។

➢ ភាគរយនៃកុមារអាយុពី១២ខែដល់៥៩ខែ បានទទួលថ្នាំម៉េបង់ដាហ្សុលក្នុងអំឡុងពេល៦ខែចុងក្រោយនៃឆ្នាំ

- ***សេចក្តីពន្យល់៖*** សំដៅដល់អត្រាកុមារអាយុ១២-៥៩ ខែ បានទទួលថ្នាំទំលាក់ព្រូន មេបង់ដាហ្សុលក្នុងរយៈពេល ៦ខែចុងក្រោយ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ របាយការណ៍លទ្ធផលប្រចាំឆ្នាំរបស់មណ្ឌលសុខភាពធៀបជាមួយគោលដៅចំណុចថ្នាក់ជាតិ។ ទិន្នន័យយកមកពិនិត្យត្រូវគិតរយៈពេល ៦ខែចុងក្រោយនៃឆ្នាំ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | លទ្ធផលនៃសូចនាករសម្រេចបាន ១០០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៤ | លទ្ធផលនៃសូចនាករសម្រេចបានពី៩៥ ដល់៩៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៣ | លទ្ធផលនៃសូចនាករសម្រេចបានពី៩០ ដល់៩៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ២ | លទ្ធផលនៃសូចនាករសម្រេចបានពី៨៥ ដល់៨៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ១ | លទ្ធផលនៃសូចនាករសម្រេចបានពី៨០ ដល់៨៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ០ | លទ្ធផលនៃសូចនាករសម្រេចបានតិចជាង ៨០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ទិន្នន័យយកមកផ្ទៀងផ្ទាត់ ជាទិន្នន័យមានសង្គតិភាពរវាងទិន្នន័យដែលផ្តល់ដោយមណ្ឌលសុខភាព និងទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល។ ក្នុងករណីដែលទិន្នន័យមិន ត្រូវគ្នាត្រូវយកទិន្នន័យដែលទាបបំផុតមកគណនា រួចត្រូវដក២ពិន្ទុ។

### ២.៤.៣ សមិទ្ធផលនៃការផ្តល់សេវាសុខភាពមាតា (៣០ពិន្ទុ)

➢ <u>ភាគរយនៃការប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើបក្នុងចំណោមស្ត្រីរៀបការ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់អត្រានៃការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតទំនើប ក្នុងចំណោមស្ត្រីរៀបការរួចក្នុងតំបន់គ្របដណ្តប់របស់មណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ របាយការណ៍លទ្ធផលប្រចាំឆ្នាំរបស់មណ្ឌលសុខភាពធៀបគោលដៅចំណុចថ្នាក់ជាតិ។ ទិន្នន័យយកមកពិនិត្យត្រូវគិតប្រចាំឆ្នាំ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | លទ្ធផលនៃសូចនាករសម្រេចបាន ១០០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៤ | លទ្ធផលនៃសូចនាករសម្រេចបានពី៩៥ ដល់៩៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៣ | លទ្ធផលនៃសូចនាករសម្រេចបានពី៩០ ដល់៩៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ២ | លទ្ធផលនៃសូចនាករសម្រេចបានពី៨៥ ដល់៨៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ១ | លទ្ធផលនៃសូចនាករសម្រេចបានពី៨០ ដល់៨៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ០ | លទ្ធផលនៃសូចនាករសម្រេចបានតិចជាង ៨០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ទិន្នន័យយកមកផ្ទៀងផ្ទាត់ ជាទិន្នន័យមានសង្គតិភាពរវាងទិន្នន័យដែលផ្តល់ដោយមណ្ឌលសុខភាព និងទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល។ ក្នុងករណីដែលទិន្នន័យមិនត្រូវគ្នា ត្រូវយកទិន្នន័យដែលទាបបំផុតមកគណនា រួចត្រូវដក២ពិន្ទុ។

➢ ភាគរយនៃស្ត្រីដែលមានគភ៌បានទទួលការថែទាំមុនសម្រាល៤លើក ដោយបុគ្គលិកសុខាភិបាល

- ***សេចក្តីពន្យល់៖*** សំដៅដល់អត្រាស្ត្រីកំពុងមានគភ៌បានប្រើប្រាស់ និងទទួលសេវាថែទាំមុនសម្រាលយ៉ាងតិច៤លើក ដោយបុគ្គលិកសុខាភិបាល។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ របាយការណ៍លទ្ធផលប្រចាំឆ្នាំរបស់មណ្ឌលសុខភាពធៀបគោលដៅចំណុចថ្នាក់ជាតិ។ ទិន្នន័យយកមកពិនិត្យត្រូវគិតប្រចាំឆ្នាំ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | លទ្ធផលនៃសូចនាករសម្រេចបាន ១០០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៤ | លទ្ធផលនៃសូចនាករសម្រេចបានពី៩៥ ដល់៩៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៣ | លទ្ធផលនៃសូចនាករសម្រេចបានពី៩០ ដល់៩៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ២ | លទ្ធផលនៃសូចនាករសម្រេចបានពី៨៥ ដល់៨៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ១ | លទ្ធផលនៃសូចនាករសម្រេចបានពី៨០ ដល់៨៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ០ | លទ្ធផលនៃសូចនាករសម្រេចបានតិចជាង ៨០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ទិន្នន័យយកមកផ្ទៀងផ្ទាត់ ជាទិន្នន័យមានសង្គតិភាពរវាងទិន្នន័យដែលផ្តល់ដោយមណ្ឌលសុខភាព និងទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល។ ក្នុងករណីដែលទិន្នន័យមិនត្រូវគ្នា ត្រូវយកទិន្នន័យដែលទាបបំផុតមកគណនា រួចត្រូវដក២ពិន្ទុ។

➢ ភាគរយស្ត្រីមានគភ៌ទទួលថ្នាំគ្រាប់ជាតិដែក/អាស៊ីតហ្វូលិក៩០គ្រាប់

- ***សេចក្តីពន្យល់៖*** សំដៅដល់អត្រាស្ត្រីមានគភ៌ ដែលបានទទួលថ្នាំគ្រាប់ជាតិដែក/អាស៊ីតហ្វូលិក៩០ គ្រាប់ក្នុងរយៈពេលមានគភ៌។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ របាយការណ៍លទ្ធផលប្រចាំឆ្នាំរបស់មណ្ឌលសុខភាពធៀបគោលដៅចំណុចថ្នាក់ជាតិ។ ទិន្នន័យយកមកពិនិត្យត្រូវគិតប្រចាំឆ្នាំ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | លទ្ធផលនៃសូចនាករសម្រេចបាន ១០០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៤ | លទ្ធផលនៃសូចនាករសម្រេចបានពី៩៥ ដល់៩៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៣ | លទ្ធផលនៃសូចនាករសម្រេចបានពី៩០ ដល់៩៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ២ | លទ្ធផលនៃសូចនាករសម្រេចបានពី៨៥ ដល់៨៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ១ | លទ្ធផលនៃសូចនាករសម្រេចបានពី៨០ ដល់៨៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ០ | លទ្ធផលនៃសូចនាករសម្រេចបានតិចជាង ៨០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ទិន្នន័យយកមកផ្ទៀងផ្ទាត់ ជាទិន្នន័យមានសង្គតិភាពរវាងទិន្នន័យដែលផ្តល់ដោយមណ្ឌលសុខភាព និងទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល។ ក្នុងករណីដែលទិន្នន័យមិនត្រូវគ្នា ត្រូវយកទិន្នន័យដែលទាបបំផុតមកគណនា រួចត្រូវដក២ពិន្ទុ។

## ➢ ភាគរយនៃការសម្រាលនៅមូលដ្ឋានសុខាភិបាល

- ***សេចក្ដីពន្យល់៖*** សំដៅដល់អត្រានៃការសម្រាលនៅមណ្ឌលសុខភាព/មូលដ្ឋានសុខាភិបាល។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ របាយការណ៍លទ្ធផលប្រចាំឆ្នាំរបស់មណ្ឌលសុខភាពធៀបគោលដៅចំណុចថ្នាក់ជាតិ។ ទិន្នន័យយកមកពិនិត្យត្រូវគិតប្រចាំឆ្នាំ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | លទ្ធផលនៃសូចនាករសម្រេចបាន ១០០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៤ | លទ្ធផលនៃសូចនាករសម្រេចបានពី៩៥ ដល់៩៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៣ | លទ្ធផលនៃសូចនាករសម្រេចបានពី៩០ ដល់៩៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ២ | លទ្ធផលនៃសូចនាករសម្រេចបានពី៨៥ ដល់៨៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ១ | លទ្ធផលនៃសូចនាករសម្រេចបានពី៨០ ដល់៨៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ០ | លទ្ធផលនៃសូចនាករសម្រេចបានតិចជាង ៨០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ទិន្នន័យយកមកផ្ទៀងផ្ទាត់ ជាទិន្នន័យមានសង្គតិភាពរវាងទិន្នន័យដែលផ្ដល់ដោយមណ្ឌលសុខភាព និងទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល។ ក្នុងករណីដែលទិន្នន័យមិនត្រូវគ្នា ត្រូវយកទិន្នន័យដែលទាបបំផុតមកគណនា រួចត្រូវដក២ពិន្ទុ។

➢ ភាគរយនៃស្ត្រីសម្រាលទទួលការពិនិត្យថៃទាំក្រោយសម្រាលលើកទី១(មុន៤៨ម៉ោងក្រោយសម្រាល) ដោយបុគ្គលិកសុខាភិបាល

- ***សេចក្តីពន្យល់៖*** សំដៅដល់អត្រានៃស្ត្រីសម្រាលដែលទទួលបានការពិនិត្យថៃទាំក្រោយសម្រាលលើកទី១(ក្នុងអំឡុងពេល៤៨ម៉ោងក្រោយសម្រាល) ដោយបុគ្គលិកមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ របាយការណ៍លទ្ធផលប្រចាំឆ្នាំរបស់មណ្ឌលសុខភាពធៀបគោលដៅចំណុចថ្នាក់ជាតិ។ ទិន្នន័យយកមកពិនិត្យត្រូវគិតប្រចាំឆ្នាំ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | លទ្ធផលនៃសូចនាករសម្រេចបាន ១០០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៤ | លទ្ធផលនៃសូចនាករសម្រេចបានពី៩៥ ដល់៩៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៣ | លទ្ធផលនៃសូចនាករសម្រេចបានពី៩០ ដល់៩៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ២ | លទ្ធផលនៃសូចនាករសម្រេចបានពី៨៥ ដល់៨៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ១ | លទ្ធផលនៃសូចនាករសម្រេចបានពី៨០ ដល់៨៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ០ | លទ្ធផលនៃសូចនាករសម្រេចបានតិចជាង៨០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ទិន្នន័យយកមកផ្ទៀងផ្ទាត់ ជាទិន្នន័យមានសង្គតិភាពរវាងទិន្នន័យដែលផ្តល់ដោយមណ្ឌលសុខភាព និងទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល។ ក្នុងករណីដែលទិន្នន័យមិនត្រូវគ្នា ត្រូវយកទិន្នន័យដែលទាបបំផុតមកគណនា រួចត្រូវដក២ពិន្ទុ។

## ➢ ភាគរយស្ត្រីក្រោយសម្រាលទទួលថ្នាំគ្រាប់ជាតិដែក/អាស៊ីតហ្វូលិក៩០គ្រាប់

- ***សេចក្តីពន្យល់៖*** សំដៅដល់អត្រាស្ត្រីក្រោយសម្រាលដែលបានទទួលថ្នាំគ្រាប់ជាតិដែក/អាស៊ីតហ្វូលិក ៩០គ្រាប់។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ របាយការណ៍លទ្ធផលប្រចាំឆ្នាំរបស់មណ្ឌលសុខភាពធៀបគោលដៅចំណុចថ្នាក់ជាតិ។ ទិន្នន័យយកមកពិនិត្យត្រូវគិតប្រចាំឆ្នាំ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | លទ្ធផលនៃសូចនាករសម្រេចបាន ១០០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៤ | លទ្ធផលនៃសូចនាករសម្រេចបានពី៩៥ ដល់៩៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ៣ | លទ្ធផលនៃសូចនាករសម្រេចបានពី៩០ ដល់៩៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ២ | លទ្ធផលនៃសូចនាករសម្រេចបានពី៨៥ ដល់៨៩ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ១ | លទ្ធផលនៃសូចនាករសម្រេចបានពី៨០ ដល់៨៤ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |
| ពិន្ទុ ០ | លទ្ធផលនៃសូចនាករសម្រេចបានតិចជាង ៨០ភាគរយ នៃគោលដៅចំណុចថ្នាក់ជាតិ ដែលបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ នៃវិស័យសុខាភិបាល |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ទិន្នន័យយកមកផ្ទៀងផ្ទាត់ ជាទិន្នន័យមានសង្គតិភាពរវាងទិន្នន័យដែលផ្តល់ដោយមណ្ឌលសុខភាព និងទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល។ ក្នុងករណីដែលទិន្នន័យមិនត្រូវគ្នា ត្រូវយកទិន្នន័យដែលទាបបំផុតមកគណនា រួចត្រូវដក២ពិន្ទុ។

# ផ្នែកទី៣៖ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព

## ៣. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព (៨០ពិន្ទុ)

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សំដៅដល់ប្រព័ន្ធគ្រប់គ្រងធនធានហិរញ្ញវត្ថុ ដែលជះឥទ្ធិពលលើប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ ប្រកបដោយសមធម៌ និងបរិយាបន្ន។ ក្នុងន័យនេះ, ការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងមណ្ឌលសុខភាព ត្រូវជានាថាការដឹកនាំ និងការគ្រប់គ្រងនូវកិច្ចដំណើការទាំងការរៀបចំផែនការថវិកា, ការអនុវត្តថវិកា, ការត្រួតពិនិត្យ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងសមិទ្ធកម្ម អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ដើម្បីធានាបានប្រសិទ្ធភាព ស័ក្តិសិទ្ធភាព, គណនេយ្យភាព និងតម្លាភាព ។

លក្ខណៈវិនិច្ឆ័យសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងមណ្ឌលសុខភាព គឺរួមចំណែកលើកកម្ពស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីឆ្លើយតបនឹងការផ្តល់សេវាសុខាភិបាលប្រកបដោយគុណភាព និងភាពទាន់ពេលវេលានៃការផ្តល់សេវាសុខាភិបាលជូនប្រជាជននៅក្នុងតំបន់មូលដ្ឋាន។ ការរៀបចំលក្ខណៈវិនិច្ឆ័យនេះ គឺមិនត្រឹមតែផ្អែកលើសមត្ថភាព និងលទ្ធភាពប៉ុណ្ណោះទេ ប៉ុន្តែក៏បានរួមបញ្ចូលនូវការអនុវត្តបានល្អៗលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផងដែរ ដើម្បីជួយគាំទ្រដល់មណ្ឌលសុខភាព ក្នុងការ (ទី១)បង្កើនប្រសិទ្ធភាពការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់មណ្ឌលសុខភាព, (ទី២)ពង្រឹងគណនេយ្យភាពលើការគ្រប់គ្រងនិងប្រើប្រាស់ថវិកា និង(ទី៣)ធានាបាននូវភាពឆ្លើយតបទៅនឹងតម្រូវការសេវាសុខភាពនៅតាមសហគមន៍។

នៅក្នុងផ្នែកនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព មានពិន្ទុសរុបចំនួន ៨០ ដែលមានលក្ខណៈវិនិច្ឆ័យរងចំនួន ៣ គឺ៖

**១. ភាពជឿទុកចិត្តនៃថវិកា** (៣០ពិន្ទុ)

**២. ប្រព័ន្ធគ្រប់គ្រងគណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋ** (៣៥ពិន្ទុ)

**៣. ការតាមដាន និងការត្រួតពិនិត្យហិរញ្ញវត្ថុ** (១៥ពិន្ទុ)

## ៣.១ ភាពជឿទុកចិត្តនៃថវិកា (៣០ពិន្ទុ)

### ៣.១.១ ការរៀបចំផែនការថវិកា (១៥ពិន្ទុ)

➢ ផែនការប្រតិបត្តិប្រចាំឆ្នាំ (Annual Operation Plan)

- ***សេចក្តីពន្យល់៖*** សំដៅដល់ផែនការរួមរបស់មណ្ឌលសុខភាព ដោយបង្ហាញអំពីផែនការសកម្មភាព និងផែនការហិរញ្ញវត្ថុរបស់មណ្ឌលសុខភាព សម្រាប់អនុវត្តនៅឆ្នាំបន្ទាប់។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការប្រតិបត្តិប្រចាំឆ្នាំស្របតាមទម្រង់ផែនការរបស់ក្រសួងសុខាភិបាល និង២)សកម្មភាពមានគ្រប់ប្រភពថវិកា(ថវិកាជាតិ សេវាបង់ថ្លៃ និងជំនួយ)។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | ផែនការប្រតិបត្តិប្រចាំឆ្នាំ |
| ពិន្ទុ ២ | ការរៀបចំតាមទម្រង់ផែនការរបស់ក្រសួងសុខាភិបាល |
| ពិន្ទុ ១ | សកម្មភាពមានគ្រប់ប្រភពថវិកា(ថវិកាជាតិ សេវាបង់ថ្លៃ និងជំនួយ) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ផែនការត្រីមាស

- ***សេចក្តីពន្យល់៖*** សំដៅដល់ផែនការប្រតិបត្តិប្រចាំឆ្នាំ ដែលបានរៀបចំតាមត្រីមាស សម្រាប់ការអនុវត្តជាក់ស្តែង។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការត្រីមាស(៤ផែនការក្នុងមួយឆ្នាំ) និង២)ការរៀបចំតាមទម្រង់ផែនការរបស់ក្រសួងសុខាភិបាល។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | ផែនការត្រីមាស(៤ផែនការក្នុងមួយឆ្នាំ) |
| ពិន្ទុ ៣ | ការរៀបចំតាមទម្រង់ផែនការរបស់ក្រសួងសុខាភិបាល (ខ្លឹមសារ កាលបរិច្ឆេទ ហត្ថលេខា) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ

- ***សេចក្តីពន្យល់៖*** សំដៅដល់ការអនុវត្តសកម្មភាពដែលបានគ្រោងក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ សកម្មភាពដែលបានអនុវត្តធៀបជាមួយសកម្មភាពដែលបានគ្រោងទុកក្នុងផែនការ។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | អនុវត្តន៍សកម្មភាពបាន៩០ភាគរយ ដល់១០០ភាគរយ នៃសកម្មភាពដែលបានគ្រោងទុក |
| ពិន្ទុ ៤ | អនុវត្តន៍សកម្មភាពបាន៨០ភាគរយ ដល់៨៩ភាគរយ នៃសកម្មភាពដែលបានគ្រោងទុក |
| ពិន្ទុ ៣ | អនុវត្តន៍សកម្មភាពបាន៧០ភាគរយ ដល់៧៩ភាគរយ នៃសកម្មភាពដែលបានគ្រោងទុក |
| ពិន្ទុ ២ | អនុវត្តន៍សកម្មភាពបាន៦០ភាគរយ ដល់៦៩ភាគរយ នៃសកម្មភាពដែលបានគ្រោងទុក |
| ពិន្ទុ ១ | អនុវត្តន៍សកម្មភាពបាន៥០ភាគរយ ដល់៥៩ភាគរយ នៃសកម្មភាពដែលបានគ្រោងទុក |
| ពិន្ទុ ០ | ក្រោម៥០ភាគរយ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ប្រសិនបើគ្មានរបាយការណ៍បញ្ជាក់ពីការអនុវត្តសកម្មភាពប្រចាំឆ្នាំ គឺមិនទទួលបានពិន្ទុទេ។

### ៣.១.២ ការអនុវត្តថវិកា (កម្មវិធីចំណូល-ចំណាយ និងគោលការណ៍ចំណូល-ចំណាយ) (១៥ពិន្ទុ)

➢ <u>ការគ្រប់គ្រងនិងការប្រមូលចំណូលរបស់មណ្ឌលសុខភាព</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការគ្រប់គ្រងចំណូល(ថវិកាជាតិ ចំណូលពីការបង់ថ្លៃ និងមូលនិធិសមធម៌)ប្រចាំត្រីមាស និងប្រចាំឆ្នាំរបស់មណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ការកត់ត្រានិងរបាយការណ៍ប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ និងយន្តការគ្រប់គ្រងចំណូល។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | ការប្រមូលចំណូល(បង់ថ្លៃសេវា) សម្រេចបានក្នុងចន្លោះពី ៩០ភាគរយ-១០០ភាគរយ (ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ) |
| ពិន្ទុ ៤ | ការប្រមូលចំណូល(បង់ថ្លៃសេវា) សម្រេចបានក្នុងចន្លោះពី ៨០ភាគរយ-៨៩ភាគរយ (ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ) |
| ពិន្ទុ ៣ | ការប្រមូលចំណូល(បង់ថ្លៃសេវា) សម្រេចបានក្នុងចន្លោះពី ៧០ភាគរយ-៧៩ភាគរយ (ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ) |
| ពិន្ទុ ២ | ការប្រមូលចំណូល(បង់ថ្លៃសេវា) សម្រេចបានក្នុងចន្លោះពី ៦០ភាគរយ-៦៩ភាគរយ (ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ) |
| ពិន្ទុ ១ | ការប្រមូលចំណូល(បង់ថ្លៃសេវា) សម្រេចបានក្នុងចន្លោះពី ៥០ភាគរយ-៥៩ភាគរយ (ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ) |
| ពិន្ទុ ០ | ក្រោម ៥០ភាគរយ |

## ➢ ការអនុវត្តថវិកាមានប្រសិទ្ធភាព

- ***សេចក្តីពន្យល់៖*** សំដៅដល់ការអនុវត្តថវិកាធៀបទៅនឹងផែនការថវិកាប្រចាំឆ្នាំដែលបានកំណត់ដោយមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ផែនការថវិកា និងរបាយការណ៍អនុវត្តន៍ថវិកាប្រចាំឆ្នាំ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | ការអនុវត្តថវិការដ្ឋ និងថវិកាដទៃទៀតបានក្នុងចន្លោះពី ៩០ភាគរយ-១០០ភាគរយ (ការប្រើប្រាស់ថវិកាក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ) |
| ពិន្ទុ ៤ | ការអនុវត្តថវិការដ្ឋ និងថវិកាដទៃទៀតបានក្នុងចន្លោះ ៨០ភាគរយ-៨៩ភាគរយ (ការប្រើប្រាស់ថវិកាក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ) |
| ពិន្ទុ ៣ | ការអនុវត្តថវិការដ្ឋ និងថវិកាដទៃទៀតបានក្នុងចន្លោះ ៧០ភាគរយ-៧៩ភាគរយ (ការប្រើប្រាស់ថវិកាក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ) |
| ពិន្ទុ ២ | ការអនុវត្តថវិការដ្ឋ និងថវិកាដទៃទៀតបានក្នុងចន្លោះ ៦០ភាគរយ-៦៩ភាគរយ (ការប្រើប្រាស់ថវិកាក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ) |
| ពិន្ទុ ១ | ការអនុវត្តថវិការដ្ឋ និងថវិកាដទៃទៀតបានក្នុងចន្លោះ ៥០ភាគរយ-៥៩ភាគរយ (ការប្រើប្រាស់ថវិកាក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ) |
| ពិន្ទុ ០ | ក្រោម៥០ភាគរយ |

## ➢ តម្លាភាពថវិកា

- ***សេចក្តីពន្យល់៖*** សំដៅដល់ការផ្សព្វផ្សាយចំណូលចំណាយប្រចាំខែរបស់មណ្ឌលសុខភាពជាប្រចាំ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការបិទផ្សាយ ឬកត់ត្រាព័ត៌មានពាក់ព័ន្ធចំណូលចំណាយរបស់មណ្ឌលសុខភាពលើតារាងតាមដានសេវាសុខាភិបាលសំខាន់ៗ និង២)កិច្ចប្រជុំផ្សព្វផ្សាយ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ៣ | មានការបិទផ្សាយ ឬកត់ត្រាព័ត៌មានពាក់ព័ន្ធចំណូលចំណាយថវិការបស់មណ្ឌលសុខភាពលើតារាងតាមដានសេវាសុខាភិបាលសំខាន់ៗជារៀងរាល់ខែកន្លងមក |
| ពិន្ទុ ២ | កិច្ចប្រជុំផ្សព្វផ្សាយ(៤ ត្រីមាស) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ចំណុចទី១នៃលក្ខណៈវិនិច្ឆ័យលម្អិតនេះត្រូវបានផ្តល់ពិន្ទុ៣ ក្នុងករណីដែលមានការបិទផ្សាយជារៀងរាល់ខែកន្លងមក ប៉ុន្តែក្នុងករណីដែលមិនបានផ្សព្វផ្សាយក្នុងខែណាមួយ ឬករណីព័ត៌មានដែលផ្សព្វផ្សាយមិនមានសុក្រឹតភាពក្នុងខែណាមួយ ត្រូវដកមួយពិន្ទុក្នុង១ខែ។

## ៣.២ ប្រព័ន្ធគ្រប់គ្រងគណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋ (៣៥ពិន្ទុ)

### ៣.២.១ ដំណើរការនៃការកត់ត្រា (២៥ពិន្ទុ)

➢ <u>មានបញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់បញ្ជី ឬសៀវភៅកត់ត្រាប្រតិបត្តិការសាច់ប្រាក់ក្នុងគណនីធនាគាររបស់មណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ បញ្ជីតាមដានសាច់ប្រាក់(អនុគណនី ៦២០២៨ និងថវិកាសេវាហិរញ្ញប្បទាន)។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានបញ្ជីតាមដានសាច់ប្រាក់ |
| ពិន្ទុ ១ | មានការកត់ត្រាតាមកាលបរិច្ឆេទ |
| ពិន្ទុ ១ | មានការបូកសរុបតាមខែនីមួយៗ ច្បាស់លាស់ |
| ពិន្ទុ ១ | មានហត្ថលេខាពីប្រធានមណ្ឌលសុខភាព |
| ពិន្ទុ ១ | មានការរៀបចំទុកដាក់ប្រកបដោយរបៀបរៀបរយ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>មានបញ្ជីបេឡាសម្រាប់តាមដានស្ថានភាពចំណូលចំណាយ និងចំនួនសាច់ប្រាក់ដែលនៅសល់ចុងថ្ងៃ ចុងខែ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់បញ្ជីកត់ត្រាចំណូល ចំណាយប្រចាំថ្ងៃ និងប្រចាំខែរបស់មណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ បញ្ជីកត់ត្រាចំណូលចំណាយរបស់មណ្ឌលសុខភាព។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានបញ្ជីកត់ត្រាចំណូលចំណាយ |
| ពិន្ទុ ១ | មានការកត់ត្រាប្រចាំថ្ងៃ |
| ពិន្ទុ ១ | មានការបូកសរុបប្រចាំខែនីមួយៗច្បាស់លាស់ |
| ពិន្ទុ ១ | មានហត្ថលេខាពីប្រធានមណ្ឌលសុខភាព |
| ពិន្ទុ ១ | មានការរៀបចំទុកដាក់ប្រកបដោយរបៀបរៀបរយ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ➢ ការកត់ត្រាកិច្ចបញ្ជិកាគណនេយ្យតាមកំព្យូទ័រ

- ***សេចក្តីពន្យល់៖*** សំដៅដល់កិច្ចបញ្ជិកាគណនេយ្យ(បូកសរុបទិន្នន័យប្រចាំឆ្នាំ) ដោយប្រើប្រាស់ប្រព័ន្ធគណនេយ្យកុំព្យូទ័រ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)កិច្ចបញ្ជិកាគណនេយ្យតាមកំព្យូទ័រ និង ២)ភាពត្រឹមត្រូវនៃការកត់ត្រាតាមរយៈប្រព័ន្ធកំព្យូទ័រ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ៣ | មានការកត់ត្រាគណនេយ្យតាមរយៈប្រព័ន្ធកំព្យូទ័រ |
| ពិន្ទុ ២ | ការកត់ត្រាតាមរយៈប្រព័ន្ធកំព្យូទ័របានត្រឹមត្រូវ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ➢ ការគ្រប់គ្រងឯកសារហិរញ្ញវត្ថុ

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរក្សាទុកឯកសារពាក់ព័ន្ធនឹងហិរញ្ញវត្ថុក្នុងក្រូណូ តាមលំដាប់និងមានភាពងាយស្រួលសម្រាប់ការប្រើប្រាស់។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ របៀបទុកដាក់ឯកសារពាក់ព័ន្ធហិរញ្ញវត្ថុ (របាយការណ៍ចំណូលចំណាយ បញ្ជីកត់ត្រាចំណូលចំណាយក្នុងមណ្ឌលសុខភាព បញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារ...)។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានឯកសារពាក់ព័ន្ធនឹងហិរញ្ញវត្ថុទាំងអស់ |
| ពិន្ទុ ១ | ឯកសារពាក់ព័ន្ធនឹងហិរញ្ញវត្ថុទាំងអស់ត្រូវបានដាក់ក្នុងក្រូណូ |
| ពិន្ទុ ២ | មានទូទុកដាក់ឯកសារពាក់ព័ន្ធនឹងហិរញ្ញវត្ថុ |
| ពិន្ទុ ១ | ការទុកដាក់ឯកសារពាក់ព័ន្ធហិរញ្ញវត្ថុមានរបៀបរៀបរយ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ➢ មានកិច្ចបញ្ជិកាគណនេយ្យបានត្រឹមត្រូវ

- ***សេចក្តីពន្យល់៖*** សំដៅលើការកត់ត្រាសាច់ប្រាក់ស្របតាមប្លង់គណនេយ្យសាធារណៈ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បញ្ជិកាគណនេយ្យ និង២)ការរក្សាទុក។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ៣ | បញ្ជិកាគណនេយ្យ(ការកត់ត្រាច្បាស់លាស់ តាមកាលបរិច្ឆេទ និងតាមប្លង់គណនេយ្យសាធារណៈ)(៣ឆ្នាំចុងក្រោយ) |
| ពិន្ទុ ២ | ការរក្សាទុកបានត្រឹមត្រូវ(៣ឆ្នាំចុងក្រោយ) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ៣.២.២ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (១០ពិន្ទុ)

➢ មានបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោល

- *សេចក្តីពន្យល់៖* សំដៅដល់ការកត់ត្រាបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោល ស្របតាមវិធាន និងទម្រង់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ២ | មានសៀវភៅសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោល(ច្បាប់ដើម ឬច្បាប់ចម្លង) |
| ពិន្ទុ ៣ | ការរៀបចំតាមទម្រង់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(ហត្ថលេខា ខ្លឹមសារ និង កាលបរិច្ឆេទ) |
| ពិន្ទុ ០ | គ្មានសៀវភៅបញ្ជីសារពើភ័ណ្ឌ ឬឯកសារសារពើភ័ណ្ឌ |

➢ មណ្ឌលសុខភាពធ្វើបច្ចុប្បន្នកម្មតារាងប្រៀបធៀប(កើន/ថយចុះ) ទ្រព្យសម្បត្តិរដ្ឋ

- *សេចក្តីពន្យល់៖* សំដៅដល់ការធ្វើបច្ចុប្បន្នកម្មតារាងប្រៀបធៀប(កើន/ថយចុះ) ទ្រព្យសម្បត្តិរដ្ឋ ប្រចាំឆ្នាំ និងទាន់ពេលវេលា។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ តារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋ។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ២ | មានតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋ(កើន/ថយចុះ)ប្រចាំឆ្នាំ (២ ឆ្នាំចុងក្រោយ) |
| ពិន្ទុ ៣ | ការរៀបចំតាមទម្រង់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(ហត្ថលេខា ខ្លឹមសារ និង កាលបរិច្ឆេទ) |
| ពិន្ទុ ០ | គ្មានសៀវភៅបញ្ជីសារពើភ័ណ្ឌ ឬឯកសារសារពើភ័ណ្ឌ |

## ៣.៣ ការតាមដាន និងការត្រួតពិនិត្យហិរញ្ញវត្ថុ (១៥ពិន្ទុ)

### ៣.៣.១ ប្រព័ន្ធរបាយការណ៍តាមដានវឌ្ឍនភាពការងារ (៥ពិន្ទុ)

➢ មានរបាយការណ៍លទ្ធផលការងារ

- *សេចក្តីពន្យល់៖* សំដៅដល់របាយការណ៍លទ្ធផលការងាររបស់មណ្ឌលសុខភាពដែលឆ្លុះបញ្ចាំងពីលទ្ធផលដែលមណ្ឌលសុខភាពអនុវត្តបានប្រចាំឆមាស និងឆ្នាំ និងផ្ញើជូនការិយាល័យសុខាភិបាលស្រុកប្រតិបត្តិបានទាន់ពេលវេលា។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍លទ្ធផលការងារ ដែលមណ្ឌលសុខភាពបានរៀបចំ និង២)កាលបរិច្ឆេទដែលផ្ញើជូនការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ២ | មានរបាយការណ៍លទ្ធផលប្រចាំឆមាស (មានខ្លឹមសារ មានការកត់ត្រាលទ្ធផល ច្បាស់លាស់ និងមានការចុះហត្ថលេខាត្រឹមត្រូវ) |

| | |
|---|---|
| ពិន្ទុ ២ | មានរបាយការណ៍លទ្ធផលប្រចាំឆ្នាំ (មានខ្លឹមសារ មានការកត់ត្រាលទ្ធផលច្បាស់លាស់ និងមានការចុះហត្ថលេខាត្រឹមត្រូវ)-១ឆ្នាំ |
| ពិន្ទុ ១ | ផ្ញើជូនការិយាល័យសុខាភិបាលស្រុកប្រតិបត្តិបានទាន់ពេលវេលា |
| ពិន្ទុ ០ | មិនមានរបាយការណ៍ |

### ៣.៣.២ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (១០ពិន្ទុ)

➢ <u>មានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការអនុវត្តប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់មណ្ឌលសុខភាព ដើម្បីធានាថាថវិកាត្រូវបានគ្រប់គ្រង និងប្រើប្រាស់ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តិជាធរមាន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ របាយការណ៍ត្រួតពិនិត្យផ្ទៃក្នុង(របាយការណ៍សវនកម្មផ្ទៃក្នុង/អធិការកិច្ច/សវនកម្មឯករាជ្យ) ដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ៣ | មានរបាយការណ៍សវនកម្មផ្ទៃក្នុង/អធិការកិច្ច/សវនកម្មឯករាជ្យ(ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ) |
| ពិន្ទុ ២ | មានកំណត់ហេតុកិច្ចប្រជុំស្តីពីរបាយការណ៍សវនកម្មផ្ទៃក្នុង/អធិការកិច្ច/សវនកម្មឯករាជ្យ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ |
| ពិន្ទុ ០ | គ្មានរបាយការណ៍ |

➢ <u>កាអនុវត្តតាមអនុសាសន៍របស់សវនកម្មផ្ទៃក្នុង/អធិការកិច្ច/សវនកម្មឯករាជ្យ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការអនុវត្តតាមអនុសាសន៍របស់សវនកម្មផ្ទៃក្នុង សវនកម្មឯករាជ្យ និងអធិការកិច្ច ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការនៃការអនុវត្តអនុសាសន៍ និង ២)របាយការណ៍នៃការអនុវត្តទៅតាមអនុសាសន៍។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានផែនការអនុវត្តតាមអនុសាសន៍ |
| ពិន្ទុ ៣ | មានរបាយការណ៍នៃការអនុវត្តទៅតាមអនុសាសន៍<br>➢ សម្រេចបានពី ៩០ភាគរយ ដល់ ១០០ភាគរយ (៣ ពិន្ទុ)<br>➢ សម្រេចបានពី ៨០ភាគរយ ដល់ ៨៩ភាគរយ (២ ពិន្ទុ)<br>➢ សម្រេចបានពី ៧០ភាគរយ ដល់ ៧៩ភាគរយ (១ ពិន្ទុ)<br>➢ ក្រោម ៧០ភាគរយ (០ ពិន្ទុ) |
| ពិន្ទុ ០ | គ្មានផែនការ និងរបាយការណ៍នៃការអនុវត្ត |

# ផ្នែកទី៤៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព

## ៤. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព (៧៥ពិន្ទុ)

ការពង្រឹង និងកំណែលម្អការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស គឺជាកិច្ចការគន្លឹះដែលមានសារៈសំខាន់ ដើម្បីប្រែក្លាយធនធានមនុស្សនៅក្នុងស្ថាប័នឬអង្គភាពមួយឱ្យកាន់តែមានសមត្ថភាព វិជ្ជាជីវៈច្បាស់លាស់ និងប្រសិទ្ធភាពក្នុងការបំពេញការងារ ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ ក្នុងន័យនេះ ការគិតគូលើការពង្រឹង និងកំណែលម្អការគ្រប់គ្រងធនធានមនុស្សប្រដោយប្រសិទ្ធភាព និងការអភិវឌ្ឍសមត្ថភាព ធនធានមនុស្សប្រកបដោយភាពត្រឹមត្រូវ ឆ្លើយតបទៅនឹងតម្រូវការរបស់មណ្ឌលសុខភាព គឺជាកត្តាចាំបាច់បំផុត ដែលរួមចំណែកដល់ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាព នៃការផ្តល់សេវាសុខាភិបាល និងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងសហគមន៍។

ក្នុងផ្នែកការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងអង្គភាពមានពិន្ទុសរុបចំនួន៧៥ ដែលលក្ខណៈវិនិច្ឆ័យវងចំនួន២ គឺ៖

១. ការគ្រប់គ្រងធនធានមនុស្ស (៥០ពិន្ទុ)

២. ការអភិវឌ្ឍធនធានមនុស្ស (២៥ពិន្ទុ)

## ៤.១ ការគ្រប់គ្រងធនធានមនុស្ស (៥០ពិន្ទុ)

### ៤.១.១ ការរៀបចំនិងអនុវត្តផែនការគ្រប់គ្រងធនធានមនុស្ស (៥ពិន្ទុ)

➢ <u>មានផែនការគ្រប់គ្រងធនធានមនុស្ស</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ឯកសារដែលពិពណ៌នាអំពីសកម្មភាព និងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងធនធានមនុស្ស ដើម្បីឆ្លើយតបនឹងតម្រូវការការងាររបស់អង្គភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការធនធានមនុស្សប្រចាំឆ្នាំ ២)កិច្ចប្រជុំពិគ្រោះយោបល់ជាមួយបុគ្គលិកក្នុងមណ្ឌលសុខភាព និង៣)សំណើស្តីពីតម្រូវការធនធានមនុស្សពីមណ្ឌលសុខភាពទៅការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានផែនការគ្រប់គ្រងធនធានមនុស្ស |
| ពិន្ទុ ២ | មានរបាយការណ៍ ឬកំណត់ហេតុនៃកិច្ចប្រជុំពិគ្រោះយោបល់ជាមួយបុគ្គលិកក្នុងមណ្ឌលសុខភាព |
| ពិន្ទុ ១ | សំណើស្តីពីតម្រូវការធនធានមនុស្សពីមណ្ឌលសុខភាពទៅការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ៤.១.២ ការគ្រប់គ្រងការវិវត្តន៍អាជីពរបស់មន្ត្រី (១៥ពិន្ទុ)

➢ <u>ការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីផ្អែកតាមតម្រូវការពិតប្រាកដ និងអនុវត្តតាមបទដ្ឋានគតិយុត្តជាធរមាន</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីទាំងនៅក្នុង និងខាងក្រៅអង្គភាព ដើម្បីបំពេញកន្លែងទំនេរ និងឆ្លើយតបទៅនឹងតម្រូវការសមត្ថភាពជំនាញ ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនៃការអនុវត្តការងាររបស់មណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការឆ្លើយតបនឹងតម្រូវការជំនាញ ២)ការផ្លាស់ប្តូរដើម្បីបំពេញកន្លែងទំនេរ ៣)ការពិគ្រោះយោបល់ប្រកបដោយតម្លាភាព និង៤)សេចក្តីសម្រេចប្រគល់ភារកិច្ចជូនមន្ត្រីដែលបានផ្ទេរចូល។ ដើម្បីផ្ទៀងផ្ទាត់អំពី ការឆ្លើយតបនឹងតម្រូវការសមត្ថភាព និងកន្លែងទំនេរ ត្រូវពិនិត្យលើរចនាសម្ព័ន្ធ មន្ត្រីក្នុងមុខតំណែងក្នុងរចនាសម្ព័ន្ធ (អង្គការលេខ) ប្រវត្តិរូបសង្ខេបរបស់មន្ត្រីដែលបានផ្ទេរចូល និងសេចក្តីសម្រេចស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាព។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | ការឆ្លើយតបនឹងតម្រូវការជំនាញ |
| ពិន្ទុ ១ | ការផ្លាស់ប្តូរដើម្បីបំពេញកន្លែងទំនេរ |
| ពិន្ទុ ១ | មានការពិគ្រោះយោបល់ប្រកបដោយតម្លាភាព(របាយការណ៍ ឬកំណត់ហេតុនៃកិច្ចប្រជុំ) |

| | |
|---|---|
| ពិន្ទុ ១ | មានសេចក្តីសម្រេចប្រគល់ភារកិច្ចជូនមន្ត្រីដែលបានផ្ទេរចូល |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ **ការដំឡើងថ្នាក់និងឋានន្តរស័ក្តិត្រូវបានរៀបចំជាទៀតទាត់**

- ***សេចក្តីពន្យល់៖*** សំដៅដល់ការដំឡើងថ្នាក់ ឬឋានន្តរស័ក្តិប្រចាំឆ្នាំជូនមន្ត្រីរាជការនៅមណ្ឌលសុខភាព ដែលជាគោលការណ៍ ត្រូវធ្វើឡើងតាមវេនជ្រើសរើស តាមអតីតភាពការងារ និងតាមសញ្ញាបត្រ។ ការដំឡើងថ្នាក់ ឬឋានន្តរស័ក្តិ ត្រូវធ្វើឡើងជាទៀតទាត់ ប្រកបដោយតម្លាភាព សុចរិតភាព និងត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បញ្ជីឈ្មោះមន្ត្រីសម្រាប់ដំឡើងថ្នាក់ប្រចាំឆ្នាំ(រយៈពេល៣ឆ្នាំជាប់គ្នា) ២)របាយការណ៍ឬកំណត់ហេតុនៃកិច្ចប្រជុំពិគ្រោះយោបល់លើការដំឡើងថ្នាក់ និងឋានន្តរស័ក្តិជូនមន្ត្រីរាជការរបស់មណ្ឌលសុខភាព ៣)សំណើដំឡើងថ្នាក់ប្រចាំឆ្នាំជូនមន្ត្រីរាជការរបស់មណ្ឌលសុខភាព និង៤)ភាពទៀងទាត់នៃការដំឡើងថ្នាក់និងឋានន្តរស័ក្តិ។ ដើម្បីពិនិត្យមើលភាពទៀងទាត់នៃការដំឡើងថ្នាក់ និងឋានន្តរស័ក្តិត្រូវពិនិត្យមើលសេចក្តីសម្រេច (ប្រកាស អនុក្រឹត្យ ព្រះរាជក្រឹត្យ)ស្តីពីការដំឡើងជូនមន្ត្រីរាជការស៊ីវិលរយៈពេល ៥ឆ្នាំចុងក្រោយ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានការរៀបចំបញ្ជីឈ្មោះមន្ត្រីសម្រាប់ដំឡើងថ្នាក់ប្រចាំឆ្នាំ |
| ពិន្ទុ ១ | មានការប្រជុំវាយតម្លៃដើម្បីឡើងថ្នាក់ប្រចាំឆ្នាំរបស់មន្ត្រីរបស់មណ្ឌលសុខភាព |
| ពិន្ទុ ១ | មានការរៀបចំលិខិតស្នើដើម្បីដំឡើងថ្នាក់ប្រចាំឆ្នាំជូនមន្ត្រីរបស់មណ្ឌលសុខភាព |
| ពិន្ទុ ១ | បានរៀបចំដំឡើងថ្នាក់និងឋានន្តរស័ក្តិជាទៀងទាត់ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ **ការរៀបចំដាក់ឱ្យចូលនិវត្តន៍គោរពតាមគោលការណ៍កំណត់**

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរៀបចំ ដាក់មន្ត្រីរាជការគ្រប់រូប ដែលបានបំពេញគ្រប់លក្ខខណ្ឌឱ្យចូលនិវត្តន៍បានទាន់ពេលវេលា និងការគិតគូរអំពីសុខទុក្ខរបស់ពួកគាត់នៅក្រោយពេលដាក់ឱ្យចូលនិវត្តន៍។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បញ្ជីឈ្មោះមន្ត្រីរាជការចូលនិវត្តន៍ប្រចាំឆ្នាំ ២)លិខិតជូនដំណឹងដល់មន្ត្រីរាជការដែលត្រៀមចូលនិវត្តន៍ ៣)លិខិតស្នើសុំដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ៤)លិខិតស្នើសុំប្រាក់ឧបត្ថម្ភសោធនដំបូងម្តងគត់សម្រាប់មន្ត្រីដែលត្រូវនិវត្តន៍ និង ៥)ការគិតគូរអំពីសុខទុក្ខនិវត្តន៍ជននៅក្រោយពេលដាក់ឱ្យចូលនិវត្តន៍។ ដើម្បីពិនិត្យលើការគិតគូរអំពីសុខទុក្ខនិវត្តន៍ជននៅក្រោយពេលដាក់ឱ្យចូលនិវត្តន៍គឺ ត្រូវជួបសម្ភាសន៍ជាមួយថ្នាក់ដឹកនាំរបស់មណ្ឌលសុខភាព។

- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ១ | មានបញ្ជីឈ្មោះមន្ត្រីរាជការដែលត្រូវចូលនិវត្តន៍ប្រចាំឆ្នាំ |
| ពិន្ទុ ១ | មានលិខិតជូនដំណឹងដល់មន្ត្រីរាជការដែលត្រៀមចូលនិវត្តន៍បានទាន់ពេលវេលា |
| ពិន្ទុ ១ | មានលិខិតស្នើសុំដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ |
| ពិន្ទុ ១ | មានលិខិតស្នើសុំប្រាក់ឧបត្ថម្ភសោធនជំបូងម្តងគត់សម្រាប់មន្ត្រីដែលត្រូវនិវត្តន៍ |
| ពិន្ទុ ១ | ការគិតគូរអំពីសុខទុក្ខនិវត្តន៍ជននៅក្រោយពេលដាក់ឱ្យចូលនិវត្តន៍ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- *ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖* ក្នុងករណីដែលមណ្ឌលសុខភាពមិនទាន់មានមន្ត្រីចូលនិវត្តន៍ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ នោះមណ្ឌលសុខភាពនឹងទទួលបានពិន្ទុ៣។ ដើម្បីពិនិត្យមើល ថាតើមានមណ្ឌលសុខភាពមាន ឬមិនមានមន្ត្រីចូលនិវត្តន៍ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ គឺត្រូវពិនិត្យទិន្នន័យ/បញ្ជីឈ្មោះមន្ត្រី។

### ៤.១.៣ ការគ្រប់គ្រងសមិទ្ធកម្ម (៣០ពិន្ទុ)

➢ ការរៀបចំរចនាសម្ព័ន្ធរបស់អង្គភាព

- *សេចក្តីពន្យល់៖* សំដៅដល់ការបែងចែកមុខតំណែង និងរចនាសម្ព័ន្ធការងារឆ្លើយតបនឹងមុខងាររបស់មណ្ឌលសុខភាពដោយតម្រៀបមុខតំណែងទាំងនោះទៅក្នុងទម្រង់ជាអង្គការលេខ។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ១)រចនាសម្ព័ន្ធនិងមន្ត្រីក្នុងមុខតំណែងក្នុងរចនាសម្ព័ន្ធ(អង្គការលេខ) ២)បច្ចុប្បន្នភាពនៃរចនាសម្ព័ន្ធ(អង្គការលេខ) ៣)ការបិទផ្សាយរចនាសម្ព័ន្ធ(អង្គការលេខ) និង៤)រចនាសម្ព័ន្ធឆ្លើយតបទៅនឹងមុខងារ។ ដើម្បីពិនិត្យរចនាសម្ព័នឆ្លើយតបទៅនឹងមុខងារគឺ ត្រូវពិនិត្យលើលិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាព ធៀបជាមួយអង្គការលេខ។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ២ | មានរចនាសម្ព័ន្ធ(អង្គការលេខ)ច្បាស់លាស់(មានឈ្មោះ រូបថត មុខតំណែង) |
| ពិន្ទុ ១ | រចនាសម្ព័ន្ធ(អង្គការលេខ)មានបច្ចុប្បន្នភាព |
| ពិន្ទុ ១ | មានការបិទផ្សាយរចនាសម្ព័ន្ធ(អង្គការលេខ)របស់មណ្ឌលសុខភាព |
| ពិន្ទុ ១ | រចនាសម្ព័ន្ធឆ្លើយតបទៅនឹងមុខងារ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ការរៀបចំការពិពណ៌នាមុខតំណែង ឬការបែងចែកភារកិច្ច

- ***សេចក្តីពន្យល់៖*** សំដៅដល់ការកំណត់ពីតួនាទី ភារកិច្ច ការទទួលខុសត្រូវ និងជំនាញវិជ្ជាជីវៈសម្រាប់មុខតំណែងនីមួយៗក្នុងរចនាសម្ព័ន្ធរបស់មណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ឯកសារស្តីពីការពិពណ៌នាមុខតំណែង ឬការបែងចែកភារកិច្ច ២)របាយការណ៍កិច្ចប្រជុំពិគ្រោះយោបល់ក្នុងការបែងចែកភារកិច្ច និង៣)របាយការណ៍លទ្ធផលការងាររបស់មន្ត្រីម្នាក់ៗ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានឯកសារស្តីពីការពិពណ៌នាមុខតំណែង ឬការបែងចែកភារកិច្ច |
| ពិន្ទុ ១ | មានការកំណត់ជំនាញវិជ្ជាជីវៈសម្រាប់មុខតំណែងនីមួយៗ |
| ពិន្ទុ ១ | មានការប្រជុំពិគ្រោះយោបល់ក្នុងការបែងចែកភារកិច្ច |
| ពិន្ទុ ២ | ការអនុវត្តភារកិច្ចរបស់មន្ត្រីម្នាក់ៗស្របតាមឯកសារស្តីពីការពិពណ៌នាមុខតំណែង ឬការបែងចែកភារកិច្ច |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ការគ្រប់គ្រងវត្តមានជាទៀងទាត់

- ***សេចក្តីពន្យល់៖*** សំដៅដល់ការពង្រឹងការគ្រប់គ្រងវត្តមានប្រចាំថ្ងៃរបស់មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ដែលកំពុងបម្រើការងារនៅក្នុងមណ្ឌលសុខភាព តាមមធ្យោបាយផ្សេងៗ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ មនសិការវិជ្ជាជីវៈ និងលទ្ធផលការងារនៅក្នុងមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បញ្ជីគ្រប់គ្រងវត្តមាន(អនុលោមតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា) ២)ការពិនិត្យជាក់ស្តែងលើការគ្រប់គ្រងវត្តមានតាមប្រព័ន្ធអេឡិចត្រូនិច(ស្កេនមេដៃ...) និង៣)របាយការណ៍វត្តមានប្រចាំខែ ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានបញ្ជីគ្រប់គ្រងវត្តមាន |
| ពិន្ទុ ១ | មានការគ្រប់គ្រងវត្តមានតាមប្រព័ន្ធអេឡិចត្រូនិច(ស្កេនមេដៃ...) |
| ពិន្ទុ ២ | មានរបាយការណ៍វត្តមានប្រចាំខែ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ➢ ការវាយតម្លៃសមិទ្ធកម្ម និងការលើកទឹកចិត្ត

- ***សេចក្តីពន្យល់៖*** សំដៅដល់ការវាយតម្លៃទៅលើការអនុវត្តការងារ និងលទ្ធផលការងាររបស់មន្ត្រីម្នាក់ៗធៀបទៅនឹងការបែងចែកភារកិច្ចរបស់មន្ត្រីម្នាក់ៗ។ ការលើកទឹកចិត្តសំដៅដល់វិធានការអនុវត្តដើម្បីលើកទឹកចិត្តមន្ត្រីម្នាក់ៗផ្អែកលើលទ្ធផលនៃការវាយតម្លៃសមិទ្ធកម្ម។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ឧបករណ៍សម្រាប់វាយតម្លៃសមិទ្ធកម្ម ២)របាយការណ៍នៃការវាយតម្លៃសមិទ្ធកម្ម និងការលើកទឹកចិត្ត និង៣)របាយការណ៍ ឬឯកសារដាក់ពិន័យដល់មន្ត្រីមណ្ឌលសុខភាព។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការវាយតម្លៃសមិទ្ធកម្ម |
| ពិន្ទុ ១ | មានការកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃសមិទ្ធកម្ម |
| ពិន្ទុ ១ | មានរបាយការណ៍ការវាយតម្លៃសមិទ្ធកម្ម |
| ពិន្ទុ ១ | ការអនុវត្តការលើកទឹកចិត្តផ្អែកលើលទ្ធផលនៃការវាយតម្លៃសមិទ្ធកម្ម |
| ពិន្ទុ ១ | វិធានការពិន័យផ្អែកលើលទ្ធផលនៃការវាយតម្លៃសមិទ្ធកម្ម |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ➢ ការគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា

- ***សេចក្តីពន្យល់៖*** សំដៅដល់ការគ្រប់គ្រងធនធានមនុស្សនៅក្នុងមណ្ឌលសុខភាពដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការពិនិត្យមើលដោយផ្ទាល់លើកម្មវិធីគ្រប់គ្រងធនធានមនុស្សតាមបច្ចេកវិទ្យាព័ត៌មាន ២)ទិន្នន័យមន្ត្រីរាជការបោះពុម្ពចេញពីប្រព័ន្ធព័ត៌មាន និង៣)សម្ភាសន៍ជាមួយមន្ត្រីគ្រប់គ្រងបុគ្គលិក អំពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការគ្រប់គ្រងបុគ្គលិក។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ៣ | មានការរៀបចំទិន្នន័យនៃការគ្រប់គ្រងបុគ្គលិកក្នុងទម្រង់បច្ចេកវិទ្យាព័ត៌មាន |
| ពិន្ទុ ១ | មានការប្រើប្រាស់ទិន្នន័យក្នុងទម្រង់បច្ចេកវិទ្យាព័ត៌មាន ជាមូលដ្ឋានសម្រាប់គ្រប់គ្រងបុគ្គលិកនៅក្នុងមណ្ឌលសុខភាព |
| ពិន្ទុ ១ | បានធ្វើបច្ចុប្បន្នកម្មជាប្រចាំ( យ៉ាងតិច១ឆ្នាំម្តង ) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ការផ្ដល់ពិន្ទុ៣ ចំពោះការវិនិច្ឆ័យទៅលើចំណុចទី១ (ការរៀបចំទិន្នន័យនៃការគ្រប់គ្រងបុគ្គលិកក្នុងទម្រង់បច្ចេកវិទ្យាព័ត៌មាន) លុះត្រាតែចំណុចនេះ មានសមាសធាតុសំខាន់ដូចជា៖ ព័ត៌មានផ្ទាល់ខ្លួន ប្រវត្តិការងារ ប្រវត្តិនៃការបណ្ដុះបណ្ដាល ប្រវត្តិស្នាដៃការងារ។

➢ ការគ្រប់គ្រង និងការដោះស្រាយវិវាទក្នុងអង្គភាព

- ***សេចក្ដីពន្យល់៖*** សំដៅដល់ការរៀបចំគោលការណ៍ នីតិវិធី និងការអនុវត្តការដោះស្រាយវិវាទនៅក្នុងមណ្ឌលសុខភាពដើម្បីកាត់បន្ថយទំនាស់ រក្សាបានសាមគ្គីភាពផ្ទៃក្នុង និងបង្កើនប្រសិទ្ធភាពការងាររបស់មណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)សេចក្ដីសម្រេចបង្កើតក្រុមការងារដើម្បីគ្រប់គ្រង និងដោះស្រាយវិវាទ ២)របាយការណ៍ដោះស្រាយវិវាទ និង៣)សម្ភាសន៍ជាមួយអ្នកគ្រប់គ្រង និងមន្ត្រីពាក់ព័ន្ធនៅក្នុងមណ្ឌលសុខភាពអំពីការដោះស្រាយវិវាទក្នុងអង្គភាព។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានក្រុមការងារដើម្បីគ្រប់គ្រង និងដោះស្រាយវិវាទ |
| ពិន្ទុ ១ | មានវិធីសាស្ត្រ ឬនីតិវិធី ឬគោលការណ៍ដើម្បីដោះស្រាយវិវាទ |
| ពិន្ទុ ១ | មានកិច្ចប្រជុំពង្រឹងសាមគ្គីភាពជាទៀងទាត់ ដើម្បីទប់ស្កាត់និងដោះស្រាយទំនាស់ |
| ពិន្ទុ ២ | មិនដែលមានវិវាទក្នុងមណ្ឌលសុខភាព |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ៤.២ ការអភិវឌ្ឍធនធានមនុស្ស (២៥ពិន្ទុ)

### ៤.២.១ ការរៀបចំផែនការអភិវឌ្ឍន៍ធនធានមនុស្ស (៥ពិន្ទុ)

➢ មានផែនការអភិវឌ្ឍន៍ធនធានមនុស្ស

- ***សេចក្ដីពន្យល់៖*** សំដៅដល់ឯកសារដែលពិពណ៌នាអំពីសកម្មភាព និងយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍធនធានមនុស្ស ឆ្លើយតបនឹងតម្រូវការការងាររបស់មណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការអភិវឌ្ឍន៍ធនធានមនុស្ស ២)របាយការណ៍ប្រជុំពិគ្រោះយោបល់ និងអនុម័តផែនការអភិវឌ្ឍន៍ធនធានមនុស្ស និង៣)របាយការណ៍ស្ដីពីការបណ្ដុះបណ្ដាល។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានផែនការអភិវឌ្ឍន៍ធនធានមនុស្ស |
| ពិន្ទុ ១ | មានការសិក្សាអំពីតម្រូវការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីក្នុងអង្គភាព |

| | |
|---|---|
| ពិន្ទុ ១ | មានការចូលរួមពិគ្រោះយោបល់ជាមួយមន្ត្រី និងភាគីពាក់ព័ន្ធក្នុងការរៀបចំផែនការអភិវឌ្ឍន៍ធនធានមនុស្ស |
| ពិន្ទុ ១ | ការអនុវត្តការអភិវឌ្ឍធនធានមនុស្សតាមផែនការដែលបានកំណត់ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ៤.២.២ ការអភិវឌ្ឍ និងការប្រើប្រាស់ធនធានមនុស្សដែលទទួលបានការបណ្តុះបណ្តាល (២០ពិន្ទុ)

➢ ការគាំទ្រនិងលើកទឹកចិត្តមន្ត្រីឱ្យទទួលបានការបណ្តុះបណ្តាល

- ***សេចក្តីពន្យល់៖*** សំដៅដល់ការខិតខំប្រឹងប្រែងរបស់អ្នកគ្រប់គ្រងអង្គភាពក្នុងការស្វែងរកមធ្យោបាយ និងកៀរគរធនធានដើម្បីលើកទឹកចិត្ត និងគាំទ្រដល់ការបណ្តុះបណ្តាលរបស់មន្ត្រីមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យ ១)របាយការណ៍ស្តីពីការបណ្តុះបណ្តាលទាំងក្នុង និងក្រៅអង្គភាព និង២)សម្ភាសន៍ជាមួយអ្នកគ្រប់គ្រង ឬមន្ត្រីអំពីការគាំទ្រនិងលើកទឹកចិត្តដើម្បីទទួលបានការបណ្តុះបណ្តាល។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មន្ត្រីក្នុងមណ្ឌលសុខភាពបានចូលរួមវគ្គបណ្តុះបណ្តាល |
| ពិន្ទុ ២ | ផ្តល់ឱកាស និងការគាំទ្រដល់មន្ត្រីទៅរៀនបន្ថែម |
| ពិន្ទុ ២ | ស្វែងរកនិងផ្សព្វផ្សាយអាហារូបករណ៍ ឬការកៀរគរធនធានពីដៃគូដើម្បីគាំទ្រដល់ការបណ្តុះបណ្តាល |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ការប្រើប្រាស់វិធីសាស្ត្រផ្សេងៗដើម្បីផ្តល់ការបណ្តុះបណ្តាល

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរៀបចំ និងអនុវត្តការបណ្តុះបណ្តាលក្នុងទម្រង់ផ្សេងៗដើម្បីផ្តល់ឱកាសឱ្យមន្ត្រីទទួលបានការបណ្តុះបណ្តាល។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍ស្តីពីការបណ្តុះបណ្តាលទាំងក្នុង និងក្រៅអង្គភាព ២)សម្ភាសន៍ជាមួយអ្នកគ្រប់គ្រង ឬមន្ត្រីអំពីការគាំទ្រនិងលើកទឹកចិត្តដើម្បីទទួលបានការបណ្តុះបណ្តាល និង៣)របាយការណ៍នៃកិច្ចប្រជុំផ្សព្វផ្សាយនៃវិធីសាស្ត្រ ឬការណែនាំថ្មីៗពាក់ព័ន្ធនឹងការគាំពារសុខភាពដែលទទួលបានពីក្រសួង និងមន្ទីរសុខាភិបាល។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | ការផ្សព្វផ្សាយនូវវិធីសាស្ត្រ ឬការណែនាំថ្មីៗពាក់ព័ន្ធនឹងការគាំពារសុខភាពដែលទទួលបានពីក្រសួង និងមន្ទីរសុខាភិបាល |
| ពិន្ទុ ១ | មានការរៀបចំការបណ្តុះបណ្តាល និងបញ្ជូនមន្ត្រីទទួលការបណ្តុះបណ្តាលនៅក្រៅស្ថាប័ន |

| | |
|---|---|
| ពិន្ទុ ១ | ការបង្ហឹកដោយផ្ទាល់ |
| ពិន្ទុ ១ | មានការចែករំលែកចំណេះដឹងនិងបទពិសោធន៍ពីបុគ្គលិកសុខាភិបាលទាំងក្នុងទាំងក្រៅស្ថាប័ន |
| ពិន្ទុ ១ | ការរៀបចំទស្សនៈកិច្ចសិក្សាក្នុង និងក្រៅប្រទេស |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ការវាយតម្លៃលទ្ធផលទទួលបានពីការបណ្តុះបណ្តាល

- ***សេចក្តីពន្យល់៖*** សំដៅដល់មណ្ឌលសុខភាពមានការសិក្សា និងវាយតម្លៃលទ្ធផលទទួលបានពីការបណ្តុះបណ្តាល និងការបញ្ជូនមន្ត្រីទៅទទួលបានការបណ្តុះបណ្តាល និងបានប្រើប្រាស់លទ្ធផលនៃការវាយតម្លៃទាំងនោះសម្រាប់ការរៀបចំនិងកែលម្អផែនការ និងការអនុវត្តការបណ្តុះបណ្តាល។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍ស្តីពីការវាយតម្លៃលទ្ធផលនៃការបណ្តុះបណ្តាល និង២)ការសម្ភាសជាមួយអ្នកគ្រប់គ្រង និងមន្ត្រីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានការសិក្សាវាយតម្លៃពីលទ្ធផលទទួលបានពីការបណ្តុះបណ្តាល |
| ពិន្ទុ ១ | ការបណ្តុះបណ្តាលអនុវត្តតាមផែនការដែលបានគ្រោងទុក |
| ពិន្ទុ ១ | បានប្រើប្រាស់លទ្ធផលនៃការវាយតម្លៃលទ្ធផលទទួលបានពីការបណ្តុះបណ្តាលសម្រាប់រៀបចំនិងកែលម្អផែនការបណ្តុះបណ្តាល |
| ពិន្ទុ ១ | បានប្រើប្រាស់លទ្ធផលនៃការវាយតម្លៃលទ្ធផលទទួលបានពីការបណ្តុះបណ្តាលសម្រាប់កែលម្អវិធីសាស្ត្រនៃការបណ្តុះបណ្តាល |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ការអភិវឌ្ឍសមត្ថភាពភាពជាអ្នកដឹកនាំ

- ***សេចក្តីពន្យល់៖*** សំដៅដល់ការពង្រឹង និងការលើកកម្ពស់សមត្ថភាពភាពជាអ្នកដឹកនាំក្នុងការបំពេញការងារដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៅក្នុងមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍ស្តីពីការបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ និង២)ការសម្ភាសជាមួយអ្នកគ្រប់គ្រង និងមន្ត្រីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | គណៈគ្រប់គ្រងបានចូលរួមវគ្គបណ្តុះបណ្តាលសមត្ថភាពភាពជាអ្នកដឹកនាំ |
| ពិន្ទុ ១ | មន្ត្រីបានចូលរួមវគ្គបណ្តុះបណ្តាលសមត្ថភាពភាពជាអ្នកដឹកនាំ |

| | |
|---|---|
| ពិន្ទុ ១ | មានការចែករំលែកចំណេះដឹងអំពីភាពជាអ្នកដឹកនាំដល់មន្ត្រីក្នុងអង្គភាព |
| ពិន្ទុ ១ | មានការផ្តល់សិទ្ធិក្នុងការសម្រេចចិត្តលើកិច្ចការនានាសមស្របទៅនឹងស្ថានភាពរបស់អង្គភាព |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

# ផ្នែកទី៥៖ ការរៀបចំ និងកែលម្អបរិស្ថានអង្គភាព

## ៥. ការរៀបចំ និងកែលម្អបរិស្ថានអង្គភាព (១០០ពិន្ទុ)

ការកំណត់ និងការវាយតម្លៃផ្នែកទី៥ ស្តីពីការរៀបចំ និងកែលម្អបរិស្ថានអង្គភាពគឺធ្វើឡើងក្នុងគោលបំណងជានាការដាក់បញ្ចូលការប្រតិបត្តិមេត្រីភាពបរិស្ថាន នៅតាមអង្គភាពផ្តល់សេវាសាធារណៈក្នុងវិស័យសុខាភិបាល។ លក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃនៅក្នុងផ្នែកនេះ នឹងធ្វើឱ្យមណ្ឌលសុខភាពបង្ហាញពីភាពគំរូនៃការប្រតិបត្តិមេត្រីភាពបរិស្ថាននៅក្នុងសហគមន៍ សំដៅឈានទៅសម្រេចបាននូវការគ្រប់គ្រងសំណល់រឹង-សំរាម ការគ្រប់គ្រងសំណល់រាវ ការគ្រប់គ្រងផ្សែង ការថែរក្សាជីវៈចម្រុះឱ្យបានប្រសើរស្របតាមគោលការណ៍មេត្រីភាពបរិស្ថាន ព្រមទាំងជាវេទិកាសម្រាប់អប់រំបំផុសដល់សាធារណជនឱ្យចូលរួមចំណែកក្នុងការថែរក្សាអនាម័យបរិស្ថាននៅតាមសហគមន៍ និងលំនៅដ្ឋានរបស់ពួកគេ។

នៅក្នុងផ្នែកនៃការរៀបចំ និងកែលម្អបរិស្ថានមណ្ឌលសុខភាព មានពិន្ទុសរុបចំនួន១០០ពិន្ទុ ដែលមានលក្ខណៈវិនិច្ឆ័យរងចំនួន៤ គឺ៖

១. ទស្សនវិស័យ និងសកម្មភាពមេត្រីភាពបរិស្ថាន(មានភាពស្អាត និងភាពបៃតងនៅក្នុងបរិវេណមណ្ឌលសុខភាព) (១០ពិន្ទុ)

២. ការបញ្ជ្រាបការយល់ដឹង និងអនុវត្តន៍អនាម័យបរិស្ថាន (២០ពិន្ទុ)

៣. មេត្រីភាពបរិស្ថាននៅក្នុងបរិវេណមណ្ឌលសុខភាព (៣០ពិន្ទុ)

៤. ការគ្រប់គ្រងសំណល់នៅមណ្ឌលសុខភាព (៤០ពិន្ទុ)

## ៥.១ ទស្សនវិស័យ និងសកម្មភាពមេត្រីភាពបរិស្ថាន(មានភាពស្អាត និងភាពបៃតងនៅក្នុងបរិវេណមណ្ឌលសុខភាព) (១០ពិន្ទុ)

### ៥.១.១ ការអនុវត្តទស្សនវិស័យ និងសកម្មភាពមេត្រីភាពបរិស្ថាន (១០ពិន្ទុ)

➢ មានទស្សនវិស័យ មានការរៀបចំនិងអនុវត្តសកម្មភាពមេត្រីភាពបរិស្ថាននៅក្នុងមណ្ឌលសុខភាព

- ***សេចក្តីពន្យល់៖*** សំដៅដល់ផែនការយុទ្ធសាស្ត្រ ឬផែនការសកម្មភាពរបស់មណ្ឌលសុខភាព ដែលមានគូសបញ្ជាក់ពីវត្ថុបំណង និងសកម្មភាពនៃការលើកកម្ពស់មេត្រីភាពបរិស្ថាននៅក្នុងមណ្ឌលសុខភាព ព្រមទាំងអនុវត្តសកម្មភាពមេត្រីភាពបរិស្ថាននៅក្នុងមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការសកម្មភាពប្រចាំឆ្នាំ ឬផែនការយុទ្ធសាស្ត្ររបស់មណ្ឌលសុខភាព ឬឯកសារផ្សេងៗទៀតដែលបង្ហាញពីគំនិតផ្តួចផ្តើម ពីផែនការសកម្មភាពដែលបម្រុងនឹងអនុវត្ត និង២)សកម្មភាពដែលបានអនុវត្តនិងកំពុងបន្តអនុវត្តដើម្បីលើកកម្ពស់មេត្រីភាពបរិស្ថាននៅក្នុងមណ្ឌលសុខភាព។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានឯកសារ ឬផែនការមេត្រីភាពបរិស្ថានសម្រាប់មណ្ឌលសុខភាព |
| ពិន្ទុ ១ | មានកាលវិភាគធ្វើអនាម័យបរិស្ថាននៅក្នុងបរិវេណមណ្ឌលសុខភាព |
| ពិន្ទុ ១ | មានយន្តការសម្រាប់ធ្វើអនាម័យបរិស្ថាន |
| ពិន្ទុ ១ | មានបទបញ្ជាផ្ទៃក្នុងស្តីពីសកម្មភាពមេត្រីភាពបរិស្ថាន |
| ពិន្ទុ ១ | មណ្ឌលសុខភាពមានអនាម័យ និងរក្សាបានភាពស្អាត និងបៃតងជានិច្ច |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ការរៀបចំបរិវេណមណ្ឌលសុខភាព និងហេដ្ឋារចនាសម្ព័ន្ធបៃតងមណ្ឌលសុខភាពដែលមានមេត្រីភាពបរិស្ថាន

- ***សេចក្តីពន្យល់៖*** សំដៅដល់មណ្ឌលសុខភាពបានរៀបចំហេដ្ឋារចនាសម្ព័ន្ធបៃតង ដែលឆ្លើយតបទៅនឹងបរិបទមេត្រីភាពបរិស្ថាន និងបានធ្វើសកម្មភាពលើកកម្ពស់មេត្រីភាពបរិស្ថាននៅក្នុងបរិវេណមណ្ឌលសុខភាពរបស់ខ្លួនជាប្រចាំ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ទិដ្ឋភាពទូទៅនៃការរៀបចំហេដ្ឋារចនាសម្ព័ន្ធបៃតងទៅតាមនិយាមមេត្រីភាពបរិស្ថាន(រំហូរខ្យល់និងពន្លឺ លំហបៃតង ការទុកដាក់សំណល់ប្រើប្រាស់ថាមពលស្អាត)។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានរៀបចំជាសួនច្បារ ឬអភិរក្សដើរៈចម្រុះក្នុងមណ្ឌលសុខភាព |

| | |
|---|---|
| ពិន្ទុ ១ | មានទីតាំងទុកដាក់សំណល់រឹង រាវ ឡដុតសំណល់ ឡកប់សុក ...ល។ បានតាំងនៅកន្លែងសមស្របមិនបង្កហានិភ័យដល់បុគ្គលិកនិងអ្នកប្រើប្រាស់សេវា |
| ពិន្ទុ ១ | មានពន្លឺគ្រប់គ្រាន់និងរំហូរខ្យល់បានល្អនៅផ្ទៃខាងក្នុងអាគារ |
| ពិន្ទុ ១ | មានប្រើប្រាស់ថាមពលស្អាត(មានប្រើប្រាស់ថាមពលសូឡា អំពូលសន្សំសំចៃថាមពល...) |
| ពិន្ទុ ១ | មានចែកផ្ទៃរុក្ខជាតិបៃតង/លំហបៃតងនិងផ្ទៃសួន និងថែទាំលំហបៃតងបានប្រសើរ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ៥.២ ការបញ្ជ្រាបការយល់ដឹង និងអនុវត្តន៍អនាម័យបរិស្ថាន (២០ពិន្ទុ)

### ៥.២.១ ការអប់រំ និងបណ្តុះបណ្តាលអំពីមេត្រីភាពបរិស្ថាន (១០ពិន្ទុ)

➢ <u>មានកម្មវិធីអប់រំបណ្តុះបណ្តាលការគ្រប់គ្រងបរិស្ថានប្រកបដោយសុវត្ថិភាព និងមេត្រីភាពដល់បុគ្គលិកនិងគ្រូពេទ្យ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការបណ្តុះបណ្តាលស្តីពីបរិស្ថានដែលរៀបចំឡើងដោយមណ្ឌលសុខភាព ឬអង្គភាពផ្សេងទៀត ដល់បុគ្គលិកនិងគ្រូពេទ្យ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ មានការចងក្រងឯកសារ ឬបទបង្ហាញស្តីពីការអប់រំបណ្តុះបណ្តាលអំពីការគ្រប់គ្រងបរិស្ថាន ឬរបាយការណ៍ស្តីពីការរៀបចំវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងមេត្រីភាពបរិស្ថាន ឬរបាយការណ៍ចូលរួមវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងបរិស្ថានដែលរៀបចំដោយអង្គភាពនានា។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | បុគ្គលិក ឬគ្រូពេទ្យបានទទួលការបណ្តុះបណ្តាល |
| ពិន្ទុ ១ | មានកម្មវិធីបណ្តុះបណ្តាល ឯកសារ និងរបាយការណ៍ស្តីពីការបណ្តុះបណ្តាលអំពីអនាម័យបរិស្ថាននិងការគ្រប់គ្រងបរិស្ថានដល់បុគ្គលិកពេទ្យ |
| ពិន្ទុ ១ | មានការអនុវត្តការទុកដាក់សំណល់មណ្ឌលសុខភាព ឱ្យបានត្រឹមត្រូវតាមប្រភេទ (ធុងសំណល់) |
| ពិន្ទុ ១ | បុគ្គលិក ឬគ្រូពេទ្យមានការយល់ដឹងអំពីការញែកសំណល់មណ្ឌលសុខភាពតាមប្រភេទ(សម្ភាសន៍) |
| ពិន្ទុ ១ | មានការផ្សព្វផ្សាយ ឬណែនាំបន្ថែមពីវិធានការបង្ការនិងទប់ស្កាត់ជំងឺឆ្លង |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ មានកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីអនាម័យបរិស្ថានដល់អ្នកប្រើប្រាស់សេវានៅក្នុងមណ្ឌលសុខភាព

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរៀបចំកម្មវិធីផ្សព្វផ្សាយអប់រំ និងជំរុញការប្រតិបត្តិអនាម័យបរិស្ថានដល់អ្នកប្រើប្រាស់សេវា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍ស្តីពីការរៀបចំការផ្សព្វផ្សាយអំពីអនាម័យបរិស្ថាន ២)ឯកសារបោះពុម្ពផ្សាយ ឬផលិតស្តីពីអនាម័យបរិស្ថាន និង៣)ការប្រតិបត្តិអនាម័យបរិស្ថានរបស់អ្នកប្រើប្រាស់សេវា(ការទុកដាក់សំរាម អនាម័យបន្ទប់ក្រោយសម្រាល បន្ទប់ទឹក...)។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | អ្នកប្រើប្រាស់សេវាបានអនុវត្តវិធានការអនាម័យបរិស្ថាននៅក្នុងមណ្ឌលសុខភាព (អង្កេត) |
| ពិន្ទុ ១ | អ្នកប្រើប្រាស់សេវាមានការយល់ដឹងអំពីវិធានការថែរក្សាអនាម័យបរិស្ថាននៅក្នុងមណ្ឌលសុខភាព (សម្ភាសន៍) |
| ពិន្ទុ ១ | មានបិទ និង/ឬចាក់ផ្សាយ (ខ្លឹមសារថ្មីស្របតាមស្ថានភាពបច្ចុប្បន្ន) ឯកសារផ្សព្វផ្សាយស្តីពីការថែរក្សាឬប្រតិបត្តិអនាម័យបរិស្ថាននៅក្នុងមណ្ឌលសុខភាព(អង្កេត) |
| ពិន្ទុ ១ | មានបិទ និង/ឬចាក់ផ្សាយឯកសារផ្សព្វផ្សាយស្តីពីការថែរក្សាឬប្រតិបត្តិអនាម័យបរិស្ថាននៅក្នុងមណ្ឌលសុខភាព(អង្កេត) |
| ពិន្ទុ ១ | មានរបាយការណ៍ស្តីពីការលើកកម្ពស់ការយល់ដឹងអំពីអនាម័យបរិស្ថានដល់អ្នកប្រើប្រាស់សេវា(ឧទាហរណ៍៖ វេទិកាសុខភាព ឬការផ្តល់ព័ត៌មានដល់ភូមិឃុំ ឬកម្មវិធីអប់រំសុខភាពនៅមណ្ឌលសុខភាព...) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ៥.២.២ ការអនុវត្តអនាម័យបរិស្ថាន (១០ពិន្ទុ)

➢ ការណែនាំពីភាពស្អាត និងការដឹកនាំបុគ្គលិកសម្អាតបរិស្ថាន នៅក្នុងបរិវេណអង្គភាពផ្តល់សេវា

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរៀបចំយុទ្ធនាការ ឬសកម្មភាពធ្វើអនាម័យរបស់មណ្ឌលសុខភាពសម្រាប់លើកកម្ពស់សោភ័ណ្ឌភាពនៅក្នុងបរិវេណមណ្ឌលសុខភាព ឬសហគមន៍។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)កម្មវិធីការងារ ឬកាលវិភាគសម្រាប់ធ្វើអនាម័យបរិស្ថានប្រចាំឆ្នាំ ២)ភាពស្អាតក្នុងបរិវេណមណ្ឌលសុខភាព និង៣)យុទ្ធនាការឬសកម្មភាពធ្វើអនាម័យបរិស្ថាននៅបរិវេណមណ្ឌលសុខភាព ឬសហគមន៍ជុំវិញមណ្ឌលសុខភាព។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានកម្មវិធី ឬកាលវិភាគសម្រាប់ធ្វើអនាម័យនៅមណ្ឌលសុខភាព(ពិនិត្យលើផែនការការងារ) |

| | |
|---|---|
| ពិន្ទុ ១ | បានធ្វើយុទ្ធនាការឬសកម្មភាពធ្វើអនាម័យបរិស្ថាននៅក្នុងមណ្ឌលសុខភាព ឬសហគមន៍ជុំវិញមណ្ឌលសុខភាព( ពិនិត្យរបាយការណ៍ ) |
| ពិន្ទុ ១ | មិនមានសំណល់ពេញហៀរធុងសំរាម សំរាមត្រូវបានវេចខ្ចប់និងទុកដាក់បានល្អ(អង្កេត) |
| ពិន្ទុ ១ | មានការកាត់ស្មៅ មានរុក្ខជាតិដុះល្អ និងមានការថែទាំជាប្រចាំ(អង្កេត) |
| ពិន្ទុ ១ | ទីធ្លាសួនច្បារស្អាត គ្មានសំណល់រាយប៉ាយ(អង្កេត) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>ការណែនាំអ្នកប្រើប្រាស់សេវាឱ្យចេះទុកដាក់សំណល់រឹង-សំរាមក្នុងធុង</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់កម្មវិធីអប់រំផ្សព្វផ្សាយដល់អ្នកប្រើប្រាស់សេវាស្តីពីការអនុវត្តវិធានការញែក និងទុកដាក់សំណល់រឹង-សំរាម( សំណល់ទូទៅ ) ទៅតាមប្រភេទនៅក្នុងមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ឯកសារអប់រំផ្សព្វផ្សាយ( ខិតប័ណ្ណ ផ្ទាំងរូបភាព ឯកសារសោតទស្សន៍ ) និង២)របាយការណ៍ ឬរូបភាពដែលបង្ហាញអំពីសកម្មភាពអប់រំផ្សព្វផ្សាយការញែក និងទុកដាក់សំណល់រឹង-សំរាម( សំណល់ទូទៅ ) នៅក្នុងមណ្ឌលសុខភាពដល់អ្នកប្រើប្រាស់សេវា។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានឯកសារអប់រំផ្សព្វផ្សាយស្តីពីការញែក និងទុកដាក់សំណល់រឹង-សំរាម( សំណល់ទូទៅ) តាមប្រភេទ( ១.សំបកដប ២.ផ្លាស្ទិកវេចខ្ចប់ ៣.សំណល់រលួយ) (ឯកសារបោះពុម្ពផ្សាយ បាន១ពិន្ទុ, ឯកសារសោតទស្សន៍ បាន១ពិន្ទុ) |
| ពិន្ទុ ៣ | របាយការណ៍ ឬរូបភាពដែលបង្ហាញអំពីសកម្មភាពអប់រំផ្សព្វផ្សាយការញែក និងទុកដាក់សំណល់រឹង-សំរាម(សំណល់ទូទៅ) (ផ្សព្វផ្សាយក្រោម៣ដងក្នុង១ឆ្នាំ បាន១ពិន្ទុ, ផ្សព្វផ្សាយពី៤-៦ដង ក្នុង១ឆ្នាំ បាន២ពិន្ទុ និងផ្សព្វផ្សាយចាប់ពី៧ដងឡើងទៅក្នុង១ឆ្នាំ បាន៣ពិន្ទុ) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ៥.៣ មេត្រីភាពបរិស្ថាននៅក្នុងបរិវេណមណ្ឌលសុខភាព (៣០ពិន្ទុ)

### ៥.៣.១ មេត្រីភាពបរិស្ថាននៅក្នុងមណ្ឌលសុខភាព (១៥ពិន្ទុ)

➢ <u>ការថែរក្សាបរិស្ថាននៅក្នុងបរិវេណមណ្ឌលសុខភាពបានស្អាតល្អ និងមានភាពបៃតង</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការថែរក្សាបរិស្ថាន និងធ្វើសកម្មភាពមេត្រីភាពបរិស្ថាននៅក្នុងមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)យន្តការថែរក្សាបរិស្ថាននិងធ្វើអនាម័យ

(មានបែងចែកវេនសម្អាតដល់បុគ្គលិកអនាម័យ ឬគ្រូពេទ្យ) ២)កម្មវិធីការងារច្បាស់លាស់ស្តីពីការធ្វើសកម្មភាពថែរក្សាសោភ័ណ្ឌភាពមណ្ឌលសុខភាព និង៣)ការធ្វើសកម្មភាពមេត្រីភាពបរិស្ថាន (ការសន្សំសំចៃទឹក ថាមពលស្អាត ទុកដាក់សំណល់វេជ្ជសាស្រ្ត...)។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានបែងចែកវេនសម្អាតដល់បុគ្គលិកអនាម័យ ឬគ្រូពេទ្យ |
| ពិន្ទុ ២ | មានការរៀបចំលំហបៃតង ឬសួន ឬថែទាំអគារបានល្អ មានពន្លឺនិងខ្យល់ចេញចូលល្អ មិនទុកឱ្យស្មៅ ឬរុក្ខជាតិដុះពាសវាលពាសកាលដោយមិនមានការថែទាំបានល្អ ក្លាយជាជម្រកមូស និងសត្វចង្រៃផ្សេងៗ |
| ពិន្ទុ ១ | មានផែនការនិងអនុវត្តការសន្សំសំចៃទឹក ការប្រើប្រាស់ថាមពលស្អាត |
| ពិន្ទុ ១ | មានការវេចខ្ចប់សំណល់វេជ្ជសាស្រ្ត និងមានពាង/ដេប៉ូទុកដាក់សំណល់ សម្រាប់ដឹកចេញទៅក្រៅ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>មានធុងសំរាមសម្រាប់សំណល់រឹង-សំរាម(សំណល់ទូទៅ)សមស្រប និងមានអនាម័យ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរៀបចំឱ្យមានធុងទុកដាក់សំណល់រឹង-សំរាម(សំណល់ទូទៅ) ទៅតាមប្រភេទសំណល់ និងលើកកម្ពស់ការញែក និងការទុកដាក់សំណល់រឹង-សំរាមទៅតាមប្រភេទនៅក្នុងមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ធុងទុកដាក់សំណល់រឹង-សំរាម (សំណល់ទូទៅ) ទៅតាមប្រភេទ(១.សំបកដប ២.ផ្លាស្ទិកវេចខ្ចប់ ៣.សំណល់រលួយ) ២)ការអនុវត្តការញែកនិងទុកដាក់សំណល់រឹង-សំរាមទៅតាមប្រភេទ និង៣)ការវេចខ្ចប់និងទុកដាក់សំណល់បណ្តោះអាសន្ន(ប្រមូលសំរាមចេញពីធុង)។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានធុងសំរាមសម្រាប់ទុកដាក់សំណល់ទូទៅ (១.សំបកដប ២.ផ្លាស្ទិកវេចខ្ចប់ ៣.សំណល់រលួយ) |
| ពិន្ទុ ២ | សំណល់រឹង-សំរាមត្រូវបានទុកដាក់ក្នុងធុងត្រឹមត្រូវតាមប្រភេទរបស់វា(១.សំបកដប ២.ផ្លាស្ទិកវេចខ្ចប់ ៣.សំណល់រលួយ) |
| ពិន្ទុ ១ | សំណល់រឹង-សំរាមត្រូវបានវេចខ្ចប់និងទុកដាក់សំណល់បណ្តោះអាសន្ន |
| ពិន្ទុ ១ | សំរាមត្រូវបានយកចេញជាទៀតទាត់ សម្រាប់ទុកដាក់ចុងក្រោយ(តំបន់ដែលគ្មានសេវាប្រមូលសំណល់ ត្រូវទុកដាក់ខ្លួនឯង, តំបន់ដែលមានសេវាប្រមូលសំណល់ត្រូវបញ្ជូនឱ្យភ្នាក់ងារប្រមូលសំណល់) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ទីតាំងអង្គុយលំហែមានអនាម័យបរិស្ថាន និងបរិយាកាសល្អ

- *សេចក្តីពន្យល់៖* សំដៅដល់ទីតាំងអង្គុយលំហែនៅមណ្ឌលសុខភាពមានផាសុកភាពនិងបរិយាកាសល្អដល់អ្នកប្រើប្រាស់សេវា។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ១)កន្លែងអង្គុយលំហែ និង២)ទីធ្លា/លំហបៃតងនៅកន្លែងអង្គុយលំហែ។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ៣ | មានកន្លែងអង្គុយលំហែ សម្រាប់អ្នកប្រើប្រាស់សេវា(សមាមាត្រកន្លែងអង្គុយ កៅអី...) លំហែទៅនឹងអ្នកប្រើប្រាស់សេវា៖ ពី១ភាគរយ ដល់៣០ភាគរយ បាន១ពិន្ទុ, ៣១ភាគរយ ដល់៦០ភាគរយ បាន២ពិន្ទុ និងចាប់ពី៦១ភាគរយឡើង បាន៣ពិន្ទុ) |
| ពិន្ទុ ២ | ទីតាំងអង្គុយលំហែមានផាសុកភាព អនាម័យល្អ និងមានបរិស្ថានប្រសើរដោយមានដាំដើមឈើជាម្លប់ឬលម្អនៅក្នុងបរិវេណមណ្ឌលសុខភាព |
| ពិន្ទុ ០ | គ្មានកន្លែងអង្គុយលំហែ |

### ៥.៣.២ បន្ទប់ទឹក និងបង្គន់ប្រកបដោយអនាម័យបរិស្ថានល្អ (១៥ពិន្ទុ)

➢ មានបែងចែកបន្ទប់ទឹក និងបង្គន់សម្រាប់បុរស ស្ត្រី និងជនពិការ

- *សេចក្តីពន្យល់៖* សំដៅដល់ការបែងចែកបន្ទប់ទឹក និងបង្គន់រវាងបុរស ស្ត្រី និងជនពិការនៅមណ្ឌលសុខភាព។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត)៖* ចំណុចត្រូវពិនិត្យគឺ ១)បន្ទប់ងូតទឹក ២)បង្គន់សម្រាប់បុរស ៣)បង្គន់សម្រាប់ស្ត្រី និង៤)បង្គន់/បន្ទប់ងូតទឹកសម្រាប់ជនពិការ។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ១ | បន្ទប់ងូតទឹកយ៉ាងតិច១ |
| ពិន្ទុ ១ | មានបង្គន់យ៉ាងតិច២(បុរស១ និង ស្ត្រី១, ករណីមានតែ១បាន ពិន្ទុ០) |
| ពិន្ទុ ១ | បង្គន់ស្ត្រីត្រូវមានធុងសំរាមសម្រាប់ដាក់សំណល់ឆ្លងរោគ |
| ពិន្ទុ ១ | បង្គន់/បន្ទប់ងូតទឹកមានទ្វារ និងគន្លឹះខ្ទាស់ត្រឹមត្រូវ |
| ពិន្ទុ ១ | បង្គន់/បន្ទប់ងូតទឹកសម្រាប់ជនពិការ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ការថែរក្សាអនាម័យនៅក្នុងបន្ទប់ទឹក និងបង្គន់អនាម័យ
  - ***សេចក្តីពន្យល់៖*** សំដៅដល់ការថែរក្សាអនាម័យនៅក្នុងបន្ទប់ទឹក និងបង្គន់អនាម័យនៅក្នុងមណ្ឌលសុខភាព។
  - ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)កាលវិភាគធ្វើអនាម័យបន្ទប់ទឹក/បង្គន់ ២)បុគ្គលិកអនាម័យ/បុគ្គលិកពេទ្យធ្វើអនាម័យ ៣)សម្ភារៈសម្រាប់ធ្វើអនាម័យបន្ទប់ទឹក/បង្គន់ និង ៤)ភាពស្អាតនៃបន្ទប់ទឹក/បង្គន់។
  - ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានកាលវិភាគធ្វើអនាម័យបន្ទប់ទឹក/បង្គន់ |
| ពិន្ទុ ១ | មានកន្លែងលាងដៃក្រោយចេញពីបង្គន់ មានសាប៊ូ និងមានកន្សែង ឬក្រដាសជូតដៃ |
| ពិន្ទុ ១ | មានបុគ្គលិកអនាម័យ/បុគ្គលិកពេទ្យធ្វើអនាម័យ |
| ពិន្ទុ ១ | មានសម្ភារៈសម្រាប់ធ្វើអនាម័យបន្ទប់ទឹក/បង្គន់(ថ្នាំសម្លាប់មេរោគ អំបោស សាប៊ូលាងបង្គន់...) |
| ពិន្ទុ ១ | បន្ទប់ទឹកនិងបង្គន់ មានអនាម័យល្អ(គ្មានក្លិនមិនល្អ) និងមានការសម្អាតជាប្រចាំ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- មានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់នៅក្នុងបង្គន់ និងបន្ទប់ទឹក
  - ***សេចក្តីពន្យល់៖*** សំដៅដល់បរិមាណទឹកស្អាតចាំបាច់ និងគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងបង្គន់និងបន្ទប់ទឹកនៅក្នុងមណ្ឌលសុខភាព។
  - ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ទឹកស្អាត ២)មានទឹកក្នុងធុង ឬអាងស្តុកទឹក(ក្នុងករណីគ្មានប្រព័ន្ធទឹកម៉ាស៊ីន) ៣)ការសន្សំសំចៃទឹក និង៤)អនាម័យអាងស្តុកទឹក។
  - ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | បន្ទប់ទឹកស្អាតមានអនាម័យនិងមានទឹកប្រើប្រាស់គ្រប់គ្រាន់ |
| ពិន្ទុ ១ | ត្រូវមានទឹក៣ភាគ៤នៃចំណុះធុង ឬអាងស្តុកទឹក |
| ពិន្ទុ ១ | មិនមានទឹកហូរហៀរចោលនៅក្នុងបន្ទប់ទឹក ឬបង្គន់ |
| ពិន្ទុ ១ | មានការលាងសម្អាតអាងស្តុកទឹកនៅក្នុងបន្ទប់ទឹក ឬបង្គន់ (ប្រសិនបើមានអាងតូចៗ) |
| ពិន្ទុ ០ | មិនមានទឹកប្រើប្រាស់គ្រប់គ្រាន់ |

## ៥.៤ ការគ្រប់គ្រងសំណល់នៅមណ្ឌលសុខភាព (៤០ពិន្ទុ)

### ៥.៤.១ ការគ្រប់គ្រងសំណល់រាវ (១០ពិន្ទុ)

➢ សំណល់រាវត្រូវបានធ្វើប្រព្រឹត្តកម្ម ឬបញ្ចូលទៅក្នុងប្រព័ន្ធលូមេ ឬអាងសិបទិក(អាងស្តុកសំណល់រាវ)

- ***សេចក្តីពន្យល់៖*** សំដៅដល់ការទប់ស្កាត់ការបំពុលបរិស្ថាន ជាពិសេសការបំពុលប្រភពទឹកសាធារណៈ តាមរយៈការធ្វើប្រព្រឹត្តកម្ម/សម្អាតសំណល់រាវ/ទឹកកខ្វក់/ទឹកសំអុយ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)អាងសិបទិក និង២)ស្រះទឹក។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | សំណល់រាវចេញពីអាងសិបទិក(អាងស្តុកសំណល់រាវ)ត្រូវបានបង្ហូរចូល៖ ស្រះទឹក (រៀបចំដោយមណ្ឌលសុខភាព) ទទួលសំណល់រាវដែលបានធ្វើប្រព្រឹត្តកម្មរួច ឬ អាងធ្វើប្រព្រឹត្តកម្មសំណល់រាវសំណល់និងដំណើរការបានល្អ |
| ពិន្ទុ ៤ | មានរៀបចំអាងសិបទិកដែលមានច្រើនដំណាក់ សម្រាប់សម្អាតសំណល់រាវមុនបញ្ចេញទៅប្រព័ន្ធលូមេសាធារណៈ ឬឱ្យជ្រាបចូលទៅក្នុងដី |
| ពិន្ទុ ៣ | មានរៀបចំអាងសិបទិក(មានមួយដំណាក់)ដែលមានជម្រាបទឹកចូលក្នុងដី |
| ពិន្ទុ ២ | បានបញ្ជូនសំណល់រាវទៅក្នុងប្រព័ន្ធលូមេសាធារណៈដោយមិនឆ្លងកាត់អាងសិបទិក |
| ពិន្ទុ ០ | មិនបានរៀបចំអ្វីទាំងអស់ ឬមានសំណល់រាវហូរពាសវាលពាសកាល |

➢ ការគ្រប់គ្រងសំណល់ទឹកលើដី/សំណល់ទឹកភ្លៀង

- ***សេចក្តីពន្យល់៖*** សំដៅដល់ការគ្រប់គ្រងសំណល់ទឹកលើដី/សំណល់ទឹកភ្លៀងនៅក្នុងបរិវេណមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)មានប្រឡាយ ឬចង្អូរបង្ហូរសម្រាប់រំដោះទឹកភ្លៀង ឬប្រព័ន្ធលូបង្ហូរ(មានគម្រប់ត្រឹមត្រូវ) ២)ការថែរក្សាប្រព័ន្ធលូបង្ហូរទឹកភ្លៀង និង៣)មិនមានថ្លុកឬកន្លែងដក់ទឹកក្នុងមណ្ឌលសុខភាព។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានធ្វើប្រព័ន្ធបង្ហូរសំណល់ទឹកភ្លៀង ឬមានចង្អូរសម្រាប់រំដោះទឹកភ្លៀង |
| ពិន្ទុ ២ | មានការគ្រប់គ្រងថែរក្សាប្រព័ន្ធបង្ហូរទឹកភ្លៀងមិនឱ្យមានសំណល់ទឹកភ្លៀងហូរពាសវាលពាសកាល |
| ពិន្ទុ ២ | មណ្ឌលសុខភាពមានសោភ័ណ្ឌភាពល្អគ្រកាល គ្មានថ្លុកដក់ទឹកកខ្វក់ ឬទឹកស្អុយ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ៥.៤.២ ការគ្រប់គ្រងសំណល់រឹង-សំរាម (សំណល់ទូទៅ) (៥ពិន្ទុ)

➢ មានវិធានការទុកដាក់សំណល់រឹង-សំរាមទៅតាមប្រភេទ

- ***សេចក្តីពន្យល់៖*** សំដៅដល់ការទុកដាក់ចុងក្រោយនូវសំណល់រឹង-សំរាម នៅក្នុងមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)សំណល់រឹង-សំរាមត្រូវបញ្ជូនទៅទីលានទុកដាក់ចុងក្រោយ (ដោយភ្នាក់ងារប្រមូលសំណល់ ឬដោយមណ្ឌលសុខភាព) និង២)សំណល់រលួយត្រូវបានកប់ ឬរក្សាទុកសម្រាប់ធ្វើជីកំប៉ុស្ត៍។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ៣ | សំណល់រឹង-សំរាមត្រូវបញ្ជូនទៅទីលានទុកដាក់ចុងក្រោយ(ដោយភ្នាក់ងារប្រមូលសំណល់ ឬដោយមណ្ឌលសុខភាព) |
| ពិន្ទុ ២ | សំណល់រលួយត្រូវបានកប់ ឬរក្សាទុកសម្រាប់ធ្វើជីកំប៉ុស្ត៍ ឬមានរោងធ្វើជីកំប៉ុស្ត៍ ឬមានការកែច្នៃសំណល់ប្រើឡើងវិញ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ៥.៤.៣ ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ (១៥ពិន្ទុ)

➢ គោលការណ៍ណែនាំ និងវិធានការសម្រាប់ញែក និងទុកដាក់សំណល់វេជ្ជសាស្ត្រតាមប្រភេទ

- ***សេចក្តីពន្យល់៖*** សំដៅដល់ការអនុវត្តការញែក និងទុកដាក់សំណល់វេជ្ជសាស្ត្រតាមប្រភេទឱ្យបានត្រឹមត្រូវ អនុលោមតាមគោលការណ៍ណែនាំ និងវិធានការ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ធុងដាក់សំណល់វេជ្ជសាស្ត្រ ២)ការទុកដាក់សំណល់ទៅតាមប្រភេទ និង៣)ការវេចខ្ចប់សំណល់ត្រឹមត្រូវតាមប្រភេទ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | ការបែងចែកធុងដាក់សំណល់វេជ្ជសាស្ត្រ |
| ពិន្ទុ ២ | ការទុកដាក់សំណល់វេជ្ជសាស្ត្រទៅតាមប្រភេទ |
| ពិន្ទុ ១ | ការវេចខ្ចប់សំណល់វេជ្ជសាស្ត្រត្រឹមត្រូវតាមប្រភេទ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ការទុកដាក់សំណល់សរីរាង្គ(សុក សាច់ ឈាម..ល។) សំណល់អំពូលថ្នាំ ផេះបាតឡ និងអនុវត្តន៍វិធានការនេះបានល្អ

- ***សេចក្តីពន្យល់៖*** សំដៅដល់ការទុកដាក់សំណល់សរីរាង្គ សំណល់អំពូលថ្នាំ និងផេះបាតឡ អនុលោមតាមវិធានការដែលបានកំណត់។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចដែលត្រូវពិនិត្យលើការទុកដាក់ចុងក្រោយ៖ ១)សំណល់សរីរាង្គ ២)សំណល់អំពូលថ្នាំ និង៣)ផេះបាតឡ។

- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ៣ | មានលូកប់សុក ឬសំណល់សរីរាង្គ |
| ពិន្ទុ ១ | មានរណ្តៅ ឬលូទុកដាក់សំណល់អំពូលថ្នាំ |
| ពិន្ទុ ១ | មានរណ្តៅ ឬលូទុកដាក់ផេះបាតឡ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ការបញ្ជូនសំណល់មុតស្រួចចេញទៅដុតនៅសេវាខាងក្រៅ

- *សេចក្តីពន្យល់៖* សំដៅដល់ការទុកដាក់សំណល់មុតស្រួចបណ្តោះអាសន្ន និងការបញ្ជូនចេញទៅដុតនៅសេវាខាងក្រៅ។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ១)ការទុកដាក់បណ្តោះអាសន្ន និង២)ការបញ្ជូនចេញ។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ៣ | មានរោងទុកដាក់សំណល់មុតស្រួចបណ្តោះអាសន្ន |
| ពិន្ទុ ២ | បញ្ជូនទៅស្រុកប្រតិបត្តិ ឬសេវាកម្មរបស់កាកបាទក្រហម ឬសេវាកម្មទទួលទុកដាក់សំណល់វេជ្ជសាស្ត្រ |
| ពិន្ទុ ០ | មិនមានឯកសារឬការអនុវត្តវិធានការទុកដាក់សំណល់មុតស្រួច |

## ៥.៤.៥ ការគ្រប់គ្រងការបំពុលខ្យល់នៅខាងក្នុង និងក្រៅអគារ (១០ពិន្ទុ)

➢ ការអនុវត្តគោលនយោបាយគ្មានផ្សែងបារីក្នុងមណ្ឌលសុខភាព

- *សេចក្តីពន្យល់៖* សំដៅដល់ការអនុវត្តគោលនយោបាយគ្មានផ្សែងបារីក្នុងមណ្ឌលសុខភាព។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ១)មានបម្រាមជក់បារី ២)គ្មានការលក់បារីក្នុងមណ្ឌលសុខភាព និង៣)គ្មានអ្នកជក់បារី/គ្មានកន្ទុយបារីក្នុងមណ្ឌលសុខភាព។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ២ | មានបម្រាមជក់បារី |
| ពិន្ទុ ១ | គ្មានការលក់បារីក្នុងមណ្ឌលសុខភាព |
| ពិន្ទុ ២ | គ្មានអ្នកជក់បារី/គ្មានកន្ទុយបារីក្នុងមណ្ឌលសុខភាព |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ គ្មានការបំពុលដោយផ្សែងតាមរយៈការដុតសំណល់នៅក្នុងបរិវេណមណ្ឌលសុខភាព

- ***សេចក្តីពន្យល់៖*** សំដៅដល់ការមិនមានការបំពុលដោយផ្សែងតាមរយៈការដុតសំណល់នៅក្នុងបរិវេណមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការរៀបចំឡបានល្អ ២)ដំណើរការឡបានល្អ ៣)ដំណើរការឡមិនឱ្យមានផ្សែងដុតសំណល់ហុយចូលក្នុងមណ្ឌលសុខភាព និង៤)គ្មានការដុតសំណល់រឹង-សំរាម(សំណល់ទូទៅ)ក្រៅឡ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | ការរៀបចំឡបានល្អ |
| ពិន្ទុ ២ | ដំណើរការឡបានល្អ |
| ពិន្ទុ ១ | ដំណើរការឡមិនឱ្យមានផ្សែងដុតសំណល់ហុយចូលក្នុងមណ្ឌលសុខភាព |
| ពិន្ទុ ១ | គ្មានការដុតសំណល់រឹង-សំរាម(សំណល់ទូទៅ)ក្រៅឡ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

# ផ្នែកទី៦៖ ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ

## ៦. ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ (៤០ពិន្ទុ)

ការកំណត់និងវាយតម្លៃលក្ខណៈវិនិច្ឆ័យស្តីពីទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ គឺដើម្បីធានាឱ្យមណ្ឌលសុខភាពមានដំណើរពេញលេញ និងជំរុញឱ្យមានទំនាក់ទំនល្អជាមួយប្រជាពលរដ្ឋ សហគមន៍ សប្បុរជន និងដៃគូអភិវឌ្ឍ។ ការផ្សារភ្ជាប់មណ្ឌលសុខភាពទៅនឹងប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ នឹងផ្តល់លទ្ធភាពឱ្យមណ្ឌលសុខភាពកៀរគរធនធានគាំទ្រទាំងផ្នែកបច្ចេកទេស ការលើកកម្ពស់គុណភាពសេវាសុខភាព ការអភិវឌ្ឍមណ្ឌលសុខភាព និងការផ្តល់ព័ត៌មានត្រឡប់ផ្សេងៗពីគ្រប់ភាគីពាក់ព័ន្ធ។

នៅក្នុងផ្នែកនៃទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ មានពិន្ទុសរុបចំនួន៤០ ដែលមានលក្ខណៈវិនិច្ឆ័យរងចំនួន១ គឺ៖

១. ការពង្រឹងទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ (៤០ពិន្ទុ)

## ៦.១ ការពង្រឹងទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ (៤០ពិន្ទុ)

### ៦.១.១ ការរៀបចំគណៈកម្មការ និងក្រុមការងារ (១០ពិន្ទុ)

➢ ការបង្កើតគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព

- ***សេចក្តីពន្យល់៖*** សំដៅដល់ការបង្កើតគណៈកម្មការដែលតម្រង់ទិសនៃការងារគ្រប់គ្រង និងផ្តល់យោបល់ដល់ក្រុមបុគ្គលិកសុខភាពដើម្បីធានាឱ្យសេវានៅមណ្ឌលសុខភាពតាមសំណុំសកម្មភាពអប្បរមារបស់ក្រសួងសុខាភិបាល ហើយប្រជាជននៅក្នុងតំបន់ទទួលខុសត្រូវនៃមណ្ឌលសុខភាពមានលទ្ធភាពចូលមកប្រើប្រាស់សេវាមណ្ឌលសុខភាពទាំងនោះ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)លិខិតបង្គាប់ការ ២)សមាសភាព និង ៣)ឯកសារ/កំណត់ហេតុដំណើរការរៀបចំបង្កើតឬធ្វើបច្ចុប្បន្នកម្មនៃគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព។ សមាសភាពសរុបយ៉ាងតិច៧នាក់ និងអាចលើសពីនេះទៅតាមចំនួនឃុំ/សង្កាត់ ហើយតម្រូវឱ្យជាចំនួនសេស។ សមាសភាពនៃគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាពរួមមាន៖ (១)តំណាងបុគ្គលិកមណ្ឌលសុខភាព (២)តំណាងក្រុមទ្រទ្រង់សុខភាពភូមិ (៣)ក្រុមប្រឹក្សាឃុំ ឬសង្កាត់។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានលិខិតបង្គាប់ការ(មានចុះហត្ថលេខា កាលបរិច្ឆេទ និងត្រា) |
| ពិន្ទុ ២ | សមាសភាពគណៈកម្មការតាមគោលការណ៍កំណត់ |
| ពិន្ទុ ១ | ឯកសារ/កំណត់ហេតុដំណើរការរៀបចំបង្កើត ឬធ្វើបច្ចុប្បន្នកម្ម |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ការបង្កើតក្រុមទ្រទ្រង់សុខភាពភូមិ

- ***សេចក្តីពន្យល់៖*** សំដៅដល់ការបង្កើតក្រុមសម្រាប់ផ្តល់ព័ត៌មានពីមណ្ឌលសុខភាពទៅសហគមន៍ និងពីសហគមន៍មកមណ្ឌលសុខភាពវិញ។ ការជ្រើសរើសក្រុមនេះតាមរយៈការបោះឆ្នោត ដោយសហគមន៍ មានសមាជិក២នាក់ ស្រី១នាក់ ប្រុស១នាក់ក្នុង១ភូមិ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)លិខិតបង្គាប់ការ ២)សមាសភាព និង ៣)ឯកសារ/កំណត់ហេតុដំណើរការរៀបចំបង្កើតឬធ្វើបច្ចុប្បន្នកម្មក្រុមទ្រទ្រង់សុខភាពភូមិ។ សមាជិករបស់ក្រុមទ្រទ្រង់សុខភាពភូមិនៃមណ្ឌលសុខភាពនីមួយៗមានយ៉ាងច្រើនបំផុត៣៥នាក់។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានលិខិតបង្គាប់ការ(មានចុះហត្ថលេខា កាលបរិច្ឆេទ និងត្រា) |
| ពិន្ទុ ២ | សមាសភាពក្រុមទ្រទ្រង់សុខភាពភូមិតាមគោលការណ៍កំណត់ |
| ពិន្ទុ ១ | ឯកសារ/កំណត់ហេតុដំណើរការរៀបចំបង្កើត ឬធ្វើបច្ចុប្បន្នកម្ម |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ៦.១.២ កិច្ចប្រជុំរបស់គណៈកម្មការ និងអនុគណៈកម្មការ (១០ពិន្ទុ)

➢ <u>គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាពមានដំណើរការពេញលេញ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់កិច្ចប្រជុំប្រចាំខែរបស់គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាពជាទៀងទាត់ ដោយមានការរៀបចំកំណត់ហេតុប្រជុំសម្រាប់ធ្វើជាមូលដ្ឋានក្នុងកិច្ចប្រជុំនាពេលបន្ទាប់ ហើយកំណត់ហេតុនេះត្រូវរក្សាទុកនៅមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ចំនួនដងនៃកិច្ចប្រជុំ និងរបាយការណ៍/កំណត់ហេតុ ២)ភាពពេញលេញនៃរបាយការណ៍/កំណត់ហេតុ(របៀបវារៈ កាលបរិច្ឆេទ ហត្ថលេខារបស់ប្រធានអង្គប្រជុំ...) និង៣)បញ្ជីវត្តមាននៃកិច្ចប្រជុំនីមួយៗដោយមានចុះហត្ថលេខារបស់សមាជិកនៃគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព (យ៉ាងតិចវត្តមាន ៧០ភាគរយ នៃសមាជិកទាំងអស់)។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ៣ | មានកិច្ចប្រជុំ និងរបាយការណ៍/កំណត់ហេតុ ជាប្រចាំ (មានរបាយការណ៍/កំណត់ហេតុ ១១ទៅ១២ដង ផ្តល់ពិន្ទុ៣, មានរបាយការណ៍/កំណត់ហេតុ ចាប់ពី៩ទៅ១០ដង ផ្តល់ពិន្ទុ២, មានរបាយការណ៍/កំណត់ហេតុ ចាប់ពី៦ទៅ៨ដង ផ្តល់ពិន្ទុ១) |
| ពិន្ទុ ១ | ភាពពេញលេញនៃរបាយការណ៍/កំណត់ហេតុ(របៀបវារៈ កាលបរិច្ឆេទ ហត្ថលេខារបស់ប្រធានអង្គប្រជុំ...) |
| ពិន្ទុ ១ | បញ្ជីវត្តមាននៃកិច្ចប្រជុំនីមួយៗដោយមានចុះហត្ថលេខារបស់សមាជិកនៃគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព (យ៉ាងតិចវត្តមាន ៧០ភាគរយ នៃសមាជិកទាំងអស់) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ពិនិត្យលើរបាយការណ៍/កំណត់ហេតុប្រជុំ ក្នុងឆ្នាំកន្លងមក។

➢ <u>ការរៀបចំកិច្ចប្រជុំរបស់ក្រុមទ្រទ្រង់សុខភាពភូមិរៀងរាល់ពីរខែម្តង</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់កិច្ចប្រជុំរបស់ក្រុមទ្រទ្រង់សុខភាពភូមិទៀងទាត់ជាប្រចាំ ដោយមានការរៀបចំកំណត់ហេតុប្រជុំនីមួយៗ ហើយកំណត់ហេតុនេះត្រូវរក្សាទុកនៅមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ចំនួនដងនៃកិច្ចប្រជុំ និងរបាយការណ៍/កំណត់ហេតុ ២)ភាពពេញលេញនៃរបាយការណ៍/កំណត់ហេតុ(របៀបវារៈ កាលបរិច្ឆេទ ហត្ថលេខារបស់ប្រធានអង្គប្រជុំ...) និង៣)បញ្ជីវត្តមាននៃកិច្ចប្រជុំនីមួយៗដោយមានចុះហត្ថលេខារបស់សមាជិកនៃគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព(យ៉ាងតិចវត្តមាន ៧០ភាគរយ នៃសមាជិកទាំងអស់)។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ៣ | មានកិច្ចប្រជុំ និងរបាយការណ៍/កំណត់ហេតុ ជាប្រចាំ (មានរបាយការណ៍/កំណត់ហេតុ ៥ទៅ៦ដង ផ្តល់ពិន្ទុ៣, មានរបាយការណ៍/កំណត់ហេតុ ចាប់ពី៣ទៅ៤ដង ផ្តល់ពិន្ទុ២, មានរបាយការណ៍/កំណត់ហេតុ ចាប់ពី១ទៅ២ដង ផ្តល់ពិន្ទុ១) |
| ពិន្ទុ ១ | ភាពពេញលេញនៃរបាយការណ៍/កំណត់ហេតុ(របៀបវារៈ កាលបរិច្ឆេទ ហត្ថលេខារបស់ប្រធានអង្គប្រជុំ...) |
| ពិន្ទុ ១ | បញ្ជីវត្តមាននៃកិច្ចប្រជុំនីមួយៗដោយមានចុះហត្ថលេខារបស់សមាជិកនៃគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព (យ៉ាងតិចវត្តមាន ៧០ភាគរយ នៃសមាជិកទាំងអស់) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ពិនិត្យលើរបាយការណ៍/កំណត់ហេតុប្រជុំ ក្នុងឆ្នាំកន្លងមក។

### ៦.១.៣ ការពង្រឹងទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ (១០ពិន្ទុ)

➢ **ការផ្សារភ្ជាប់មណ្ឌលសុខភាពជាមួយនឹងមន្ទីរពេទ្យបង្អែក និងសហគមន៍**

- ***សេចក្តីពន្យល់៖*** ការផ្សារភ្ជាប់មណ្ឌលសុខភាពជាមួយនឹងមន្ទីរពេទ្យបង្អែកសំដៅដល់ទំនាក់ទំនងរវាងមណ្ឌលសុខភាពជាមួយមន្ទីរពេទ្យបង្អែកក្នុងការគាំទ្រផ្នែកបច្ចេកទេស(គ្លីនិក) ការគ្រប់គ្រងប្រព័ន្ធបញ្ជូនជំងឺពីមណ្ឌលសុខភាពទៅមន្ទីរពេទ្យបង្អែក និងការផ្តល់ព័ត៌មានត្រឡប់ពីមន្ទីរពេទ្យបង្អែកមកមណ្ឌលសុខភាពវិញ។ ដោយឡែក ការផ្សារភ្ជាប់មណ្ឌលសុខភាពជាមួយនឹងសហគមន៍សំដៅដល់ទំនាក់ទំនងរវាងមណ្ឌលសុខភាពជាមួយសហគមន៍ក្នុងការពិគ្រោះយោបល់ ដើម្បីគាំទ្រដល់ដំណើរការនៃការផ្តល់សេវារបស់មណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ទំនាក់ទំនងរវាងមណ្ឌលសុខភាពជាមួយនឹងមន្ទីរពេទ្យបង្អែកក្នុងការគាំទ្រផ្នែកបច្ចេកទេស និងការផ្តល់ព័ត៌មានទៅវិញទៅមករវាងមន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាព។ ២)ទំនាក់ទំនងរវាងមណ្ឌលសុខភាពជាមួយនឹងសហគមន៍ក្នុងការពិគ្រោះយោបល់ ដើម្បីគាំទ្រដល់ដំណើរការនៃការផ្តល់សេវារបស់មណ្ឌលសុខភាពដូចជាតម្លៃសេវា និងតម្រូវការផ្សេងៗរបស់ប្រជាពលរដ្ឋ។ សម្រាប់ពិនិត្យបណ្តាចំណុចខាងលើ គណៈកម្មការវាយតម្លៃត្រូវ ១)ពិនិត្យលើរបាយការណ៍កិច្ចប្រជុំ ឬរបាយការណ៍ស្តីពីការបណ្តុះបណ្តាល ឬបង្វឹក និង២)សម្ភាសន៍ជាមួយថ្នាក់ដឹកនាំមណ្ឌលសុខភាព។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មណ្ឌលសុខភាពទទួលបានការបណ្តុះបណ្តាល ឬបង្វឹកផ្នែកបច្ចេកទេសពីមន្ទីរពេទ្យបង្អែក |
| ពិន្ទុ ១ | ការផ្តល់ព័ត៌មានទៅវិញទៅមករវាងមន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាព |
| ពិន្ទុ ១ | កិច្ចពិភាក្សា និងការផ្តល់យោបល់ត្រឡប់អំពីបញ្ហាពាក់ព័ន្ធនឹងករណីជំងឺដែលបានបញ្ជូន |

| | |
|---|---|
| ពិន្ទុ ២ | មានការពិគ្រោះយោបល់ជាមួយសហគមន៍ស្តីពីតម្លៃសេវា ការចង់បានឬតម្រូវការរបស់ប្រជាពលរដ្ឋ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ការចុះផ្តល់សេវាដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ

- ***សេចក្តីពន្យល់៖*** សំដៅដល់ការចុះពិនិត្យនិងចែកថ្នាំដោយផ្ទាល់របស់ថ្នាក់ដឹកនាំនិងបុគ្គលិកមណ្ឌលសុខភាពចំពោះប្រជាពលរដ្ឋដែលស្ថិតក្នុងតំបន់ដែលមណ្ឌលសុខភាពគ្របដណ្តប់។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការចុះដាក់ថ្នាំអាល់បែតនិងបាញ់ថ្នាំមូស ២)តាមដានអ្នកជំងឺរបេង/ហាង់សិនដែលលះបង់ការព្យាបាល ៣)ការចុះផ្តល់ថ្នាំជីវជាតិអា និងថ្នាំព្រូន ៤)ការស្វែងរកកុមារដែលមានកង្វះអាហារូបត្ថម្ភស្រួចស្រាល់ធ្ងន់ធ្ងរ និង៥)ការតាមដានបញ្ហាជំងឺឆ្លងរាតត្បាតដែលកើតថ្មីក្នុងសហគមន៍។ សម្រាប់ពិនិត្យបណ្តាចំណុចខាងលើ គណៈកម្មការវាយតម្លៃត្រូវ ១)ពិនិត្យលើរបាយការណ៍ ២)សម្ភាសន៍ជាមួយថ្នាក់ដឹកនាំមណ្ឌលសុខភាព និង៣) សម្ភាសន៍ជាមួយប្រជាពលរដ្ឋតាមរយៈទូរស័ព្ទ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | ការចុះដាក់ថ្នាំអាល់បែតនិងបាញ់ថ្នាំមូស |
| ពិន្ទុ ១ | ការតាមដានអ្នកជំងឺរបេង/ហាង់សិនដែលលះបង់ការព្យាបាល |
| ពិន្ទុ ១ | ការចុះផ្តល់ថ្នាំជីវជាតិអា និងថ្នាំព្រូន |
| ពិន្ទុ ១ | ការស្វែងរកកុមារដែលមានកង្វះអាហារូបត្ថម្ភស្រួចស្រាល់ធ្ងន់ធ្ងរ |
| ពិន្ទុ ១ | ការតាមដានបញ្ហាជំងឺឆ្លងរាតត្បាតដែលកើតថ្មីក្នុងសហគមន៍ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ៦.១.៤ ការកៀរគរធនធាន និងការសហការជាមួយដៃគូអភិវឌ្ឍ (១០ពិន្ទុ)

➢ ការកៀរគរធនធាន(ថវិកា សម្ភារៈ...)ពីសប្បុរសជន និងដៃគូអភិវឌ្ឍ

- ***សេចក្តីពន្យល់៖*** សំដៅដល់ការកៀរគរធនធានពីសប្បុរសជន និងដៃគូអភិវឌ្ឍដែលធ្វើឡើងដោយមណ្ឌលសុខភាពក្នុងគោលបំណងអភិវឌ្ឍមណ្ឌលសុខភាពឱ្យកាន់តែប្រសើរឡើង។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការឬគម្រោងដែលបង្ហាញពីតម្រូវការធនធានរបស់មណ្ឌលសុខភាព ២)ការប្រកាសឬអំពាវនាវរបស់មណ្ឌលដល់សប្បុរសជន និងដៃគូអភិវឌ្ឍ និង៣)ការចូលរួមគាំទ្រពីសប្បុរសជន និងដៃគូអភិវឌ្ឍ។ សម្រាប់ពិនិត្យបណ្តាចំណុចខាងលើ គណៈកម្មការវាយតម្លៃត្រូវ ១)ពិនិត្យលើផែនការ និងរបាយការណ៍ និង២)សម្ភាសន៍ជាមួយថ្នាក់ដឹកនាំមណ្ឌលសុខភាព និង៣)ការអង្កេតជាក់ស្តែង។

- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ១ | មណ្ឌលសុខភាពមានផែនការឬគម្រោងដែលបង្ហាញពីតម្រូវការធនធាន |
| ពិន្ទុ ១ | មណ្ឌលសុខភាពបានប្រកាសឬអំពាវនាវដល់សប្បុរសជន និងដៃគូអភិវឌ្ឍ |
| ពិន្ទុ ៣ | មានការចូលរួមឧបត្ថម្ភគាំទ្រពីសប្បុរសជន អង្គការជាតិ និងអង្គការអន្តរជាតិ(ដៃគូអភិវឌ្ឍ) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ➢ ការសហការ និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ អង្គការជាតិ និងអន្តរជាតិ លើការងារសុខភាព

- ***សេចក្តីពន្យល់៖*** សំដៅដល់កិច្ចសហប្រតិបត្តិការរវាងមណ្ឌលសុខភាពជាមួយដៃគូអភិវឌ្ឍ អង្គការជាតិ/អន្តរជាតិ ក្នុងការគាំទ្រផ្នែកបច្ចេកទេស ការព្យាបាល និងការគាំទ្រក្នុងរូបភាពផ្សេងៗ ដើម្បីលើកកម្ពស់គុណភាពនៃការផ្តល់សេវារបស់មណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ការសហការនិងការគាំទ្រពីដៃគូអភិវឌ្ឍ អង្គការជាតិ/អន្តរជាតិលើការងារសុខភាព(ផ្តល់ការបណ្តុះបណ្តាល ការព្យាបាល និងការគាំទ្រក្នុងរូបភាពផ្សេងៗ)។ សម្រាប់ពិនិត្យបណ្តាចំណុចខាងលើ គណៈកម្មការវាយតម្លៃត្រូវ ១)ពិនិត្យលើរបាយការណ៍ និង២)សម្ភាសន៍ជាមួយថ្នាក់ដឹកនាំមណ្ឌលសុខភាព។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ២ | មណ្ឌលសុខភាពទទួលបានការបណ្តុះបណ្តាលពីដៃគូអភិវឌ្ឍ អង្គការជាតិ និងអន្តរជាតិ |
| ពិន្ទុ ២ | មានកិច្ចសហការជាមួយដៃគូអភិវឌ្ឍ អង្គការជាតិ និងអន្តរជាតិក្នុងការព្យាបាល |
| ពិន្ទុ ១ | ផ្តល់ការគាំទ្រដល់ដំណើរការក្នុងការផ្តល់ និងទទួលសេវា |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

# ផ្នែកទី៧៖ ការដោះស្រាយបញ្ហាប្រឈម ជាមួយប្រជាពលរដ្ឋ អាជ្ញាធរ និងសហគមន៍

## ៧. ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ អាជ្ញាធរ និងសហគមន៍ (២៥ពិន្ទុ)

ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ អាជ្ញាធរ និងសហគមន៍ គឺជាយន្តការនៃការទទួល និងផ្តល់ព័ត៌មានត្រឡប់ ព្រមទាំងដោះស្រាយសំណើ សំណូមពរនានារបស់អ្នកទទួលសេវា តាមរយៈការបង្កើតក្រុមការងារ និងមធ្យោបាយផ្សេងៗរបស់មណ្ឌលសុខភាព ដោយមានកិច្ចសហការនិងការសម្របសម្រួលជាមួយអាជ្ញាធរពាក់ព័ន្ធ មណ្ឌលសុខភាពផ្សេងទៀត និងសហគមន៍មូលដ្ឋាន។ យន្តការនេះនឹងធានាថាអ្នកប្រើប្រាស់សេវាអាចមានលទ្ធភាពក្នុងការផ្តល់មតិយោបល់អំពីភាពអសកម្ម និងចំណុចខ្វះខាតរបស់មណ្ឌលសុខភាព ព្រមទាំងអាចទទួលបានការឆ្លើយតបពីមណ្ឌលសុខភាព សំដៅលើកកម្ពស់ប្រសិទ្ធភាព គុណភាព តម្លាភាព គណនេយ្យភាព និងការជឿទុកចិត្តក្នុងការផ្តល់សេវារបស់មណ្ឌលសុខភាព។

នៅក្នុងផ្នែកនៃការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ អាជ្ញាធរ និងសហគមន៍ មានពិន្ទុសរុបចំនួន២៥ ដែលមានលក្ខណៈវិនិច្ឆ័យរងចំនួន២ គឺ៖

**១. យន្តការព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា** (១៥ពិន្ទុ)

**២. ការសហការជាមួយអាជ្ញាធរ សហគមន៍ និងមណ្ឌលសុខភាពដទៃ ដើម្បីដោះស្រាយបញ្ហារបស់អ្នកប្រើប្រាស់សេវា** (១០ពិន្ទុ)

## ៧.១ យន្តការព័ត៌មានត្រឡប់ និងបណ្ដឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា (១៥ពិន្ទុ)

➢ <u>មានយន្តការទទួលព័ត៌មានត្រឡប់ និងបណ្ដឹងតវ៉ា</u>

- ***សេចក្ដីពន្យល់៖*** សំដៅដល់របៀប បែបបទ និងវិធីសាស្ត្រនៃការទទួលព័ត៌មាន និងបណ្ដឹងតវ៉ានានាពីអ្នកប្រើប្រាស់សេវា និងសាធារណជន ដោយបង្កលក្ខណៈងាយស្រួលឱ្យអ្នកប្រើប្រាស់សេវាអាចលើកឡើងនូវបញ្ហា និងសំណូមពរពាក់ព័ន្ធនឹងដំណើរការនៃការផ្ដល់សេវាសាធារណៈរបស់មណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)សេចក្ដីសម្រេចបង្កើតក្រុមការងារទទួលពាក្យបណ្ដឹងតវ៉ា និងផ្ដល់ព័ត៌មានត្រឡប់ ២)ប្រអប់បញ្ចេញមតិ ៣)ប្រព័ន្ធទំនាក់ទំនង (លេខទូរស័ព្ទ តេឡេក្រាម Facebook...) ដើម្បីទទួលព័ត៌មាន និងផ្ដល់ព័ត៌មានត្រឡប់ និង៤) មធ្យោបាយផ្សេងៗដើម្បីទទួលព័ត៌មាន និងផ្ដល់ព័ត៌មានត្រឡប់(ការជួបផ្ទាល់ កិច្ចប្រជុំជាមួយក្រុមទ្រទ្រង់សុខភាពភូមិ...)។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានក្រុមការងារទទួលពាក្យបណ្ដឹងតវ៉ា និងផ្ដល់ព័ត៌មានត្រឡប់ |
| ពិន្ទុ ១ | មានប្រអប់បញ្ចេញមតិ |
| ពិន្ទុ ១ | មានប្រព័ន្ធទំនាក់ទំនង (លេខទូរស័ព្ទ តេឡេក្រាម Facebook...) ដើម្បីទទួលព័ត៌មាន និងផ្ដល់ព័ត៌មានត្រឡប់ |
| ពិន្ទុ ២ | មានមធ្យោបាយផ្សេងៗដើម្បីទទួលព័ត៌មាន និងផ្ដល់ព័ត៌មានត្រឡប់(ការជួបផ្ទាល់ កិច្ចប្រជុំជាមួយក្រុមទ្រទ្រង់សុខភាពភូមិ...) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>មានការឆ្លើយតបទៅនឹងព័ត៌មានត្រឡប់ និងបណ្ដឹងតវ៉ា តាមពេលវេលាសមស្របតាមករណីនីមួយៗ</u>

- ***សេចក្ដីពន្យល់៖*** សំដៅដល់ការឆ្លើយតបរបស់មណ្ឌលសុខភាពចំពោះព័ត៌មានត្រឡប់ និងបណ្ដឹងតវ៉ារបស់អ្នកប្រើប្រាស់សេវាឬសាធារណជនដែលបានផ្ដល់ មុននឹងឈានទៅកំណត់ដំណោះស្រាយដាក់លាក់លើបណ្ដឹងតវ៉ា ឬសំណូមពរនីមួយៗ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការរៀបចំបែងចែកព័ត៌មានត្រឡប់ បណ្ដឹងតវ៉ា ឬសំណូមពរនានាទៅតាមប្រភេទ ២)ការរៀបចំកិច្ចប្រជុំពិនិត្យលើព័ត៌មានត្រឡប់និងបណ្ដឹងតវ៉ា ឬសំណូមពរនានា ៣)ការឆ្លើយតបចំពោះព័ត៌មានត្រឡប់ បណ្ដឹងតវ៉ា ឬសំណូមពរនានា និង៤)ការរក្សាទុកនូវព័ត៌មានត្រឡប់ បណ្ដឹងតវ៉ា ឬសំណូមពរនានា។ ក្នុងការពិនិត្យមើលចំណុចទាំង៤ខាងលើ គណៈកម្មការវាយតម្លៃត្រូវពិនិត្យលើរបាយការណ៍ និងការអង្កេតជាក់ស្ដែង។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការរៀបចំបែងចែកព័ត៌មានត្រឡប់ បណ្តឹងតវ៉ា ឬសំណូមពរនានាទៅតាមប្រភេទ |
| ពិន្ទុ ១ | មានកិច្ចប្រជុំពិនិត្យលើព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា ឬសំណូមពរនានា |
| ពិន្ទុ ២ | ការឆ្លើយតបចំពោះព័ត៌មានត្រឡប់ បណ្តឹងតវ៉ា ឬសំណូមពរនានាតាមមធ្យោបាយផ្សេងៗ |
| ពិន្ទុ ១ | មានការរក្សាទុកនូវព័ត៌មានត្រឡប់ បណ្តឹងតវ៉ា ឬសំណូមពរនានាដែលទទួលបាន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➤ <u>មានវិធានការដោះស្រាយក្រោយពេលទទួលបានព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់វិធានដោះស្រាយរបស់មណ្ឌលសុខភាពក្រោយពេលទទួលបានព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ាពីអ្នកប្រើប្រាស់សេវា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)វិធានការដោះស្រាយ និង២)ការតាមដានត្រួតពិនិត្យលើវិធានការដែលបានដាក់ចេញ។ ក្នុងការពិនិត្យមើលចំណុចខាងលើ គណៈកម្មការវាយតម្លៃត្រូវពិនិត្យលើរបាយការណ៍ស្តីពីវិធានការ ឬដំណោះស្រាយចំពោះព័ត៌មានត្រឡប់ បណ្តឹងតវ៉ា ឬសំណូមពរនានារបស់អ្នកប្រើប្រាស់សេវា និងការអង្កេតជាក់ស្តែង។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ៤ | មានវិធានការដោះស្រាយ៖<br>- ករណីមានវិធានការដោះស្រាយបានពី៩០ ទៅ១០០ភាគរយ នៃបណ្តឹងតវ៉ាឬសំណូមពរ ត្រូវផ្តល់ពិន្ទុ៤<br>- ករណីមានវិធានការដោះស្រាយបានពី៨០ ទៅ៨៩ភាគរយ នៃបណ្តឹងតវ៉ាឬសំណូមពរ ត្រូវផ្តល់ពិន្ទុ៣<br>- ករណីមានវិធានការដោះស្រាយបានពី៦៦ ទៅ៧៩ភាគរយ នៃបណ្តឹងតវ៉ាឬសំណូមពរ ត្រូវផ្តល់ពិន្ទុ២<br>- ករណីមានវិធានការដោះស្រាយបានពី៥០ ទៅ៦៥ភាគរយ នៃបណ្តឹងតវ៉ាឬសំណូមពរ ត្រូវផ្តល់ពិន្ទុ១ និង<br>- ករណីមានវិធានការដោះស្រាយបានក្រោម ៥០ភាគរយ នៃបណ្តឹងតវ៉ាឬសំណូមពរ ត្រូវផ្តល់ពិន្ទុ០។ |
| ពិន្ទុ ១ | មានការតាមដាន ត្រួតពិនិត្យលើវិធានការដែលបានដាក់ចេញ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ៧.២ ការសហការជាមួយអាជ្ញាធរ សហគមន៍ និងមណ្ឌលសុខភាពដទៃ ដើម្បីដោះស្រាយបញ្ហារបស់អ្នកប្រើប្រាស់សេវា (១០ពិន្ទុ)

➢ **កិច្ចសហការ និងការសម្របសម្រួលជាមួយអាជ្ញាធរ ដើម្បីដោះស្រាយបញ្ហារបស់អ្នកប្រើប្រាស់សេវា**

- ***សេចក្តីពន្យល់៖*** សំដៅដល់កិច្ចសហការ និងការសម្របសម្រួលរវាងមណ្ឌលសុខភាពជាមួយអាជ្ញាធរ ក្នុងការកែលម្អការផ្តល់សេវា និងដោះស្រាយបញ្ហាដែលស្នើឡើងដោយអ្នកប្រើប្រាស់សេវា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការចូលរួមវេទិកាសាធារណៈ និង២) កិច្ចប្រជុំពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន។ ក្នុងការពិនិត្យលើចំណុចទាំងនេះ គណៈកម្មការវាយតម្លៃត្រូវពិនិត្យលើរបាយការណ៍កិច្ចប្រជុំ ឬវេទិកាសាធារណៈ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានការចូលរួមវេទិកាសាធារណៈ |
| ពិន្ទុ ៣ | មានកិច្ចប្រជុំពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន (ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់...) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ **កិច្ចសហការ និងការសម្របសម្រួលជាមួយអាជ្ញាធរក្នុងការកៀរគរ និងប្រើប្រាស់ធនធានសម្រាប់អភិវឌ្ឍមណ្ឌលសុខភាព**

- ***សេចក្តីពន្យល់៖*** សំដៅដល់កិច្ចសហការ និងការសម្របសម្រួលរបស់មណ្ឌលសុខភាពជាមួយអាជ្ញាធរក្នុងការកៀរគរ និងប្រើប្រាស់ធនធានសម្រាប់អភិវឌ្ឍមណ្ឌលសុខភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍កិច្ចប្រជុំឬទំនាក់ទំនងរវាងមណ្ឌលសុខភាពជាមួយអាជ្ញាធរក្នុងការកៀរគរនិងប្រើប្រាស់ធនធាន និង២)របាយការណ៍កិច្ចប្រជុំឬទំនាក់ទំនងរវាងមណ្ឌលសុខភាពជាមួយសហគមន៍ក្នុងការកៀរគរធនធាន។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ៣ | មានកិច្ចប្រជុំឬទំនាក់ទំនងរវាងមណ្ឌលសុខភាពជាមួយអាជ្ញាធរក្នុងការកៀរគរ និងប្រើប្រាស់ធនធាន |
| ពិន្ទុ ២ | មានកិច្ចប្រជុំឬទំនាក់ទំនងរវាងមណ្ឌលសុខភាពជាមួយសហគមន៍ក្នុងការកៀរគរធនធាន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

# ផ្នែកទី៨៖ ការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍ ដើម្បីធ្វើឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរ

## ៨. ការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍ ដើម្បីធ្វើឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរ (១៥ពិន្ទុ)

ការកំណត់ការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍ដើម្បីធ្វើឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរជាលក្ខណៈវិនិច្ឆ័យគោលមួយនៃការវាយតម្លៃ ដើម្បីជំរុញឱ្យមណ្ឌលសុខភាពខិតខំគិត និងអនុវត្តន៍នូវអ្វីថ្មីៗតាមរយៈការប្រើប្រាស់នូវចំណេះដឹងថ្មី វិធីសាស្ត្រថ្មី បច្ចេកវិទ្យាថ្មី របកគំហើញថ្មី នៅក្នុងដំណើរការនៃការផ្តល់សេវារបស់ខ្លួន។

នៅក្នុងផ្នែកនៃការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍ដើម្បីធ្វើឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរ មានពិន្ទុសរុបចំនួន១៥ ដែលមានលក្ខណៈវិនិច្ឆ័យរងចំនួន២ គឺ៖

១. ការបញ្ជ្រាបការយល់ដឹងអំពីប្រធានបទនវានុវត្តន៍ និងការច្នៃប្រឌិតដើម្បីជំរុញឱ្យអង្គភាពដំណើរការកាន់តែប្រសើរ (៥ពិន្ទុ)

២. ការដឹកនាំអនុវត្ត ការជំរុញ និងការគាំទ្រការអនុវត្តគំនិតច្នៃប្រឌិត និងនវានុវត្តន៍ក្នុងអង្គភាពផ្តល់សេវា (១០ពិន្ទុ)

## ៨.១ ការបញ្ជ្រាបការយល់ដឹងអំពីប្រធានបទនវានុវត្តន៍ និងការច្នៃប្រឌិត ដើម្បីជំរុញឱ្យអង្គភាពដំណើរការកាន់តែប្រសើរ (៥ពិន្ទុ)

➢ ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ និងការបញ្ជ្រាបការយល់ដឹងអំពីប្រធានបទពាក់ព័ន្ធនឹងនវានុវត្តន៍ និងការច្នៃប្រឌិត

- ***សេចក្តីពន្យល់៖*** សំដៅដល់ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ និងការបញ្ជ្រាបការយល់ដឹងអំពីការគិត និងការអនុវត្តថ្មីៗនៅក្នុងការបំពេញភារកិច្ចរបស់បុគ្គលិក ដែលអនុវត្តឬរៀបចំឡើងដោយមណ្ឌលសុខភាព ឬអង្គភាពផ្សេង។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ របាយការណ៍នៃការបណ្តុះបណ្តាលដែលអនុវត្តឬរៀបចំឡើងដោយមណ្ឌលសុខភាព ឬអង្គភាពផ្សេង និង២)ការសម្ភាសជាមួយប្រធានមណ្ឌលសុខភាព និងបុគ្គលិកដែលធ្លាប់ទទួលបានការបណ្តុះបណ្តាល។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | ការបណ្តុះបណ្តាលដែលអនុវត្តឬរៀបចំឡើងដោយមណ្ឌលសុខភាព(យ៉ាងតិចចំនួន ២ដងក្នុង១ឆ្នាំ) |
| ពិន្ទុ ២ | ចំនួនបុគ្គលិកដែលទទួលបានបណ្តុះបណ្តាលដែលអនុវត្តឬរៀបចំឡើងដោយអង្គភាពផ្សេង(បានចំនួន៨០ភាគរយឡើងត្រូវបានផ្តល់ពិន្ទុ២ បានចំនួនចន្លោះពី៦០ភាគរយដល់៧៩ភាគរយ ត្រូវបានផ្តល់ពិន្ទុ១ បានចំនួនទាបជាង៦០ភាគរយ ត្រូវបានផ្តល់ពិន្ទុ០) |
| ពិន្ទុ ១ | ការគាំទ្រចំពោះបុគ្គលិកដែលធ្វើការបណ្តុះបណ្តាលដោយអង្គភាពផ្សេង |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** នវានុវត្តន៍សំដៅដល់ការអនុវត្តនូវអ្វីថ្មីៗ តាមរយៈការប្រើប្រាស់នូវចំណេះដឹងថ្មី វិធីសាស្ត្រឬយុទ្ធសាស្ត្រថ្មី គោលដៅថ្មី បច្ចេកវិទ្យាថ្មី និង/ឬរបកគំហើញថ្មី។ លក្ខណៈវិនិច្ឆ័យនេះត្រូវបានបែងចែកជា៣លក្ខណៈវិនិច្ឆ័យលម្អិត ដែលលក្ខណៈវិនិច្ឆ័យលម្អិតទី១ ត្រូវបានផ្តល់ពិន្ទុ២ លក្ខណៈវិនិច្ឆ័យលម្អិតទី២ ត្រូវបានផ្តល់ពិន្ទុ២ និងលក្ខណៈវិនិច្ឆ័យលម្អិតទី៣ ត្រូវបានផ្តល់ពិន្ទុ១។ ពិន្ទុសរុបនៅលក្ខណៈវិនិច្ឆ័យនេះមានចំនួន៥។

## ៨.២ ការដឹកនាំអនុវត្ត ការជំរុញ និងការគាំទ្រការអនុវត្តគំនិតច្នៃប្រឌិត និងនវានុវត្តន៍ក្នុងអង្គភាពផ្តល់សេវា (១០ពិន្ទុ)

➢ នវានុវត្តន៍ក្នុងការអភិវឌ្ឍមណ្ឌលសុខភាព

- ***សេចក្តីពន្យល់៖*** សំដៅដល់ការប្រើប្រាស់គំនិតថ្មីៗរបស់ថ្នាក់ដឹកនាំនិងបុគ្គលិករបស់មណ្ឌលសុខភាព ដើម្បីកៀរគរនិងកែច្នៃធនធាននិងនីតិវិធីបំពេញការងារក្នុងគោលបំណងបង្កើនគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការបំពេញការងារនិងការផ្តល់សេវារបស់អង្គភាព។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)នវានុវត្តន៍ក្នុងការងារគ្រប់គ្រង ២) នវានុវត្តន៍ក្នុងការផ្តល់សេវា(ការប្រើប្រាស់ឧបករណ៍ បរិក្ខាពេទ្យ និងការផ្តល់សេវាឱ្យកាន់តែប្រសើរឡើង) ៣)នវានុវត្តន៍ក្នុងការងារបរិស្ថាន និង៤)នវានុវត្តន៍ក្នុងការកៀរគរធនធាន។ ដើម្បីពិនិត្យមើលចំណុចខាងលើ គណៈកម្មការវាយតម្លៃត្រូវ ១)ពិនិត្យរបាយការណ៍ ២)ការជួបសម្ភាសន៍ និង ៣)ការអង្កេតជាក់ស្តែង។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | នវានុវត្តន៍ក្នុងការងារគ្រប់គ្រង |
| ពិន្ទុ ១ | នវានុវត្តន៍ក្នុងការងារបរិស្ថាន |
| ពិន្ទុ ១ | នវានុវត្តន៍ក្នុងការកៀរគរធនធាន |
| ពិន្ទុ ២ | នវានុវត្តន៍ក្នុងការផ្តល់សេវា(ការប្រើប្រាស់ឧបករណ៍ បរិក្ខាពេទ្យ និងការផ្តល់សេវាឱ្យកាន់តែប្រសើរឡើង) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យនេះត្រូវបានបែងចែកជា៤លក្ខណៈវិនិច្ឆ័យលម្អិត ដែលលក្ខណៈវិនិច្ឆ័យលម្អិតទី១ត្រូវបានផ្តល់ពិន្ទុ១ លក្ខណៈវិនិច្ឆ័យលម្អិតទី២ត្រូវបានផ្តល់ពិន្ទុ១ លក្ខណៈវិនិច្ឆ័យលម្អិតទី៣ត្រូវបានផ្តល់ពិន្ទុ១ និង លក្ខណៈវិនិច្ឆ័យលម្អិតទី៤ត្រូវបានផ្តល់ពិន្ទុ២ ។ ពិន្ទុសរុបនៅលក្ខណៈវិនិច្ឆ័យនេះមានចំនួន៥។

➢ **ការគាំទ្រនិងលើកទឹកចិត្តដើម្បីជំរុញឱ្យមាននវានុវត្តន៍ក្នុងមណ្ឌលសុខភាព**

- ***សេចក្តីពន្យល់៖*** សំដៅដល់ការគាំទ្រនិងលើកទឹកចិត្តរបស់ថ្នាក់ដឹកនាំមណ្ឌលសុខភាពចំពោះបុគ្គលិកដែលមានគំនិតនវានុវត្តន៍នៅក្នុងការបំពេញការងារ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការសរសើរ ២)លាភការសម្រាប់លើកទឹកចិត្ត ៣)ការស្វែងរកឬកៀរគរធនធានដើម្បីគាំទ្រដល់សកម្មភាពដែលមានលក្ខណៈនវានុវត្តន៍ និង៤)ការផ្តល់ឱកាសចំពោះបុគ្គលិកដែលមានគំនិតនវានុវត្តន៍ក្នុងការបញ្ចេញស្នាដៃរបស់ខ្លួន។ ដើម្បីពិនិត្យមើលចំណុចខាងលើ គណៈកម្មការវាយតម្លៃត្រូវ ១)ជួបសម្ភាសន៍ជាមួយថ្នាក់ដឹកនាំមណ្ឌលសុខភាព និងបុគ្គលិកដែលមានគំនិតនវានុវត្តន៍ និង២)ការអង្កេតជាក់ស្តែង។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | ការសរសើរ(លិខិតសរសើរ ការសរសើរក្នុងកិច្ចប្រជុំ) |
| ពិន្ទុ ១ | លាភការសម្រាប់លើកទឹកចិត្ត |
| ពិន្ទុ ១ | ការផ្តល់ឱកាសចំពោះបុគ្គលិកដែលមានគំនិតនវានុវត្តន៍ក្នុងការបញ្ចេញស្នាដៃរបស់ខ្លួន |

| | |
|---|---|
| ពិន្ទុ ២ | ការស្វែងរកឬកៀរគរធនធានដើម្បីគាំទ្រដល់សកម្មភាពដែលមានលក្ខណៈនវានុវត្តន៍ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យនេះត្រូវបានបែងចែកជា៤លក្ខណៈវិនិច្ឆ័យលម្អិត ដែលលក្ខណៈវិនិច្ឆ័យលម្អិតទី១ ត្រូវបានផ្តល់ពិន្ទុ១ លក្ខណៈវិនិច្ឆ័យលម្អិតទី២ ត្រូវបានផ្តល់ពិន្ទុ១ លក្ខណៈវិនិច្ឆ័យលម្អិតទី៣ ត្រូវបានផ្តល់ពិន្ទុ១ និង លក្ខណៈវិនិច្ឆ័យលម្អិតទី៤ ត្រូវបានផ្តល់ពិន្ទុ២។ ពិន្ទុសរុបនៅលក្ខណៈវិនិច្ឆ័យនេះមានចំនួន៥។

# សេចក្តីសន្និដ្ឋាន

ការស្វែងយល់ និងប្រតិបត្តិតាមឯកសារណែនាំស្តីពីវិធីសាស្ត្រនៃការវាយតម្លៃ និងការទទួលស្គាល់មណ្ឌលសុខភាពគំរូ នឹងធ្វើឱ្យគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូគ្រប់កម្រិតអនុវត្តការងារវាយតម្លៃរបស់ខ្លួនប្រកបដោយសុក្រឹតភាពផ្អែកលើមូលដ្ឋានច្បាស់លាស់ ព្រមទាំងធ្វើឱ្យមណ្ឌលសុខភាពទូទាំងប្រទេសអភិវឌ្ឍខ្លួនឈានទៅក្លាយជាអង្គភាពគំរូគួរជាទីពេញចិត្ត និងជឿទុកចិត្តពីប្រជាជន។ ដូចនេះ គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូទាំងអស់គួរសិក្សាពីខ្លឹមសារនៃអត្ថបទឯកសារណែនាំនេះប្រកាន់ខ្ជាប់នូវវិធីសាស្ត្រនៃការវាយតម្លៃដែលផ្តល់ជូនក្នុងការអនុវត្តតួនាទីវាយតម្លៃរបស់ខ្លួន ព្រមទាំងចូលរួមផ្សព្វផ្សាយខ្លឹមសារនៃឯកសារណែនាំនេះឱ្យជ្រាបដល់គណៈគ្រប់គ្រងមណ្ឌលសុខភាព និងភាគីពាក់ព័ន្ធឱ្យចូលរួមរៀបចំ និងអភិវឌ្ឍមណ្ឌលសុខភាពតាមគន្លងនៃអង្គភាពផ្តល់សេវាសុខាភិបាលគំរូនេះ។ គណៈគ្រប់គ្រងមណ្ឌលសុខភាពត្រូវយកចិត្តទុកដាក់ស្វែងយល់ ផ្សព្វផ្សាយជូនដល់បុគ្គលិករបស់ខ្លួន ព្រមទាំងកៀរគរការចូលរួមពីប្រជាជន សហគមន៍ អាជ្ញាធរ និងដៃគូអភិវឌ្ឍ ក្នុងការអភិវឌ្ឍមណ្ឌលសុខភាព ឱ្យស្របតាមលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងឯកសារណែនាំនេះ។

មណ្ឌលសុខភាពផ្តល់សេវាប្រកបដោយគុណភាព នឹងរួមចំណែកក្នុងការលើកកម្ពស់កម្រិតជីវភាព និងសុខុមាលភាពរបស់ប្រជាជនឱ្យកាន់តែប្រសើរឡើង ដែលជាបច្ច័យក្នុងការនាំកម្ពុជាឆ្ពោះទៅកាន់ឋានៈជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ ២០៥០ តាមបំណងដ៏ពិសិដ្ឋរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជូនដល់ប្រជាជនកម្ពុជា។

# គន្ថនិទ្ទេស

| ល.រ | ឈ្មោះឯកសារ |
|---|---|
| ១ | អនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសំណល់រឹង |
| ២ | អនុក្រឹត្យលេខ ៤៥៥ អនុក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិវាយតម្លៃសេវាសាធារណៈ និងឧបសម្ព័ន្ធ៖ ឯកសារណែនាំស្តីពីស្តង់ដាសេវាសាធារណៈ |
| ៣ | អនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន |
| ៤ | អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ |
| ៥ | អនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក |
| ៦ | អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល |
| ៧ | រាជរដ្ឋាភិបាលកម្ពុជា, ឆ្នាំ២០០៦ គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ |
| ៨ | រាជរដ្ឋាភិបាលកម្ពុជា, ឆ្នាំ២០១៣ គោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ |
| ៩ | រាជរដ្ឋាភិបាលកម្ពុជា, ឆ្នាំ២០១៩ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ |
| ១០ | ក្រសួងសុខាភិបាល, ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០ |
| ១១ | ក្រសួងសុខាភិបាល, ចុះថ្ងៃទី១០ ខែមករា ឆ្នាំ១៩៩៨ សេចក្តីណែនាំសម្រាប់អភិវឌ្ឍស្រុកប្រតិបត្តិ |
| ១២ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ |
| ១៣ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម |
| ១៤ | ក្រសួងសុខាភិបាល, ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨ សេចក្តីណែនាំប្រតិបត្តិស្តីពីសំណុំសកម្មភាពអប្បបរមា |
| ១៥ | នាយកដ្ឋានមន្ទីរពេទ្យ ក្រសួងសុខាភិបាល, ឆ្នាំ២០១៤ មគ្គុទេសក៍ស្តីពីសុវត្ថិភាពនៃការចាក់ថ្នាំ |
| ១៦ | នាយកដ្ឋានមន្ទីរពេទ្យ ក្រសួងសុខាភិបាល, ឆ្នាំ២០១៧ គោលការណ៍ណែនាំស្តីពីការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ |
| ១៧ | នាយកដ្ឋានមន្ទីរពេទ្យ ក្រសួងសុខាភិបាល, ឆ្នាំ២០១៨ គោលការណ៍ណែនាំស្តីពីទឹកស្អាត និងអនាម័យនៅមូលដ្ឋានព្យាបាល និងថែទាំសុខភាព |

| | |
|---|---|
| ១៨ | នាយកដ្ឋានមន្ទីរពេទ្យ ក្រសួងសុខាភិបាល, ឆ្នាំ២០១៨ សេចក្តីណែនាំគ្លីនិកស្តីពីសំណុំសកម្មភាពអប្បបរមា |
| ១៩ | នាយកដ្ឋានមន្ទីរពេទ្យ ក្រសួងសុខាភិបាល, ឆ្នាំ២០១៨ សេចក្តីណែនាំប្រតិបត្តិស្តីពីសំណុំសកម្មភាពអប្បបរមា |

**សហការរៀបចំដោយ**

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ
giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH


**ក្រសួងមុខងារសាធារណៈ**

ផ្លូវអេង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ/ទូរសារ៖ +៨៥៥ ២៣ ៨៦៦ ៥០១

គេហទំព័រ៖ http//www.mcs.gov.kh

បណ្តាញទំនាក់ទំនងសង្គម៖ http//www.facebook.com/CivilServiceCambodia